## ក្រសួងអប់រំ យុវជន និងកីឡា

# កាលិកបត្រ

# អប់រំ

# កម្ពុជា

វ៉ុល ៥ លេខ ១ ពិសេស

មិថុនា ២០២២

# កាលិកបត្រ

# អប់រំ

# កម្ពុជា

## វ៉ុល ៥ លេខ ១ ពិសេស

**រក្សាសិទ្ធិ © កាលិកបត្រអប់រំកម្ពុជា**

ការបោះពុម្ពនេះ គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា(អយក) និងកម្ចីឥណទានធនាគារអភិវឌ្ឍន៍អាស៊ី លេខ ៣៤២៧ CAM(COL)

គ្មានផ្នែកណាមួយនៃការបោះពុម្ពនេះ អាចត្រូវបានយកទៅផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ។

បោះពុម្ព និងវាយអក្សរ នៅប្រទេសកម្ពុជា ដោយកាលិកបត្រអប់រំកម្ពុជា

**អាលិកបត្រ**

**អប់រំ**

**កម្ពុជា**

**ក្រុមប្រឹក្សានិពន្ធ**

**ក្រុមប្រឹក្សាវិចារណកថា**

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តម លឹម សុជា *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិត ឌី សមស៊ីដេត *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តម អ៊ុង បូរាត *ក្រសួងអប់រំ យុវជន និងកីឡា*

ឯកឧត្តមបណ្ឌិត ឌី ខាំបូលី *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត ហេង គ្រេង *ក្រសួងអប់រំ យុវជន និងកីឡា*

លោកបណ្ឌិត អ៊ុន លាង *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

លោកបណ្ឌិត សុខ សូត្រ *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

ឯកឧត្តមបណ្ឌិត យ៉ាស៊ូស៊ី ហ៊ីរ៉ូសាតុ *សាកលវិទ្យាល័យសុភា ប្រទេសជប៉ុន*

**និពន្ធនាយក**

លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា *ក្រសួងអប់រំ យុវជន និងកីឡា*

**និពន្ធនាយករង**

លោកបណ្ឌិត ងិន ច័ន្ទរិទ្ធ *សាកលវិទ្យាល័យអុកឡែន ប្រទេសនូវែលសេឡង់*

លោកបណ្ឌិត សុខ សិរី *សាកលវិទ្យាល័យភូមិន្ទភ្នំពេញ*

លោកបណ្ឌិត កែវ រតនៈ *ក្រសួងអប់រំ យុវជន និងកីឡា*

## មាតិកា


ក្រុមប្រឹក្សានិពន្ធ i

មាតិកា ii

ទស្សនវិស័យនៃការត្រៀមខ្លួនដើម្បីប្រែក្លាយសាលាធនធានជាសាលារៀនជំនាន់ថ្មី៖ ករណីសិក្សាវិទ្យាល័យខ្ញូវ ប៊ុនស៊ុន ក្រចេះក្រុង ១-១០

ហួ កែវពិសិដ្ឋ, ស៊ីន ភារ៉ា, រុន ដារ៉ា, អ៊ុត កញ្ញា, ស្រី កុត និង ម៉ា ប៊ុងឃី

ការមករៀនមិនទាន់ពេលវេលារបស់សិស្សក្នុងវិទ្យាល័យក្រឡាញ់ ១១-១៩

ឡាំ សំអាន, ហ៊ី សុផាត, ហ៊ាន់ ជីវ៉ា, តន់ អាន់, ឡុច វិន្ថា, ប៉ាន់ ប៉ុនធឿន, តឹក ចាន់រី, សោម ណារុណ, ធន សមន្ធា, ខេង សារដ្ឋ និង សៅ មន

មូលហេតុអ្វីសិស្សមួយចំនួនមិនសូវចេះអានអក្សរនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ខេត្តកំពង់ធំ ២០-២៨

អែម អៀងស៊ន, នាគ វ៉ាសុក្រី, សុក សុវិជ្ជា, ប៉ាង វ៉ាប៉ូលី, មាស សុគឿន, ទូច ធូ, អ៊ឹម យ៉ុនណារ៉ា, ភួ គឹមសាន, វេត កុល, អ៊ិត គឹមស្រ៊ុន និង កែ ដារិទ្ធ

តើវិទ្យាល័យព្រះបាទសុរាម្រឹតបានត្រៀមខ្លួនក្លាយជាសាលារៀនជំនាន់ថ្មីហើយឬនៅ ? ២៩-៣៥

លឿង បញ្ញាវុឌ្ឍ, ហុង សៅ, ហែម បញ្ញារិទ្ធិ, ឡុង ស៊ីដារុធ, ឃឹម ផាត, រី រំចេក និង សំ វីរៈ

កត្តាជះឥទ្ធិពលដល់សិស្សថ្នាក់ទី១០ រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ ៣៦-៤៦

សួរ ម៉ាឃូណែត, គុជ សំអែល, កឹម មង្គល, ប៉ែន វន្ថា, កូវ ធារី និង ឥន រិទ្ធី

មូលហេតុដែលនាំឱ្យសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម ៤៧-៦០

ញ៉េប សំណាង, ផុន ស្រីណុម និង ស្រីឈូវ សុខេង

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានគោលនយោបាយ

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# ទស្សនវិស័យនៃការត្រៀមខ្លួនដើម្បីប្រែក្លាយសាលាធនធានជាសាលារៀនជំនាន់ថ្មី៖ ករណីសិក្សាវិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង

ហួ កែវពិសិដ្ឋ*[១] ស៊ីន ភាព៉ា[២], រុន ដារ៉ា[៣], អ៊ុត កញ្ញា[៤], ស្រី កុត[៥], និង ម៉ា ប៊ុងឃី[៦]
*វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត ហេតុនេះបានជាប្រទេសនីមួយៗជានិច្ចកាលត្រូវការធនធានមនុស្សដែលមានចំណេះដឹង និងជំនាញប្រកបដោយសមត្ថភាពខ្ពស់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាកសាងសង្គមជាតិឱ្យបានរឹងមាំ។ ដើម្បីឆ្លើយតបនឹងទស្សនៈខាងលើ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្ដីពីសាលារៀនជំនាន់ថ្មី ក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំទាំងមូល។ ជាក់ស្ដែងសាលាធនធានមួយចំនួនបានក្លាយទៅជាសាលារៀនជំនាន់ថ្មី។ ចំណែកវិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង ក៏ជាសាលាធនធានមួយដែលបាននឹងកំពុងត្រៀមអភិវឌ្ឍខ្លួនទៅជាសាលារៀនជំនាន់ថ្មី ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីធ្វើការស្រាវជ្រាវបាន ក្រុមអ្នកស្រាវជ្រាវបានកំណត់ក្រុមគោលដៅ និងកំណត់ចំនួនសំណាកដែលត្រូវធ្វើការសម្ភាសសម្រាប់ក្រុមគោលដៅនីមួយៗ បន្ទាប់មកបង្កើតកម្រងសំណួរសម្រាប់ចុះសម្ភាសតាមគោលដៅដែលបានកំណត់។ ជាលទ្ធផលនៃការសិក្សា មតិភាគច្រើនបានគាំទ្រសាលាធនធាន ខូវ ប៊ុនស៊ុន ឱ្យប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី បើទោះបីមានមតិមួយចំនួនសម្ដែងមិនយល់ស្របនឹងគោលណ៍

សាលារៀនជំនាន់ថ្មីក៏ដោយ។ សរុបមក អ្នកចូលរួមភាគច្រើនបានបញ្ចេញទស្សនៈគាំទ្រការប្រែក្លាយសាលាធនធានវិទ្យាល័យខូវ ប៊ុនស៊ុន ក្រចេះក្រុងជាសាលារៀនជំនាន់ថ្មី។

**អាគតដ្ឋានៈ** ហួ, ក., ស៊ីន, ភ., រុន, ដ., អ៊ុត, ក.,ស្រី, ភ., &ម៉ា, ប.(២០២២). ទស្សនវិស័យនៃការត្រៀមខ្លួនដើម្បីប្រែក្លាយសាលាធនធានជាសាលារៀនជំនាន់ថ្មីៈ ករណីសិក្សាវិទ្យាល័យខូវ ប៊ុនស៊ុន ក្រចេះក្រុង,*កាលិកបត្រអប់រំកម្ពុជា,៥(១)*, ១-១០។

## ១. សេចក្តីផ្តើម

ក្រោមការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការបណ្តុះបណ្តាធនធានមនុស្សផ្នែកវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សា ក្រសួងបានបង្កើតគោលនយោបាយមួយចំនួនដើម្បីគាំទ្រការពង្រឹងសេវាអប់រំប្រកបដោយគុណភាព ជាពិសេសផ្នែកវិទ្យាសាស្ត្រដូចជា គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៨) គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦) និងគោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦) ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅយុគសម័យឌីជីថលឬឧស្សាហកម្ម៤.០។ ក្រៅពីការបង្កើតគោលនយោបាយក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលក៏កំពុងយកចិត្តដាក់ខ្ពស់លើបច្ចេកវិទ្យាព័ត៌មាន ដោយបានបង្កើតគោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០(ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា, ២០១៩) និងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ (ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ២០២១)។

សាលាមធ្យមសិក្សាធនធានគឺជាសាលាដែលត្រូវបានយកចិត្តទុកដាក់ខ្ពស់លើការបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើងជាដើម) ដើម្បីលើកស្ទួយការផ្តល់សេវាគុណភាពអប់រំផ្នែកវិទ្យាសាស្ត្រដល់សាលារៀន។ សាលាមធ្យមសិក្សាធនធាននឹងផ្តល់ការដឹកនាំ និងតម្រង់ទិសក្នុងការជួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ និងការប្រើប្រាស់វិធីសាស្ត្រថ្មីៗ ក្នុងការបង្រៀននិងរៀនដើម្បីគាំទ្រគោលយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាថ្មី។ យុទ្ធសាស្ត្របណ្តាញសាលាមធ្យមសិក្សាធនធានរួមមាន ការបណ្តុះវប្បធម៌ធ្វើការងារជាមួយគ្នា ដកបទពិសោធការងារពីគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នារវាងសាលារៀននានា និងសាលារៀនក្នុងបណ្តាញ ព្រមទាំងសហគមន៍

ឱ្យបានទូលំទូលាយ។ សាលារៀនក្នុងបណ្ដាញអាចប្រើប្រាស់សម្ភារៈរូបវន្តរបស់សាលាធនធានដែលជាស្នូលរបស់បណ្ដាញ។ ទោះបីជា សាលាមធ្យមសិក្សាធនធានមានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តជាច្រើន ដើម្បីគាំទ្រដល់ការអប់រំតាមបែបទំនើបយ៉ាងណាក៏ដោយ សាលាធនធាននៅតែមិនទាន់ឆ្លើយតបបានល្អទៅនឹងការរំពឹងទុកដូចសាលារៀនជំនាន់ថ្មី ទើបក្រសួងមានគម្រោងពង្រីកវិសាលភាពសាលាធនធានឱ្យប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដែលស្របទៅនឹងគោលនយោបាយស្ដីពីសាលារៀនជំនាន់ថ្មីក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំ(គោលនយោបាយសាលាមធ្យមសិក្សាធនធាន, ២០០៨)។

គោលនយោបាយសាលារៀនជំនាន់ថ្មីបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមមាននៅកម្ពុជាក្នុងសតវត្សរ៍ទី ២១។ បញ្ហាប្រឈមទាំងនោះលេចចេញពីប្រភពជាច្រើនរួមមាន សមាហរណកម្មនៃសហគមន៍អាស៊ាន ការកើនឡើងនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជ្រាតចូលយ៉ាងឆាប់រហ័សនូវប្រព័ន្ធបច្ចេកវិទ្យានៅក្នុងសង្គមកម្ពុជា ការកើនឡើងផ្នែកនគរូបនីយកម្ម ការពង្រីកសាលារៀនឯកជន និងចំនួនពលរដ្ឋជាយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលតម្រូវឱ្យមានសេចក្ដីណែនាំដ៏ទូលំទូលាយពីជម្រើស និងគំនិតប្រកួតប្រជែងនៅក្នុងពិភពលោកបច្ចុប្បន្ន។ សាលារៀនជំនាន់ថ្មីព្យាយាមបង្កើតគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់នឹងស្តង់ដាថ្មី ដោយមានគណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សរ៍ទី២១។ សាលារៀនជំនាន់ថ្មីមានគោលដៅបង្កើតសាលារៀនសាធារណៈស្វយ័តដែលគ្រប់គ្រងដោយវិន័យតឹងរឹងក្នុងការបំពេញភារកិច្ចនិងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់ កែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗ ដែលរួមបញ្ចូលការជ្រើសរើសគ្រូដោយការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ច ការបំប៉នសមត្ថភាពគ្រូបង្រៀនបន្ថែមលើផ្នែកបច្ចេកវិទ្យាអប់រំ វិធីសាស្ត្របង្រៀន STEM និងការសិក្សាឱ្យស្គាល់បញ្ហា និងការរកដំណោះស្រាយ ព្រមទាំងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននិងពង្រីកសេវាអប់រំសម្រាប់យុវជនកម្ពុជាដែលរួមបញ្ចូលទាំងសេវាប្រឹក្សាអាជីព សកម្មភាពសិក្សាប្លែកៗដូចជា ការងារគម្រោង ក្លឹបអ្នកសិក្សាតាមមុខវិជ្ជា ការសិក្សាតាមឧបករណ៍ចល័ត និងកម្មវិធីសិក្សាបំណិនជីវិត។ ដើម្បីសម្រេចបានគោលបំណង និងគោលដៅដែលបានកំណត់ ក្រសួងបានដាក់យុទ្ធសាស្ត្រសំខាន់ៗដូចជា ១) ជ្រើសរើសសាលារៀនគោលដៅយ៉ាងហ្មត់ចត់ដោយជ្រើសយកសាលាដែលមានសក្ដានុពលពេញលេញក្នុងការវិនិយោគឱ្យមានប្រសិទ្ធភាពខ្ពស់ ២ ) កសាងភាពជាដៃគូជិតស្និទ្ធជាមួយតួអង្គមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីការអនុវត្តនិងជួយផ្ដត់ផ្គង់ធនធានដល់សាលារៀនជំនាន់ថ្មី ៣) ជ្រើសរើសគណៈគ្រប់គ្រងសាលាតាមរយៈការប្រកួតប្រជែង ការលើកទឹកចិត្ត

ផ្សារភ្ជាប់នឹងការបំពេញភារកិច្ចបានល្អ ដើម្បីពង្រឹងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលារៀន ៤) ការផ្ដល់ប្រាក់លើកទឹកចិត្ត ពិសេសដល់គ្រូបង្រៀនដើម្បីលើកកម្ពស់ការបំពេញភារកិច្ចឈានទៅលុបបំបាត់ការបង្រៀនឯកជនដល់សិស្សរបស់ខ្លួនដែលប៉ះពាល់ដល់វិជ្ជាជីវៈ និងសេចក្ដីថ្លៃថ្នូរគ្រូបង្រៀន ៥) ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយ ដើម្បីជំរុញការច្នៃប្រឌិតថ្មីគឺសិស្សមិនត្រឹមតែទទួលបានការប្រើប្រាស់ឧបករណ៍រឹងប៉ុណ្ណោះទេ ពួកគេនឹងទទួលបានការប្រើកម្មវិធីទន់ក្នុងការអប់រំទំនើបទៀតផង (ឧទាហរណ៍ កម្មវិធី Literatu, 3D classroom។ល។) ៦) ការប្រកាន់ខ្ជាប់នៅម៉ោងបង្រៀនតាមសេចក្ដីណែនាំផ្លូវការនិងបង្កើនម៉ោងរៀនរហូតដល់៣៦ ម៉ោង ក្នុងមួយសប្ដាហ៍ នៅកម្រិតបឋមសិក្សា និង៤០ម៉ោងក្នុងមួយសប្ដាហ៍សម្រាប់មធ្យមសិក្សា និង ៧) ការធ្វើទំនើបកម្មបរិស្ថានសិក្សា ដោយការប្រើគំនិតច្នៃប្រឌិតថ្មីក្នុងស្ថាបត្យកម្មអប់រំ ដើម្បីកែប្រែបន្ទប់រៀន និងបន្ទប់ផ្សេងទៀតឱ្យសម្របទៅនិងស្តង់ដាសាលារៀននាសតវត្សរ៍ទី ២១ (គោលនយោបាយសាលារៀនជំនាន់ថ្មី, ២០១៦)។

សព្វថ្ងៃនេះ ក្រសួងបាននិងកំពុងព្យាយាមប្រែក្លាយសាលាធនធានដែលមានស្រាប់នូវហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តទៅជាសាលារៀនជំនាន់ថ្មី។ វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង ជាសាលាធនធានមួយដែលបាននិងកំពុងប្រែក្លាយមុខមាត់ទៅជាសាលារៀនជំនាន់ថ្មីនាពេលខាងមុខ។ វិទ្យាល័យ ខូវ ប៊ុនស៊ុន ក្រចេះក្រុង មានទីតាំងនៅភូមិអូរឫស្សី២ សង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។ វិទ្យាល័យនេះបានកកើតតាំងពីសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៦៦មកម្ល៉េះ ហើយត្រូវបានដាក់ឈ្មោះថា អនុវិទ្យាល័យ ខូវ ប៊ុនស៊ុន ដែលកសាងឡើងដោយគហបតី ខូវ ប៊ុនស៊ុន។ នៅឆ្នាំ ១៩៧០-១៩៧៩ អនុវិទ្យាល័យ ខូវ ប៊ុនស៊ុន ត្រូវបានដាក់ជាមណ្ឌលកុមារ។ រហូតមកដល់ពេលនេះ ក្នុងការដឹកនាំ និងគ្រប់គ្រងវិទ្យាល័យដ៏ចំណាស់មួយនេះមានគណៈគ្រប់គ្រងចំនួន៤រូបមកហើយ ក្នុងនោះមានលោកនាយកទី១គឺ ស.ម ប៉ិច ផន នាយកទី២គឺ ស.ម សំ ស៊ា នាយកទី៣គឺ លោក នូ ផល្លុន នាយកទី៤គឺ លោក ហួ កែវពិសិដ្ឋ។ រហូតមកដល់ឆ្នាំ១៩៩៧ ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីសម្ដេចតេជោ ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានកសាងអគារចំនួន៣ ខ្នងស្មើនឹង ១០បន្ទប់។ នៅឆ្នាំ២០០៧ ធនាគារអភិវឌ្ឍអាស៊ី(ADB) បានសាងសង់អគារអន្តេវាសិកដ្ឋាននារីចំនួន០១ខ្នង ស្មើនឹ១៤បន្ទប់ និងនៅឆ្នាំ ២០១០ សាលាមានអគារធនធានចំនួន ០១ ខ្នង ស្មើនឹង ១៧ បន្ទប់ ដោយបំពាក់សម្ភារៈពិសោធន៍ សៀវភៅសម្រាប់ដាក់ក្នុងបណ្ណាល័យនិងកុំព្យូទ័រ។ បច្ចុប្បន្ន វិទ្យាល័យនេះមានគ្រូបង្រៀនសរុប ៦៧ នាក់ ស្រី ៣៦ នាក់ និងមានសិស្សសរុប ១២៤៦ នាក់ សិស្សស្រី ៦៧៨ នាក់ ដែលមានពីរកម្រិតសិក្សាគឺ មធ្យមសិក្សាបឋមភូមិ ថ្នាក់ទី ៧ ៨ ៩ មានសិស្សសរុប ៥២៣ នាក់ ស្រី ២៩៤ នាក់ និងមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ១១ ១២ មានសិស្សសរុប ៧២៣ នាក់ ស្រី ៣៨៤ នាក់។

**សំនួរស្រាវជ្រាវ៖** តើវិទ្យាល័យខូវ ប៊ុនស៊ុន ក្រចេះក្រុងត្រូវត្រៀមខ្លួនរបៀបណា ដើម្បីប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី?

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមការងារធ្វើការជ្រើសរើសអ្នកផ្ដល់សម្ភាសរួមមាន៖ លោកនាយក នាយករង គណៈកម្មការគ្រប់គ្រងសាលា គ្រូបង្រៀនបឋមភូមិ និងទុតិយភូមិ (ពីររូបក្នុងមួយកម្រិតថ្នាក់) អាណាព្យាបាលសិស្សដប់ពីររូបដែលមានកូនៗរៀននៅសាលានេះ ព្រមទាំងអាជ្ញាធរមូលដ្ឋាន។ អ្នកផ្ដល់សម្ភាសទាំងអស់គឺស្ថិតនៅក្នុងមូលដ្ឋានផ្ទាល់។

ចំពោះដំណើរការស្រាវជ្រាវ ក្រុមអ្នកស្រាវជ្រាវបានប្រជុំពិភាក្សាគ្នាអំពីប្រធានបទដើម្បីឱ្យសមាជិកក្នុងក្រុមបានយល់ស៊ីជម្រៅ បន្ទាប់មកក្រុមការងារក៏បានប្រជុំនៅថ្ងៃបន្ទាប់ ដើម្បីបង្កើតសំណួរគន្លឹះ ក៏ដូចជាកម្រងសំណួរសម្រាប់សម្ភាស។ ក្រុមអ្នកស្រាវជ្រាវក៏បានសម្រេចចែកឱ្យសមាជិកក្រុមម្នាក់ៗបង្កើតសំណួរគន្លឹះទៅតាមក្រុមគោលដៅ ដែលបានជ្រើសរើស ដែលមានសមាជិកចំនួន ០៦ នាក់ ដោយចែកជា០៤ក្រុមគោលដៅ។

នៅពេលបង្កើតសំណួរគន្លឹះរួចរាល់ហើយ សមាជិកម្នាក់បានទូរស័ព្ទស្នើសុំអញ្ជើញគណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋាននិងលោកគ្រូ អ្នកគ្រូពាក់ព័ន្ធដើម្បីឱ្យក្រុមការងារស្រាវជ្រាវបានសម្ភាសពាក់ព័ន្ធនឹងប្រធានបទខាងលើ។ ថ្ងៃសម្ភាសន៍ ក្រុមការងារបានទៅដល់ទីតាំងគោលដៅរៀងៗខ្លួន រួចហើយសមាជិកនីមួយៗបានសុំអនុញ្ញាតពីអ្នកផ្ដល់សម្ភាសដូចជា លោកនាយក គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល ដោយប្រាប់ពីមូលហេតុ និងគោលបំណងនៃការស្រាវជ្រាវអំពីប្រធានបទខាងលើ។ ក្រោយពីសមាជិកក្រុមបានជម្រាបនូវមូលហេតុនិងគោលបំណងរួចហើយ សមាជិកក្រុមបានធ្វើការសម្ភាសយកសំណាក តាមការបែងចែកខាងលើ។ រាល់ការសម្ភាសរបស់ក្រុមអ្នកស្រាវជ្រាវត្រូវបានកត់បញ្ចូលទៅក្នុងទម្រង់សម្រាប់បំពេញទិន្នន័យសម្ភាស និងថតជាខ្សែអាត់សំឡេង។

ក្នុងពេលប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវគោរពតាមគោការណ៍ក្រមសីកធម៌ស្រាវជ្រាវទាំង៥ចំណុច។ ក្រុមការងារពុំមានការបង្ខិតបង្ខំអ្នកផ្ដល់សម្ភាសទេ ដោយប្រើគោលការណ៍ការស្ម័គ្រចិត្តក្នុងការផ្ដល់សម្ភាសដល់ក្រុមការងារ ហើយក៏ពុំបានបង្ហាញឈ្មោះ អត្តសញ្ញាណ ឬក៏ទិន្នន័យទាំងឡាយណាដែលបានសម្ភាសពីអ្នកផ្ដល់សម្ភាសជាសាធារណៈនោះឡើយ។ មួយវិញទៀត សមាជិករបស់ក្រុមការងារក៏ពុំបានកុហកឬក៏ប្រើល្បិចបោកបញ្ឆោតណាមួយ ដើម្បីបានមតិយោបល់ពីអ្នកផ្ដល់សម្ភាសទេក្នុងនេះផងដែរ ប្រសិនបើអ្នកផ្ដល់សម្ភាសលែងចង់ឱ្យសម្ភាស ក្រុមការងារក៏យល់ស្របតាម។ នៅក្នុង

ដំណើរការនៃការស្រាវជ្រាវនេះ ផលវិបាកដែលក្រុមការងារទទួលបាននោះគឺ ការយល់ដឹងពីគោលការណ៍សាលាជំនាន់ថ្មីរបស់លោកគ្រូអ្នកគ្រូ និងអាណាព្យាបាលនៅមានកម្រិតនៅឡើយ។

## ៣. លទ្ធផលស្រាវជ្រាវ

ក្រោយពីការសិក្សាវិភាគលើសំណាកដែលបានមកពីការសម្ភាស ការស្រាវជ្រាវបង្ហាញថា មានមតិយោបល់ជាច្រើនចំពោះការត្រៀមខ្លួន ដើម្បីប្រែក្លាយសាលាធនធានវិទ្យាល័យខ្វរ ប៊ុនស៊ុន ក្រចេះក្រុងជាសាលារៀនជំនាន់ថ្មី។ ខាងក្រោមជាមតិយោបល់ដែលបញ្ជាក់យ៉ាងលម្អិតចេញពីថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងសាលា ព្រមទាំងអាណាព្យាបាលផ្ទាល់ដើម្បីត្រៀមខ្លួននិងផ្ដល់ការគាំទ្រក្នុងការប្រែក្លាយពីសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី៖

### ក. ទស្សនៈយល់ឃើញរបស់នាយក នាយិកា

យោងតាមការសម្ភាសចេញពីលោកនាយក នាយករងមានប្រសាសន៍ថា លោកគាំទ្រក្នុងការប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី ដោយលោកយល់ថា សាលាជំនាន់ថ្មីអាចលើកកម្ពស់គុណភាពសិក្សារបស់សិស្សឱ្យកាន់តែល្អប្រសើរនិងដើរទាន់សភាពការណ៍ពិភពលោក។ លោកបន្តថា ធនធានដែលសាលាកំពុងមានបច្ចុប្បន្នគឺពុំអាចគាំទ្រដល់ការបង្រៀន តាមគោលនយោបាយសាលារៀនជំនាន់ថ្មីនៅឡើយទេ ពីព្រោះនៅសាលាលោកគ្រប់គ្រងសព្វថ្ងៃនៅខ្វះទាំងធនធានគ្រូបង្រៀននិងសម្ភារៈរូបវន្តជាច្រើនទៀត។ ធនធានគ្រូបង្រៀននៅមានកម្រិត គ្រូកម្រិតទុតិយភូមិមិនគ្រប់ទៅតាមឯកទេស និងកម្រិតថ្នាក់ ហើយគ្រូកម្រិតបឋមភូមិទៅជួយបង្រៀននៅថ្នាក់ទុតិយភូមិ។ ម្យ៉ាងទៀត ពួកគាត់នៅខ្វះការស្រាវជ្រាវបន្ថែម ជាពិសេសគ្រូបង្រៀនមួយចំនួនពុំទាន់មានការវិវត្តផ្នែកបំណិនឌីជីថល និងភាសាអង់គ្លេសនោះទេ។ ចំណែក សម្ភារៈរូបវន្តនៅសាលាសព្វថ្ងៃមិនទាន់បំពេញតម្រូវការការបង្រៀន និងរៀនបានទេ ឧទាហរណ៍ សព្វថ្ងៃក្នុងមួយបន្ទប់មានសិស្ស ៥០ នាក់ទៅ ៦០ នាក់ សិស្សពិបាកធ្វើការងារក្រុម ដោយសារតុវែងពេកពិបាកបំលាស់ទី កុំព្យូទ័រ ស្លាយ (LED projector) សម្ភារៈឧបទេស និងធនធានថវិកាសម្រាប់ទ្រទ្រង់ដំណើរការ។ លើសពីនេះទៅទៀត ពួកគាត់ក៏នៅមានកង្វល់ចំពោះបញ្ហាដែលតម្រូវឱ្យអាណាព្យាបាលផ្ដល់ជាបដិភាគមួយចំនួន សម្រាប់គាំទ្រដំណើរការសិក្សារបស់កូន ដោយសារតែសិស្សមួយចំនួនធំមកពីគ្រួសារដែលមានជីវភាពខ្វះខាត។

ជាចុងក្រោយលោកនាយក និងនាយករងមានការប្ដេជ្ញាចិត្តថា នឹងខិតខំដឹកនាំគ្រប់គ្រងឱ្យដំណើរការបានល្អប្រសើរទាំងការងាររៀន និងបង្រៀន ព្រមទាំងជំរុញសិស្សឱ្យខិតខំវិវត្តខ្លួនដើម្បីទទួលបានលទ្ធផលសិក្សាល្អទាំងអស់គ្នា។

### ខ. ទស្សនៈយល់ឃើញរបស់លោកគ្រូ អ្នកគ្រូ

យោងតាមការសម្ភាស លោកគ្រូ អ្នកគ្រូមួយចំនួនធំមានប្រសាសន៍ថា ពួកគាត់គាំទ្រក្នុងការប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី ដោយយល់ឃើញថា សាលារៀនជំនាន់ថ្មីនឹងអាចលើកកម្ពស់គុណភាពសិក្សារបស់សិស្ស និងគុណភាពបង្រៀនរបស់គ្រូឱ្យកាន់តែល្អប្រសើរ ដើម្បីដើរឱ្យទាន់សភាពការណ៍ពិភពលោក។ ក្នុងន័យនេះ ពួកគាត់បានបញ្ជាក់ច្បាស់ៗថា សាលារៀនជំនាន់ថ្មីនឹងជំរុញឱ្យមានការស្រាវជ្រាវ ការបង្កើតការសិក្សា ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាប្រចាំ មានវិន័យតឹងរឹង មានសម្ភារៈបច្ចេកវិទ្យាទំនើបៗសម្រាប់គាំទ្រដល់ការបង្រៀននិងរៀននៅសតវត្សន៍ទី២១។ លើសពីនេះទៅទៀត ការជ្រើសរើសគ្រូមកបង្រៀននិងសិស្សមករៀននៅសាលារៀនជំនាន់ថ្មី ត្រូវបានឆ្លងកាត់ការដាក់ពាក្យប្រឡង និងសម្ភាសប្រកបដោយភាពសុក្រឹតនិងយុត្តិធម៌ដែលសបញ្ជាក់ឱ្យឃើញថា សាលារៀនបានផ្តល់ឱកាសឱ្យមានការប្រកួតប្រជែងយ៉ាងទូលំទូលាយ។

លោកគ្រូ អ្នកគ្រូ ក៏មានយោបល់ប្រហាក់ប្រហែលទៅនឹងលោកនាយកដែរ ចំពោះធនធានសម្ភារៈរបស់សាលារៀននាពេលបច្ចុប្បន្ន គឺពុំអាចគាំទ្រដល់ការបង្រៀននៅពេលក្លាយជាសាលារៀនជំនាន់ថ្មីនៅឡើយទេ ពីព្រោះសម្ភារៈរូបវន្តនៅសាលាសព្វថ្ងៃ ពុំទាន់បំពេញតម្រូវការការបង្រៀននិងរៀនបានទេ ក៏គាត់បានបង្ហាញក្តីព្រួយបារម្ភអំពីសមត្ថភាពគ្រូបង្រៀនទៅលើការស្រាវជ្រាវនិងការប្រើប្រាស់បច្ចេកទេសទំនើប ក៏ដូចជាការចូលរួមពីឪពុកម្តាយរបស់សិស្សក្នុងការបង់ថ្លៃសិក្សា។

ផ្ទុយទៅវិញ សម្រាប់គ្រូបង្រៀនដែលមានវ័យចំណាស់មួយចំនួនមិនគាំទ្រឱ្យប្រែក្លាយសាលាធនធានទៅជាសាលារៀនជំនាន់ថ្មីនោះទេ ដោយសារពួកគាត់មានសុខភាពមិនរឹងមាំ មិនអាចអភិវឌ្ឍសមត្ថភាពបន្ថែម មិនមានពេលស្រាវជ្រាវនិងមិនមានចំណេះដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យា។ ឯសិស្សវិញត្រូវរៀនច្រើនមិនមានពេលវេលាសម្រាកគ្រប់គ្រាន់ មិនមានពេលស្រាវជ្រាវជាប្រចាំ កិច្ចការសាលាច្រើនមានការប្រកួតប្រជែកខ្លាំង ដែលធ្វើឱ្យសិស្សខ្សោយ មានសម្ពាធ និងចង់បោះបង់ការសិក្សា។ លោកគ្រូអ្នកគ្រូក៏មានយោបល់ស្រដៀងទៅនឹងលោកនាយករងដែរថា សិស្សភាគច្រើនជាសិស្សដែលមកពីតាមបណ្តាលស្រុកដែលមានជីវភាពខ្វះខាតនាំឱ្យមានការលំបាកដល់អាណាព្យាបាលសិស្សទាំងនោះ។

### គ. ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា

គណៈកម្មាការគ្រប់គ្រងសាលាបានមានប្រសាសន៍ថា លោកគាំទ្រឱ្យសាលា ខូវ ប៊ុន ស៊ុន ក្រចេះក្រុង ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដោយសារលោកចង់បានគុណភាពអប់រំល្អ ទាំងការរៀននិងបង្រៀន។ សិស្សទទួលបាននូវសិទ្ធិអប់រំស្មើៗគ្នា វាក៏មានលក្ខណៈល្អប្រសើរ ដោយមានការចូលរួមនិងទទួលខុសត្រូវពីសហគមន៍។ ចំពោះឪពុកម្តាយ ឬអាណាព្យាបាលសិស្សមានទំនាក់ទំនងល្អជាមួយសាលារៀនផងដែរ។

### ឃ. ទស្សនៈយល់ឃើញរបស់អាណាព្យាបាល

ឆ្លងតាមការសម្ភាសអាណាព្យាបាលមួយចំនួនចង់ឱ្យសាលាធនធាន ខូវ ប៊ុនស៊ុន ក្រចេះក្រុង ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី។

អាណាព្យាបាលបានលើកឡើងថា«សាលារៀនជំនាន់ថ្មីនឹងធ្វើឱ្យកូនរបស់ពួកគាត់មានពេលវេលារៀនសូត្រគ្រប់គ្រាន់ ចេះស្រាវជ្រាវ ចេះគិតដោយខ្លួនឯង ចេះស្វ័យសិក្សាបានជិតដល់ រៀនសូត្របានទៀងទាត់ មានការប្រកួតប្រជែងគ្នាទៅវិញទៅមក។ ការបង្រៀនតាមបែបទំនើប បំពាក់ដោយប្រព័ន្ធបច្ចេកវិទ្យាទំនើប»។ អាណាព្យាបាលម្នាក់ទៀតបានមានប្រសាសន៍ថា «កូនរបស់គាត់មិនតម្រូវឱ្យរៀនគួរបន្ថែមរហូតដល់ពេលយប់ទេដែលធ្វើឱ្យគាត់មានការព្រួយបារម្ភជាខ្លាំង» ជាការពិតណាស់ការរៀនគួរបន្ថែមមិនថា ពេលថ្ងៃ ឬពេលយប់ វាអាចបង្កជាអសន្តិសុខ អសុវត្ថិភាព អាណាធិបតេយ្យភាព គ្មានសណ្តាប់ធ្នាប់ ពុំមានសុវត្ថិភាពពេលធ្វើចរាចរណ៍ បង្កឱ្យមានគ្រោះថ្នាក់ផ្សេងៗ បង្កឱកាសឱ្យក្មេងទំនើងបង្កើតភាពចលាចលនិងបណ្តាលឱ្យមានឱកាសសេពគ្រឿងញៀននិងគ្រឿងស្រវឹងជាដើម។

ចំណែកឯការសិក្សាដែលមានពេលវេលាសម្រាកគ្រប់គ្រាន់ មានគ្រូបង្រៀនល្អ និងសិស្សគោរពពេលវេលាបានច្បាស់លាស់ មានការពង្រឹងពេលវេលារៀននិងបង្រៀន មានវិន័យតឹងរឹងធ្វើឱ្យមានគុណភាពក្នុងការបង្រៀននិងរៀន។ សាលារៀនជំនាន់ថ្មីជាសាលាដែលមានបរិស្ថានស្អាត មានសណ្តាប់ធ្នាប់ មានវិន័យ មានអគារសិក្សាស្អាត និងបរិយាកាសរីករាយដែលធ្វើឱ្យការរៀនសូត្ររបស់សិស្សមានមិនភាពធុញទ្រាន់។ ម្យ៉ាងវិញទៀត មានសមធម៌ចំពោះសិស្សដែលមានជីវភាពក្រីក្រ មធ្យមនិងខ្ពស់។ ចំណែកគ្រូបង្រៀនវិញទទួលបានប្រាក់លើកទឹកចិត្តស្មើៗគ្នា ដែលនាំឱ្យគ្រូបង្រៀនមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀនដូចគ្នានិងសិស្សផងដែរ ព្រមទាំងសម្រាលដល់ការចំណាយរបស់ពួកគាត់។

ទន្ទឹមនឹងនេះ ក៏មានឪពុកម្តាយនិងអាណាព្យាបាលមួយចំនួនមិនគាំទ្រឱ្យសាលាធនធាន ខូវ ប៊ុនស៊ុន ក្រចេះក្រុងប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មីនោះទេ ដោយពួកគាត់បានលើកឡើងថា «កូនរបស់គាត់អត់បានរៀនគួរបន្ថែម បណ្តាលឱ្យកូនៗរបស់ពួកគាត់ខ្ជិលរៀននិងស្រាវជ្រាវ ធ្វើឱ្យកូនរបស់គាត់ខ្សោយគ្រូៗមិនយកចិត្តទុកដាក់ក្នុងការបង្រៀនដូចពេលរៀនគួរ» អាណាព្យាបាលខ្លះទៀតបាននិយាយថា «សិស្សមានពេលទំនេរច្រើនលេងទូរស័ព្ទ ដើរលេង អត់ខំប្រឹងរៀន សិស្សមិនសូវឱ្យតម្លៃលើកការសិក្សារៀនសូត្រ»។ ម្យ៉ាងទៀត សាលារដ្ឋត្រូវតម្រូវឱ្យសិស្សបង់បដិភាគដូចសាលាឯកជនដែរ ដែលត្រូវចំណាយថវិកាច្រើនលើការសិក្សារបស់កូនៗ។

## ៤. សេចក្តីសន្និដ្ឋាន

ក្រោយពីក្រុមអ្នកស្រាវជ្រាវធ្វើការវិភាគរួចមក លទ្ធផលស្រាវជ្រាវបានថា មតិមួយចំនួនបានគាំទ្រសាលាធនធានខូវ ប៊ុនស៊ុន ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ដោយសារសាលារៀនជំនាន់ថ្មីផ្តល់ការអប់រំប្រកបដោយគុណភាព ពង្រឹងសមត្ថភាពបង្រៀននិងរៀន មានវិន័យតឹងរឹង មានសន្តិសុខសុវត្ថិភាព កាត់បន្ថយការបង្រៀន និងរៀនឯកជនដែលនាំឱ្យកាត់ការចំណាយរបស់អាណាព្យាបាល។ គ្រូបង្រៀននិងសិស្សមានទំនាក់ទំនងល្អ មានសាមគ្គីភាពល្អក្នុងការសិក្សាស្រាវជ្រាវអ្វីដែលថ្មី បង្កើតថ្មីស្របទៅនឹងបរិបទថ្មី។ ទន្ទឹមនឹងការគាំទ្រក៏មានមតិមួយចំនួនលើកឡើងថា សមត្ថភាពគ្រូបង្រៀននៅមានកម្រិត លទ្ធផលសិក្សាមិនដូចការរំពឹងទុកនោះទេ សិស្សរៀនច្រើនគ្មានពេលសម្រាក មានការប្រកួតប្រជែងខ្លាំងបណ្តាលឱ្យសិស្សខ្សោយនិងមានសម្ពាធរហូតចង់បោះបង់ការសិក្សា។ សរុបមក ឆ្លងតាមការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់អំពីសាលារៀនជំនាន់ថ្មី ដែលជានាស្តង់ដាខ្ពស់នៃអភិបាលកិច្ចល្អដូចជា តម្លាភាព គណនេយ្យភាពនិងការចូលរួមបង្កើតបានជាកម្លាំងទាក់ទាញវិនិយោគថ្មីៗក្នុងវិស័យអប់រំដែលនាំឱ្យគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាណាព្យាបាលសិស្ស ភាគច្រើនមានបំណងឱ្យសាលាខូវ ប៊ុនស៊ុន ទៅជាសាលារៀនជំនាន់ថ្មីក្នុងពេលឆាប់ៗ។

**អនុសាសន៍**

បន្ទាប់ពីបានចុះសិក្សាជ្រាវស្រាវរួចមក ក្រុមអ្នកស្រាវជ្រាវផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីឱ្យសាលាធនធានអាចប្រែក្លាយជាសាលារៀនជំនាន់ថ្មីបាន លុះត្រាតែមានការគាំទ្របន្ថែមផ្នែកធនធានសម្ភារៈ និងធនធានមនុស្ស ដូចខាងក្រោម៖

- ធនធានសម្ភារៈ៖ សាលាត្រូវការអគារសិក្សាបន្ថែម បន្ទប់ប្រកបដោយផាសុកភាព និងមានបំពាក់ដោយបច្ចេកវិទ្យាទំនើប តុដែលអាចបម្លាស់ទីបាន។ល។
- ធនធានមនុស្ស៖ សាលាត្រូវការគណៈគ្រប់គ្រងប្រកបដោយគុណវុឌ្ឍិ លោកគ្រូ អ្នកគ្រូមានវិជ្ជាជីវៈច្បាស់លាស់ ត្រូវចេះបំណិនឌីជីថល និងមានការអភិវឌ្ឍខ្លួនជាប្រចាំ។
- កិច្ចសហប្រតិបត្តិការ៖ បង្កើតជាបណ្តាញសាលាជាមួយសាលារៀនជំនាន់ថ្មីដែលកំពុងមានប្រជាប្រិយភាពដើម្បីអាចរៀនសូត្រពីគ្នាទៅវិញទៅមក។

## សេចក្តីថ្លែងអំណរគុណ

*ក្រុមអ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណនាយកដ្ឋានគោលនយោបាយដែលបានចុះគាំទ្រការបណ្តុះបណ្តាលការស្រាវជ្រាវប្រតិបត្តិ និងបានដឹកនាំសម្របសម្រួលការសរសេរអត្ថបទស្រាវជ្រាវនេះ*

*ឡើង។ ក្រុមស្រាវជ្រាវក៏សូមថ្លែងអំណរគុណធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានគាំទ្រថវិកាលើការស្រាវជ្រាវមួយនេះ។*

## ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៨). គោលនយោបាយស្តីពី សាលាមធ្យមសិក្សាធនធាន. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). គោលនយោបាយស្តីពី សាលារៀនជំនាន់ថ្មី. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦(. គោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា. នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). គោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០. ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

រាជរដ្ឋាភិបាលកម្ពុជា.(២០២១). ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# ការមករៀនមិនទាន់ពេលវេលារបស់សិស្សក្នុងវិទ្យាល័យក្រឡាញ់

ឡាំ សំអាន*[១] ហ៊ី សុផាត[២] ហ៊ាន់ ជីវ៉ា[៣] តន់ អាន់[៤] ឡុច វិន្ទា[៥] ប៉ាន់ ប៊ុនធឿន[៦] គឹក ចាន់រី[៧] សោម ណារុណ[៨] ធន សមន្ទា[៩] ខេង សារដ្ឋ[១០] និង សៅ មន[១១]

*វិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

នៅក្នុងដំណើរការរៀន និងបង្រៀនតាមវិទ្យាល័យនីមួយៗតែងមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។ ក្នុងនោះ វិទ្យាល័យក្រឡាញ់ដែលជាវិទ្យាល័យធនធានមួយក្នុងខេត្តសៀមរាបក៏មានបញ្ហាប្រឈមចម្បងមួយដែរគឺការមករៀនមិនទាន់ពេលវេលារបស់សិស្ស ដែលជាកិច្ចការចាំបាច់មួយធ្វើឱ្យក្រុមការងារស្រាវជ្រាវផ្ដោតនិងត្រូវរកមូលហេតុដើម្បីធ្វើការដោះស្រាយ។ ក្នុងធ្វើការស្រាវជ្រាវលើប្រធានបទមួយនេះ ក្រុមអ្នកស្រាវជ្រាវបានជ្រើសរើសសិស្សចំនួន ១០នាក់ ឪពុកម្ដាយ ឬអាណាព្យាបាលចំនួន ០៤នាក់ និងលោកគ្រូ អ្នកគ្រូចំនួន ០៦នាក់។ ក្រុមអ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរជាបីប្រភេទសម្រាប់សម្ភាសក្រុមគោលដៅទាំងបី។ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា កត្តាដែលពាក់ព័ន្ធជាច្រើនដូចជា កត្តាសិស្សខ្លួនឯង កត្តាឪពុកម្ដាយ កត្តាសាលារៀន ព្រមទាំងកត្តាគួបផ្សំផ្សេងទៀតមាន កត្តាភូមិសាស្ត្រ ផ្ទះនៅឆ្ងាយ ផ្លូវពិបាកធ្វើដំណើរ ខ្វះមធ្យោបាយធ្វើដំណើរដែលជាឧបសគ្គក្នុងការធ្វើឱ្យសិស្សមករៀនមិនទាន់ពេល។ ចំណែក សិស្សខ្លួនឯងផ្ទាល់ ក៏មានភាពខ្ជិលច្រអូស មិនយកចិត្តទុកដាក់ និងមិនឱ្យតម្លៃលើការរៀនសូត្រ។ ចំពោះឪពុកម្ដាយមួយចំនួន ដោយរវល់លើកិច្ចការងារចិញ្ចឹមជីវិត ពួកគាត់ពុំសូវបានជំរុញនិងយកចិត្តទុកដាក់លើការសិក្សារបស់កូននោះទេ។ សម្រាប់កត្តាសាលារៀន

គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនមិនបានដាក់វិន័យឱ្យតឹងរឹងតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាដល់សិស្សដែលមកយឺតជាប្រចាំ និងបណ្តែតបណ្តោយតាមចិត្តរបស់សិស្ស ជាហេតុធ្វើឱ្យបញ្ហានៅតែបន្តកើតឡើង។ ជារួម ក្រុមអ្នកស្រាវជ្រាវស្នើសុំឱ្យគ្រប់ភាគីពាក់ព័ន្ធជួយសហការ និងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទីរបស់ខ្លួន ដើម្បីលុបបំបាត់បញ្ហាដែលកើតឡើងក្នុងវិទ្យាល័យក្រឡាញ់។

**អាគតដ្ឋាន:** ឡាំ, ស., ហ៊ី, ស., & ហ៊ន់. ជ. (២០២២). ការមករៀនមិនទាន់ពេលវេលារបស់សិស្សក្នុងវិទ្យាល័យក្រឡាញ់. *កាលិកបត្រអប់រំកម្ពុជា,* ៥(១),១១-១៩។

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះវិស័យអប់រំនៅកម្ពុជា ពិសេសក្រសួងអប់រំ យុវជន និងកីឡាដែលជាក្រសួងសាមីផ្ទាល់បាននិងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងទិសដៅលើកកម្ពស់គុណភាពអប់រំ និងផ្តល់ឱកាសឱ្យប្រជាជនទូទៅទទួលបានការអប់រំ ប្រកបដោយសមភាពសមធម៌ និងសិទ្ធិទទួលបានការអប់រំស្មើៗគ្នា។ វិស័យអប់រំនៅក្នុងប្រទេសមានការបោះជំហានទៅមុខយ៉ាងខ្លាំង មិនថា គ្រឹះស្ថានរដ្ឋ ឬឯកជននោះទេ កត្តាទាំងនេះហើយដែលធ្វើឱ្យប្រទេសយើងផលិតបាននូវធនធានមនុស្សជាច្រើនប្រកបដោយគុណភាពនិងចំណេះដឹងយ៉ាងពិតប្រាកដ ដើម្បីប្រកួតប្រជែងក្នុងទីផ្សារការងារទាំងក្នុង ក៏ដូចជាក្រៅប្រទេសផងដែរ។ សាលាមធ្យមសិក្សាធនធានក៏បាននឹងកំពុងជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននិងចែករំលែកបទពិសោធក្នុងការបង្រៀននិងរៀន ការងារគ្រប់គ្រង ការណែនាំកសាងអនុវត្តផែនការអភិវឌ្ឍសាលារៀននិងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន តាមរយៈការណែនាំផ្ទាល់និងការអភិវឌ្ឍវិជ្ជាជីវៈ (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៨)។ ទន្ទឹមនឹងភាពជោគជ័យនេះ ក៏មាននូវបញ្ហាប្រឈមមួយចំនួនដែលបានសង្កេតឃើញនៅក្នុងវិស័យអប់រំបច្ចុប្បន្ន។ ក្នុងនោះផងដែរ ការមករៀនមិនទៀងទាត់ពេលវេលារបស់សិស្សជាបញ្ហាចម្បងមួយដែលធ្វើឱ្យការសិក្សារបស់សិស្សានុសិស្សមានលទ្ធផលមិនបានល្អ។ សិស្សានុសិស្សដែលតែងតែមករៀនយឺតពេល ពួកគាត់ភាគច្រើនប្រាកដជាដឹងយ៉ាងច្បាស់នូវគុណវិបត្តិនៃការដែលពួកគាត់តែងតែមករៀនមិនទាន់ម៉ោងនោះ តែពួកគាត់មួយចំនួននៅតែប្រព្រឹត្តនូវទម្លាប់មិនល្អនោះជាប្រចាំដោយមិនមានការខ្វល់ខ្វាយពីលទ្ធផលនិងចំណេះដឹងពិតប្រាកដ ដែលពួកគាត់នឹងទទួលបាននោះទេ។ តាមរយៈបទពិសោធ និងការសង្កេតរបស់ក្រុមអ្នកស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការដែលសិស្សម្នាក់មករៀនយឺតពេលនោះបានជះឥទ្ធិពលអវិជ្ជមានមួយចំនួនដូចជា ការសិក្សារបស់សិស្សទទួលបានលទ្ធផលមិនល្អ ខាតបង់ថវិកាដែលឪពុកម្តាយ ឬអ្នកអាណាព្យាបាលបានផ្គត់ផ្គង់ក្នុងការសិក្សា និងប៉ះពាល់ការសិក្សារបស់មិត្តរួមថ្នាក់ (ពេលដែលគាត់ចូលថ្នាក់យឺតជាងគេ) ប៉ះ

ពាល់ដល់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងរៀនមិនទាន់គេជាដើម។ ដោយអនុលោមតាមសេចក្តីប្រកាសលេខៈ ២៧៨៦ អយក.ប្រក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩ ស្តីពី បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងជំពូក ៤ លក្ខខណ្ឌនៃការសិក្សា ប្រការ ១០ ការចូលរួមសកម្មភាពរបស់គ្រឹះស្ថានសិក្សាបានបញ្ជាក់ថា សិស្សទាំងអស់ត្រូវមករៀនទាន់ពេលវេលា ពិសេស សិស្សដែលត្រូវវេនសំអាតតាមកាលវិភាគកំណត់ ត្រូវមកដល់គ្រឹះស្ថានសិក្សា ៣០នាទី មុនពេលចូលរៀន ដើម្បីសំអាតទីធ្លា បង្គន់អនាម័យ និងបន្ទប់រៀន។ លើសពីនេះទៅទៀត នៅក្នុងជំពូកដដែល ប្រការ ១២ ការសុំច្បាប់ឈប់សម្រាកបានបញ្ជាក់ថា សិស្សដែលមករៀនមិនទាន់ពេលវេលា ឬមករៀនយឺតត្រូវមកសុំការអនុញ្ញាតពីទីចាត់ការ ឬសុំការអនុញ្ញាតពីគ្រូបង្រៀនផ្ទាល់។ រាល់ការឈប់ដែលគ្មានការអនុញ្ញាតត្រូវកំណត់ថា ជាការឈប់អត់ច្បាប់។ ក្នុងករណីសិស្សអវត្តមានច្រើនចូលក្នុងលក្ខខណ្ឌដែលបានកំណត់ សិស្សនឹងត្រូវរៀនត្រួតថ្នាក់។ បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងរៀបចំគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈឱ្យមានរបៀបរៀបរយវិន័យ និងសីលធម៌ល្អក្នុងគោលដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ(ក្រសួងអប់រំ យុវជន និងកីឡា, ២០០៩)។

បើទោះបីជាមានការខិតខំប្រឹងពីគ្រប់ភាគីព័ន្ធជាច្រើនក៏ដោយ ក៏នៅតែមានសិស្សមួយចំនួនមានភាពយឺតយ៉ាវក្នុងការចូលរៀនឱ្យបានពេញលេញក្នុងម៉ោងសិក្សា។ ជាក់ស្តែងនៅវិទ្យាល័យក្រឡាញ់មានសិស្សប្រមាណជា ២០% បានមករៀនមិនទៀងទាត់ និងមិនទាន់ពេលវេលា ដែលនេះជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងលើគុណភាពសិក្សារបស់សិស្សនិងសាលារៀន (វិទ្យាល័យក្រឡាញ់, ២០២២)។

តាមការលើកឡើងខាងលើនេះបានបង្ហាញឱ្យឃើញថា ការមករៀនមិនគោរពម៉ោងសិក្សារបស់សិស្សនៅតែជាបញ្ហាប្រឈមដែលវិទ្យាល័យក្រឡាញ់ត្រូវយកចិត្តទុកដាក់និងរិះរកវិធានការដោះស្រាយបញ្ហាប្រឈមនេះឱ្យបានទាន់ពេលវេលា។ ប៉ុន្តែមុននឹងឈានដល់ដំណោះស្រាយយើងត្រូវដឹងអំពីឫសគល់នៃបញ្ហាដែលធ្វើឱ្យសិស្សនៅវិទ្យាល័យក្រឡាញ់មិនគោរពម៉ោងសិក្សាជាមុនសិន។ តាមការសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយលោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យក្រឡាញ់ក្នុងខេត្តសៀមរាបនេះ មានគោលបំណងធំចំនួនពីរ ទីមួយគឺការសិក្សាពីមូលហេតុដែលធ្វើឱ្យសិស្សមករៀនមិនទាន់ពេលវេលា និងកំណត់កត្តាចម្បងនានាដែលនាំឱ្យសិស្សមករៀនមិនទៀងទាត់ពេលវេលា ទីពីរគឺការដាក់ចេញជាអនុសាសន៍ជួយឱ្យសិស្សមករៀនទៀងទាត់ជាប្រចាំ។

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ដើម្បីរិះរកវិធានការណាដែលសមស្របក្នុងជួយឱ្យសិស្សមករៀនទៀងទាត់និងផ្តល់ជាធាតុចូលសម្រាប់កំណត់នូវវិធីសាស្ត្រទូទៅមួយ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអប់រំនៅវិទ្យាល័យក្រឡាញ់ ព្រមទាំងកសាងឯកសារគោលសម្រាប់ការងារស្រាវជ្រាវបន្តផងដែរ។

ដើម្បីស្វែងរកចម្លើយ ក៏ដូចជាដំណោះស្រាយទៅលើបញ្ហាខាងលើ ក្រុមអ្នកស្រាវជ្រាវបាន លើកឡើងសំណួរស្រាវជ្រាវ និងសំណួរគន្លឹះមួយចំនួនដូចខាងក្រោម៖

**សំណួរស្រាវជ្រាវ៖**

តើមានមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យសិស្សវិទ្យាល័យក្រឡាញ់មករៀនមិនទាន់ពេល?

**សំណួរគន្លឹះ៖**

- តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យសិស្សខ្លួនឯងមករៀនយឺត?
- តើកត្តាគ្រួសារអ្វីខ្លះដែលធ្វើឱ្យសិស្សមករៀនយឺត?
- តើកត្តាសាលារៀនអ្វីខ្លះដែលធ្វើឱ្យសិស្សមករៀនយឺត?

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យកិច្ចការស្រាវជ្រាវមានភាពល្អប្រសើរ ក្រុមអ្នកស្រាវជ្រាវបានធ្វើការសិក្សាជាក់ស្តែងទៅលើអ្នកពាក់ព័ន្ធជាមួយនឹងប្រធានបទដែលបានលើកឡើងខាងលើរួមមាន សិស្ស ឪពុកម្តាយ ឬអាណាព្យាបាលនិងលោកគ្រូ អ្នកគ្រូ ដើម្បីប្រមូលទិន្នន័យឱ្យគ្រប់ជ្រុងជ្រោយទាក់ទងទៅនឹងបញ្ហានៃការមករៀនមិនទាន់ពេលវេលារបស់សិស្ស។ ដោយសារការស្រាវជ្រាវនេះធ្វើឡើងតែសម្រាប់វិទ្យាល័យក្រឡាញ់ ការជ្រើសរើសសំណាកមានទំហំតូចដែលរួមមាន សិស្សសរុប ១០នាក់ ក្នុងនោះសិស្សស្រី ០៧នាក់ ចាប់ពីថ្នាក់ទី៧ ដល់ទី១២ ក្នុងនោះ សិស្សថ្នាក់ទី៧ មានចំនួន ០១នាក់ ថ្នាក់ទី៨ មានចំនួន ០១នាក់ ថ្នាក់ទី៩ មានចំនួន ០១នាក់ ថ្នាក់ទី១០ មានចំនួន ០២នាក់ ថ្នាក់ទី១១ មានចំនួន ០២នាក់ និងថ្នាក់ទី១២ មានចំនួន ០៣នាក់។ ក្រុមការងារបានជ្រើសរើសសិស្សដែលតែងតែមករៀនមិនទាន់ពេលវេលា ដោយផ្អែកតាមព័ត៌មានដែលបានមកពីប្រធានថ្នាក់ លោកគ្រូ អ្នកគ្រូទទួលបន្ទុកថ្នាក់និងលោកគ្រូ អ្នកគ្រូដែលបង្រៀនតាមមុខវិជ្ជានីមួយៗ។ ជាមួយគ្នាផងដែរ អ្នកស្រាវជ្រាវក៏បានជ្រើសរើសអ្នកផ្តល់សម្ភាសសរុប ០៤នាក់ជាឪពុកម្តាយ ឬអាណាព្យាបាលរបស់សិស្សដែលមករៀនយឺតនិងមិនគោរពម៉ោង ក្នុងនោះឪពុកម្តាយ ឬអាណាព្យាបាលសិស្សថ្នាក់ទី១០ មានចំនួន ០១នាក់ ថ្នាក់ទី១១ មានចំនួន០១នាក់ និង ថ្នាក់ទី១២ មានចំនួន ០២នាក់។

ក្រុមអ្នកស្រាវជ្រាវក៏បានធ្វើការជ្រើសរើសលោកគ្រូ អ្នកគ្រូ ចំនួន ០៦នាក់ ស្រីចំនួន០៣នាក់ ដែលជាគ្រូទទួលបន្ទុកថ្នាក់ គ្រូបង្រៀនច្រើនម៉ោង និងជាគ្រូត្រូវបង្រៀនម៉ោងទី១ ពេលព្រឹកនិងពេលរសៀលដើម្បីសម្ភាសផងដែរ។ អ្នកចូលរួមផ្តល់សម្ភាសទាំងអស់គឺបានព្រមព្រៀងនិងអនុញ្ញាតឱ្យក្រុម

អ្នកស្រាវជ្រាវសម្ភាសដោយស្ម័គ្រចិត្តនិងសហការយ៉ាងរលូន ហើយពួកគាត់ក៏បានគាំទ្រប្រធានបទនៃការស្រាវជ្រាវនេះផងដែរ។

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការសម្ភាសជាក្រុមនិងជាបុគ្គល។ ក្រុមអ្នកស្រាវជ្រាវបានធ្វើការណាត់ជួបពួកគាត់ជាមុនដើម្បីត្រៀមខ្លួនសម្ភាស។ សម្រាប់ដំណើរការនៃការប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវបានធ្វើការបែងចែកគ្នាជា៣ក្រុមរួមមាន៖ ក្រុមទី១ សម្ភាសសិស្សនៅពេលព្រឹក ក្នុងបរិវេណវិទ្យាល័យ ក្រុមទី២ ធ្វើការសម្ភាសគ្រូបង្រៀននៅពេលព្រឹកដូចគ្នាជាក្រុមនិងជាបុគ្គលដោយសារតែការសម្ភាសក្នុងក្រុម យើងសង្កេតឃើញថា ការផ្តល់ចម្លើយហាក់ស្រដៀងៗគ្នាពុំសូវមានភាពក្បោះក្បាយ ហើយព័ត៌មានដែលទទួលបានមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ដូច្នេះហើយទើបក្រុមអ្នកស្រាវជ្រាវសម្រេចសម្ភាសគ្រូ០៣នាក់ផ្សេងទៀតជាបុគ្គល។ សម្រាប់ក្រុមទី៣គឺសម្ភាសឪពុកម្តាយ ឬអាណាព្យាបាលតាមរយៈទូរស័ព្ទដែលប្រព្រឹត្តទៅនៅពេលព្រឹក និងរសៀលផងដែរដោយហេតុថា ផ្ទះអាណាព្យាបាលនៅឆ្ងាយព្រមទាំងប្រឈមនឹងបញ្ហាជម្ងឺកូវីដ-១៩។ ម្យ៉ាងវិញទៀត ក្រុមអ្នកស្រាវជ្រាវគិតថា ការសម្ភាសតាមទូរស័ព្ទធ្វើឱ្យឪពុកម្តាយ ឬអាណាព្យាបាលពុំសូវមានភាពអៀនខ្មាស់ក្នុងការផ្តល់ទិន្នន័យ។ រាល់ការសម្ភាសពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្រុមអ្នកស្រាវជ្រាវបានធ្វើការកត់ត្រានូវព័ត៌មានសំខាន់ៗចេញពីសំណួរនីមួយៗមុននឹងធ្វើការវិភាគ។

ដើម្បីឱ្យមានភាពងាយស្រួលនិងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ «តើមានមូលហេតុអ្វីខ្លះធ្វើឱ្យសិស្សមករៀនមិនទាន់ពេលវេលានៅវិទ្យាល័យក្រឡាញ់?» ការវិភាគទិន្នន័យបានឆ្លងកាត់ជំហានជាច្រើនដូចជា ក្រុមអ្នកស្រាវជ្រាវបានប្រើប្រាស់តារាងក្នុងទម្រង់គំរូដើម្បីបំពេញព័ត៌មានតាមលំដាប់លំដោយនៃអ្នកចូលរួមនីមួយៗ ដោយស្វែងរកនិងកត់ត្រាគំនិតសំខាន់ៗ រួចធ្វើចំណាត់ថ្នាក់ក្រុមនៃគំនិតសំខាន់ៗទាំងនោះដាក់ក្នុងតារាងតាមលេខរៀងនៃអ្នកចូលរួមម្តងមួយៗ ដោយយកចិត្តទុកដាក់។

នៅក្នុងដំណើរការនៃការស្រាវជ្រាវ ក្រុមអ្នកស្រាវជ្រាវបានប្រកាន់ខ្ជាប់នូវក្រមសីលធម៌នៃអ្នកស្រាវជ្រាវ ដើម្បីធានាឱ្យលទ្ធផលស្រាវជ្រាវបានល្អប្រសើរនិងឆ្លុះបញ្ចាំងពីការពិតដាក់ស្តែងលើបញ្ហានៃការស្រាវជ្រាវ។

## ៣. លទ្ធផល និងការពិភាក្សា

ផ្អែកតាមការវិភាគទិន្នន័យដែលបានមកពីការសម្ភាសចេញពីអ្នកចូលរួមទាំងអស់ ក្រុមអ្នកស្រាវជ្រាវបានរកឃើញលទ្ធផលដូចខាងក្រោម៖

### ៣.១ លទ្ធផលដែលបានពីការសម្ភាសសិស្ស

ដោយផ្អែកលើការសម្ភាសសិស្សដែលមករៀនយឺតចំនួន១០នាក់ ក្រុមអ្នកស្រាវជ្រាវបានរកឃើញកត្តាមួយចំនួនដែលជាមូលហេតុនាំឱ្យសិស្សមកសិក្សាមិនទាន់ពេលវេលាដូចជា កត្តាគ្រួសារ ដោយហេតុថា សិស្សភាគច្រើនភ្ញាក់ពីព្រលឹមដើម្បីជួយធ្វើកិច្ចការផ្ទះឪពុកម្ដាយដូចជា បើកតូបលក់បាយ បោសផ្ទះ លាងចាន ដាំបាយ ធ្វើម្ហូបនិងជួយដឹកគោទៅចង។ ត្រង់ចំណុចនេះបានបង្ហាញថា ឪពុកម្ដាយហាក់ដូចជាមិនផ្ដល់អាទិភាពលើការសិក្សារបស់កូន។

កត្តាសិស្សខ្លួនឯងក៏ជាផ្នែកមួយដែលនាំឱ្យពួកគេមកសិក្សាយឺតយ៉ាវផងដែរ ដោយសិស្សខ្លះចូលគេងយប់ជ្រៅដោយជាប់រវល់មើលមេរៀន ឯសិស្សខ្លះទៀតមើលរឿងនិងលេងហ្គេមក្នុងទូរស័ព្ទ។ សិស្សចំនួនទៀតលេងកីឡាពីល្ងាច អស់កម្លាំងខ្លាំងដែលជាហេតុបណ្ដាលឱ្យពួកគេក្រោកពីដំណេកយឺត។ ម្យ៉ាងទៀត សិស្សខ្លួនឯងផ្ទាល់ហាក់ដូចជាមិនសូវចេះគ្រប់គ្រងពេលវេលានិងផ្ដល់តម្លៃលើការសិក្សារបស់ខ្លួន។

ចំណែកហេដ្ឋារចនាសម្ព័ន្ធដែលពុំសូវផ្ដល់ភាពងាយស្រួលដល់សិស្ស ក៏រួមចំណែកធ្វើឱ្យសិស្សជួបប្រទះការលំបាកផងដែរដូចជា ស្ថានភាពភូមិសាស្ត្រសាលារៀននៅឆ្ងាយពីផ្ទះរបស់សិស្សដែលមានចម្ងាយប្រហែល២០គីឡូម៉ែត្រនិងផ្លូវភាគច្រើនជាផ្លូវលំមានសភាពទ្រុឌទ្រោមនិងផ្លូវដីក្រហមមានជង្ហុកច្រើនជាដើម។

ចំពោះកត្តាសាលារៀនវិញ ទោះបីជាការមករៀនរបស់សិស្សមានភាពយឺតយ៉ាវ និងមិនទាន់ពេលវេលាយ៉ាងណាក៏ដោយ ក៏លោកគ្រូ អ្នកគ្រូមិនបានដាក់ពិន័យចំពោះសិស្សនោះទេ ហើយករណីខ្លះទៀតសិស្សមួយចំនួនទទួលបានត្រឹមតែការណែនាំឱ្យមករៀនបានទៀងទាត់និងទាន់ពេលវេលាតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ទើបសិស្សភាគច្រើនមិនស្ដាប់តាមការណែនាំរបស់លោកគ្រូ អ្នកគ្រូដែលជាហេតុបណ្ដាលឱ្យពួកគេមករៀនយឺតនិងមិនគោរពម៉ោងសិក្សារបស់ខ្លួនដដែល។ ចំណុចទាំងអស់ខាងលើបានបញ្ជាក់ឱ្យឃើញថា លោកគ្រូ អ្នកគ្រូហាក់ដូចជាមានភាពធកល្វែងលើការអនុវត្តវិន័យដល់សិស្សនិងពុំសូវយកចិត្តទុកដាក់ចំពោះសិស្សដែលមករៀនមិនទាន់ពេលវេលា។

### ៣.២ លទ្ធផលដែលបានពីការសម្ភាសអាណាព្យាបាល

ក្រោយពីជួបសម្ភាសជាមួយឪពុកម្ដាយនិងអាណាព្យាបាលក្រុមអ្នកស្រាវជ្រាវបានរកឃើញមូលហេតុជាច្រើនដែលជាកត្តានាំឱ្យសិស្សមករៀនយឺតនិងមិនគោរពម៉ោងសិក្សាដូចជា សិស្សខ្លួនឯងផ្ទាល់មានភាពខ្ជិលច្រអូសនិងក្រោកពីដំណេកយឺត។ សិស្សមួយចំនួនរវល់នឹងការងារផ្ទះដូចជា ជួយបើកតូបលក់ដូរពេលព្រឹក បោសសំអាតផ្ទះ ដាំបាយ ដាំទឹកនិងជួយមើលថែទាំជីដូនចាស់ជរាជាដើម។ សិស្សខ្លះទៀតមានផ្ទះនៅឆ្ងាយពីសាលារៀនរហូតដល់ទៅជាង ១០ គីឡូម៉ែត្រនិងផ្លូវមានស្ថានភាពលំបាកដែលជាហេតុនាំឱ្យពិបាកក្នុងការធ្វើដំណើរមកសាលារៀនឱ្យទាន់ពេលវេលា។ លទ្ធផលទាំងនេះបាន

បង្ហាញពីភាពស្រដៀងគ្នាជាមួយនឹងលទ្ធផលដែលបានមកពីសិស្សទាក់ទងទៅនឹងភាពធកល្វែងរបស់អាណាព្យាបាលចំពោះការយកចិត្តទុកដាក់លើការសិក្សារបស់កូន ការមិនចេះគ្រប់គ្រងពេលវេលានិងការមិនផ្តល់តម្លៃចំពោះការសិក្សារបស់សិស្សខ្លួនឯងផ្ទាល់ ភាពធកល្វែងរបស់លោកគ្រូ អ្នកគ្រូលើការអនុវត្តវិន័យចំពោះសិស្សនិងខ្វះការយកចិត្តលើសិស្សដែលមករៀនយឺត ក៏ដូចជាកង្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជាដើមដែលជាហេតុនាំឱ្យសិស្សមករៀនមិនទាន់ពេលវេលា។

### ៣.៣ លទ្ធផលដែលបានពីការសម្ភាសគ្រូបង្រៀន

យោងតាមកិច្ចសម្ភាសលោកគ្រូ អ្នកគ្រូនៅវិទ្យាល័យក្រឡាញ់ បញ្ហាភូមិសាស្ត្រ ស្ថានភាពគ្រួសារនិងសិស្សខ្លួនឯងគឺជាហេតុដែលធ្វើឱ្យការមករៀនមិនទាន់ពេលវេលា។ លោកគ្រូ អ្នកគ្រូបានបញ្ជាក់ថាពួកគាត់បានដឹងនិងតាមដានសិស្សមករៀនយឺតតាមរយៈការសាកសួរព័ត៌មានពីប្រធានថ្នាក់ គ្រូបន្ទុកថ្នាក់និងគ្រូតាមមុខវិជ្ជា ក៏ដូចជាសាកសួរសាម៉ីខ្លួនផ្ទាល់។ លើសពីនេះទៀត លោកគ្រូ អ្នកគ្រូក៏បានធ្វើការសង្កេតដោយផ្ទាល់នៅពេលកំពុងបង្រៀនបានបញ្ជាក់ថា សិស្សដែលមករៀនយឺតភាគច្រើនគឺតែងចូលរៀនក្រោយគ្រូចាប់ពី១៥នាទីឡើងទៅស្ទើរតែរាល់ថ្ងៃ។ នៅពេលលោកគ្រូ អ្នកគ្រូបានដឹងពីមូលហេតុទាំងនេះហើយ ពួកគាត់បានព្យាយាមប្រាប់ដំណឹងនេះទៅដល់ឪពុកម្តាយ ឬអាណាព្យាបាលសិស្សដោយផ្ទាល់និងតាមលិខិតអញ្ជើញ ដើម្បីកែប្រែបញ្ហាទាំងនោះឱ្យមានភាពល្អប្រសើរឡើង។ ក្រោយពីទទួលបានការណែនាំពីលោកគ្រូ អ្នកគ្រូហើយ ពួកគាត់សន្យាថានឹងគោរពបទបញ្ជាផ្ទៃក្នុងសាលានិងមករៀនឱ្យបានទាន់ពេលវេលាដូចសិស្សដទៃទៀត ប៉ុន្តែសិស្សមួយចំនួនហាក់ដូចជាពុំទាន់បានអនុវត្តតាមការណែនាំនិងបទបញ្ជាផ្ទៃក្នុងសាលាឱ្យបានត្រឹមត្រូវនោះទេ។

ជារួមមានហេតុផលជាច្រើនដែលបណ្តាលឱ្យសិស្សនៅក្នុងវិទ្យាល័យក្រឡាញ់មករៀនយឺតដូចជាសិស្សខ្លួនឯងមិនចេះគ្រប់គ្រងពេលវេលានិងមិនយកចិត្តទុកដាក់ផ្តល់តម្លៃលើការសិក្សា។ ចំណែកផ្លូវដែលសិស្សត្រូវធ្វើដំណើរទៅសាលារៀនមានចម្ងាយឆ្ងាយ មានសភាពទ្រុឌទ្រោមនិងមានជង្ហុកច្រើនពិបាកក្នុងការធ្វើដំណើរ។ ម្យ៉ាងវិញទៀត ក្រុមគ្រួសារមិនបានផ្តោតការយកចិត្តទុកដាក់លើម៉ោងសិក្សារបស់កូនដោយប្រើកូនឱ្យធ្វើការងារផ្សេងៗក្នុងថ្ងៃសិក្សា។ គ្រូបង្រៀនក៏ចូលរួមចំណែកផងដែរចំពោះការមករៀនមិនទាន់ពេលវេលារបស់សិស្សតាមរយៈការបន្ធូរបន្ថយ ការលើកលែង និងមិនបានអនុវត្តវិន័យតឹងរ៉ឹងចំពោះសិស្សដែលមករៀនយឺតឱ្យបានត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់សាលា។

## ៤. ចំណុចខ្លាំង និងចំណុចខ្សោយ

ឆ្លងតាមការសិក្សាស្រាវជ្រាវប្រតិបត្តិលើប្រធានបទ «ការមករៀនមិនទាន់ពេលវេលារបស់សិស្សនៅវិទ្យាល័យក្រឡាញ់» ក្រុមអ្នកស្រាវជ្រាវបានអនុវត្តការងារដោយធ្វើការជាមួយអ្នកពាក់ព័ន្ធទៅលើ

កត្តាផ្សេងៗដូចជា សិស្សខ្លួនឯងផ្ទាល់ លោកគ្រូ អ្នកគ្រូនិងឪពុកម្តាយ ឬអាណាព្យាបាល។ ក្រុមអ្នកស្រាវជ្រាវបានបែងចែកក្រុមដើម្បីជួបសម្ភាសនិងសាកសួរអំពីមូលហេតុដែលនាំឱ្យសិស្សមករៀនយឺតពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដោយទទួលបានលទ្ធផលដូចការរំពឹងទុក។ ម្យ៉ាងវិញទៀត ក្នុងការសម្ភាសពួកគាត់បានផ្តល់ចម្លើយឱ្យក្រុមអ្នកស្រាវជ្រាវទៅតាមអ្វីដែលពួកគាត់បានដឹងនិងសហការយ៉ាងល្អ។

ទន្ទឹមនឹងនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា មានការលំបាកទាក់ទងទៅនឹងការស្វែងរកឯកសារយោងដើម្បីគាំទ្រអត្ថបទស្រាវជ្រាវនិងមានភាពធកល្វែងខ្លះៗក្នុងការសរសេររបាយការណ៍ស្រាវជ្រាវប្រតិបត្តិ។ បញ្ហាមួយទៀតគឺពិបាកក្នុងការទាក់ទងជាមួយឪពុកម្តាយ ឬអាណាព្យាបាលសិស្សដោយផ្ទះរបស់ពួកគាត់នៅឆ្ងាយពីសាលារៀននិងខ្វះមធ្យោបាយទាក់ទង។ ទោះជាយ៉ាងនេះក៏ដោយក៏ក្រុមអ្នកស្រាវជ្រាវខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីអភិវឌ្ឍការស្រាវជ្រាវឱ្យទទួលបានលទ្ធផលល្អដូចការរំពឹងទុក។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ផ្អែកលើលទ្ធផលស្រាវជ្រាវបង្ហាញថា មានមូលហេតុជាច្រើន ដែលបណ្តាលឱ្យសិស្សមករៀនមិនទាន់ពេលវេលាមានដូចជា កត្តាសិស្សខ្លួនឯងជាចម្បងគឺសិស្សមិនចេះគ្រប់គ្រងពេលវេលានិងមិនយកចិត្តទុកដាក់ផ្តល់តម្លៃលើការសិក្សា។ លើសពីនេះ មានកត្តាផ្សេងទៀតរួមមានគ្រួសារមិនបានផ្តោតការយកចិត្តទុកដាក់លើការសិក្សារបស់កូន សាលារៀនមិនបានអនុវត្តវិន័យតឹងរ៉ឹងចំពោះសិស្សដែលមករៀនយឺតនិងផ្លូវទៅសាលារៀនមានចម្ងាយឆ្ងាយនិងមានជង្ហុកច្រើនពិបាកក្នុងការធ្វើដំណើរ។

**អនុសាសន៍**

ដើម្បីពង្រឹងវិន័យសិស្សក្នុងការគោរពម៉ោងសិក្សាឱ្យបានទៀងទាត់និងទាន់ពេលវេលានៅវិទ្យាល័យក្រឡាញ់ ក្រុមអ្នកស្រាវជ្រាវផ្តល់អនុសាសន៍ដូចខាងក្រោម៖

សិស្សគួរផ្តល់អាទិភាពនិងឱ្យតម្លៃលើការសិក្សា ដោយគោរពវិន័យនិងបទបញ្ជាផ្ទៃក្នុងសាលាឱ្យបានខ្ជាប់ខ្ជួន។ បន្ថែមពីនេះ សិស្សត្រូវពង្រឹងនិងរៀបចំពេលវេលាសិក្សាឱ្យបានត្រឹមត្រូវដើម្បីឱ្យដឹងច្បាស់ពីការងារដែលត្រូវធ្វើជាប្រចាំថ្ងៃ។

ចំពោះឪពុកម្តាយ ឬអាណាព្យាបាលត្រូវចូលរួមចំណែកក្នុងការជួយជំរុញកូនឱ្យមករៀនទៀងទាត់និងទាន់ពេលវេលា កាត់បន្ថយការងារប្រចាំថ្ងៃដែលពាក់ព័ន្ធក្នុងថ្ងៃសិក្សារបស់កូន ផ្តល់តម្លៃនិងផ្តល់អាទិភាពដល់ការសិក្សារៀនសូត្ររបស់កូនដោយការដាស់តឿន ក្រើនរំលឹក និងតាមដានជាប្រចាំ។

ចំពោះគណៈគ្រប់គ្រង ព្រមទាំងលោកគ្រូអ្នកគ្រូត្រូវពង្រឹងវិន័យដល់សិស្សឱ្យបានហ្មត់ចត់ តាមបទបញ្ជាផ្ទៃក្នុងរបស់សាលាដែលមានស្រាប់និងបន្តបង្កើតទំនាក់ទំនងល្អជាមួយឪពុកម្តាយ ឬអាណា

ព្យាបាលសិស្សក្នុងការតាមដាន និងផ្តល់ដំណឹងពីការសិក្សារបស់កូននិងពិចារណាលើការរៀបចំអន្តេវាសិកដ្ឋានដល់សិស្សដែលមានផ្ទះនៅឆ្ងាយពីសាលារៀន ហើយផ្លូវពិបាកក្នុងការធ្វើដំណើរជាពិសេសសិស្សស្រី។ លើសពីនេះទៀត សាលារៀនគួរផ្តល់ព័ត៌មានឱ្យច្បាស់លាស់អំពីកាលវិភាគសិក្សាដល់ឪពុកម្តាយ ឬអាណាព្យាបាលសិស្សដើម្បីងាយស្រួលដល់ពួកគាត់ដឹងនិងតាមដានម៉ោងសិក្សាកូនឱ្យបានច្បាស់លាស់។ លោកគ្រូ អ្នកគ្រូក៏គួរចូលរួមចំណែកជំរុញលើកទឹកចិត្តពន្យល់ ណែនាំពីអត្ថប្រយោជន៍នៃការសិក្សាទៅដល់សិស្សគ្រប់ៗគ្នា ក៏ដូចជាបង្ហាត់បង្ហាញពីរបៀបនៃការបែងចែកនិងគ្រប់គ្រងពេលវេលាដែលជាចំណែករួមមួយធ្វើឱ្យសិស្សបង្វែរចំណាប់អារម្មណ៍មកលើការសិក្សាកាន់តែប្រសើរ។

សហគមន៍គួរចូលរួមចំណែកឱ្យបានសស្រាក់សស្រាំក្នុងការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អប្រសើរ និងចូលរួមសហការដោះស្រាយបញ្ហាផ្សេងៗដែលបានកើតមានឡើងចំពោះសិស្សនៅក្នុងសហគមន៍របស់ខ្លួន។


### សេចក្តីថ្លែងអំណរគុណ

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារនៃនាយកដ្ឋានគោលនយោបាយ ដែលបានចុះគាំទ្រការបណ្តុះបណ្តាលការស្រាវជ្រាវប្រតិបត្តិ និងដឹកនាំសម្របសម្រួលក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ ដល់ក្រុមការងារស្រាវជ្រាវយើងខ្ញុំ។ ក៏សូមថ្លែងអំណរគុណផងដែរ ចំពោះគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ (USESDP-ADB) ដែលបានឧបត្ថមថវិការលើការស្រាវជ្រាវមួយនេះ។*


## ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា .(២០០៨). គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន https://www.moeys.gov.kh/index.php/kh/policies-and-strategies/.934html#.YjsuoudBy5c, Assessed on 12 March 2022

ក្រសួងអប់រំ យុវជន និងកីឡា .(២០០៩). ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈhttps://drive.google.com/file/d/1Sd4FZn89Qu3aeFeLY3VxUuY-zX1BJcQv/view, Assessed on 12March 2022

វិទ្យាល័យក្រឡាញ់.(២០២២).សៀវភៅសម្រង់អវត្តមានសិស្ស។

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

## មូលហេតុអ្វីសិស្សមួយចំនួនមិនសូវចេះអានអក្សរនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ខេត្តកំពង់ធំ

អែម អៀងស៊ន[១] នាគ រ៉ាសុក្រី[២] សុក សុរិដ្ឋា[៣] ប៉ាង រ៉ាប៉ូលី[៤] មាស សុគឿន[៥] ទូច ធូ[៦] អ៊ឹម យ៉ុនណារ៉ា[៧] ភ្លូ គឹមសាន[៨] វត កុល[៩] អ៊ិត គឹមស្រ៊ុន[១០] និង កែ ដារិទ្ធ[១១]

វិទ្យាល័យហ៊ុន សែន បល្ល័ង្ក

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

ចាប់ពីឆ្នាំ ២០១៨ រហូតដល់ឆ្នាំ ២០២១ ទិន្នន័យនៃការសិក្សាតាមរយៈការចូលអានសៀវភៅនៅក្នុងបណ្ណាល័យត្រូវបានធ្លាក់ចុះជាបន្តបន្ទាប់ពីកម្រិត ៨៣.២៨% មកនៅត្រឹមតែ ៤១.៦៤%។ ផ្អែកតាមការសង្កេតនៅតាមថ្នាក់រៀនបង្ហាញថា សិស្សានុសិស្សភាគច្រើនមិនអាចអានអក្សរតាមអក្ខរាវិរុទ្ធ និងឃ្លាឃ្លោងបានត្រឹមត្រូវនៅឡើយ។ ហេតុនេះ ក្រុមអ្នកស្រាវជ្រាវបានកំណត់យកបញ្ហានេះមកធ្វើជាប្រធានបទ។ ការសិក្សានេះ មានគោលបំណងស្វែងរកមូលហេតុដែលធ្វើឱ្យសិស្សមួយចំនួនមិនសូវចេះអានអក្សរ៖ ករណីសិក្សាវិទ្យាល័យ ហ៊ុន សែនបល្ល័ង្គ ខេត្តកំពង់ធំ។

វិធីសាស្ត្រស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់កម្រងសំណួរនិងការសម្ភាសដែលមានអ្នកចូលរួមសរុបចំនួន១៥នាក់ក្នុងនោះ មាននាយកសាលា០១នាក់ លោកគ្រូ អ្នកគ្រូ០២នាក់ អ្នកអាណាព្យាបាល ០២នាក់និងសិស្សានុសិស្ស១០នាក់។ ទិន្នន័យដែលទទួលបានពីការសម្ភាសបានកំណត់ទៅតាមក្រុមនៃថ្នាក់ពាក្យ។ តាមលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា មានកត្តាចំនួន ៣ ដែលធ្វើឱ្យសិស្សមិនសូវ

ចូលចិត្តអានអក្សរគឺកត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។ យោងតាមលទ្ធផលខាងលើនេះ សាលារៀនគួរតែរៀបចំព្រឹត្តិការណ៍ ឬសកម្មភាពដើម្បីជំរុញសិស្សានុសិស្សឱ្យយកចិត្តទុកដាក់និងយល់ពីសារៈសំខាន់នៃការអានសៀវភៅ។ ឪពុកម្ដាយសិស្ស ឬអ្នកអាណាព្យាបាលគួរប្រើពេលវេលាជាមួយកូនៗ និងផ្តល់ថវិកាទ្រទ្រង់លើការទិញសៀវភៅសិក្សាបន្ថែមសម្រាប់កូនៗរបស់គាត់ ព្រមទាំងរៀបចំកន្លែងអង្គុយរៀននិងបង្កើតបណ្ណាល័យតាមផ្ទះឱ្យបានសមរម្យ។

ជារួម កត្តាដែលធ្វើឱ្យសិស្សមិនសូវចេះអានអក្សរមាន កត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។ ដូច្នេះអ្នកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាខាងលើនេះដើម្បីទាក់ទាញនិងលើកទឹកចិត្តសិស្សឱ្យមកចាប់អារម្មណ៍ទៅលើការអានសៀវភៅវិញ។

**អាគតដ្ឋាន:** អែម, អ., នាគ, វ., &សុក, ស.,(២០២២). មូលហេតុអ្វីសិស្សមួយចំនួនមិនសូវចេះអានអក្សរនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ខេត្តកំពង់ធំ . *កាលិកបត្រអប់រំកម្ពុជា,* ៥(១),២០-២៨។

## ១.សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជាមិនថា តំបន់ណា ឬសាលារៀនណាឡើយ សិស្សមិនសូវចូលចិត្តអានសៀវភៅនៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បំផុត។ ការអភិវឌ្ឍប្រទេសជាតិមួយឱ្យរីកចម្រើនគឺត្រូវផ្តើមចេញពីការអភិវឌ្ឍធនធានមនុស្សជាចម្បង។ ការបណ្តុះបណ្តាលមនុស្សឱ្យក្លាយជាពលរដ្ឋល្អទៅបានគឺផ្តើមចេញពីការអានសៀវភៅដែលជាឃ្លាំងនៃប្រាជ្ញា។ អ្នកប្រាជ្ញជាច្រើនបានចងក្រងនូវឯកសារដើម្បីទុកណែនាំដល់មនុស្សជំនាន់ក្រោយក្នុងការបណ្តុះសតិបញ្ញា ស្មារតី ឱ្យកាន់តែភ្លឺថ្លាជាពណ្ណរាយថ្កុំថ្កើងជាងមុនជាដរាប។ ការអានច្រើនអាចធ្វើឱ្យមនុស្សទាំងឡាយនៅក្នុងសង្គមមិនថា ចាស់ ឬក្មេង អាចមានឱកាសទទួលបាននូវគំនិតល្អៗជាច្រើន សម្រាប់យកមកធ្វើជាការពិចារណា ហើយទាញយកមកប្រើប្រាស់ជាប្រយោជន៍ដល់ការសិក្សា ក៏ដូចជាការរស់នៅរបស់យើងទាំងអស់គ្នា ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឆ្ពោះទៅរកសេចក្តីចម្រើន។ ដូច្នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (២០១៥) បានអនុម័តអនុក្រឹត្យរៀបចំទិវាជាតិអំណានដែលប្រព្រឹត្តទៅរៀងរាល់ខែមីនាដើម្បីលើកកម្ពស់ទម្លាប់នៃការអាននិងការចូលចិត្តអាន (រដ្ឋាភិបាលកម្ពុជា, ២០១៥)។ កន្លងមកនេះ យោងតាមការផ្សាយលើគេហទំព័រ (សារព័ត៌មានថ្មីៗ, ២០២២) ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំទិវាជាតិអំណានចំនួន៧លើក។ ក្នុងនោះ ទិវាជាតិអំណានឆ្នាំ២០២២ ប្រារព្ធឡើងក្រោមប្រធានបទស្តីពី «អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល» ក្នុងគោលបំណងបណ្តុះទម្លាប់អាន ជំរុញ

វប្បធម៌អាន លើកកម្ពស់សមត្ថភាពនៃការអាន ស្នូត កំណាព្យ និងការតែងនិពន្ធជាដើម។ ដើម្បីត្រៀមខ្លួនក្នុងការវាយតម្លៃសមត្ថភាពអំណានរបស់សិស្សដែលមានអាយុចាប់ពី១៥ឆ្នាំ នាយកដ្ឋានធានាគុណភាពអប់រំនៃក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំឯកសារជំនួយស្មារតីស្តីពី «សំណួរតេស្តគំរូនៃកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្រាប់ប្រទេសកំពុងអភិវឌ្ឍ»។

បន្ថែមពីនេះទៀត ដើម្បីរួមចំណែកក្នុងការផ្លាស់ប្តូរទម្លាប់នេះ យុវជនដែលមានចំណូលចិត្តក្នុងការអាននៅប្រទេសកម្ពុជាបាននិពន្ធសៀវភៅដែលមានចំណងជើងថា «អំណានជាអំណាច (លីម, អំណានជាអំណាច, ២០១៩)»។ នៅក្នុងសំណេរបកស្រាយអំពីការអាន លោកលីមបានបង្ហាញអំពីទស្សនៈនៃការជំរុញលើកទឹកចិត្តនិងវិធីសាស្ត្រឬបច្ចេកទេសនៃការអាន ដើម្បីទទួលបានចំណេះដឹង។ ក្នុងនោះដែរ នៅក្នុងទិវាជាតិអំណានលើកទី២ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បានបោះពុម្ពស្នាដៃជាច្រើន ដែលសមិទ្ធផលទាំងនោះជាការរួមចំណែកក្នុងការលើកកម្ពស់នូវការអាន ការតែងនិពន្ធ ក៏ដូចជាផ្តល់ចំណេះដឹងទូទៅទាំងផ្នែកសេដ្ឋកិច្ច ទស្សនវិជ្ជា និងចិត្តវិទ្យាផងដែរ។ ស្នាដៃចុងក្រោយរបស់លោកបានសរសេរអំពី «ទ្រឹស្តីអភិវឌ្ឍភាសា និងទ្រឹស្តីអភិវឌ្ឍកុមារ» (ណារ៉ុន, ២០២២)។ យោងតាម ដោ នីដា បានប្រែសម្រួលសៀវភៅដែលមានឈ្មោះថា «ពេលព្រឹកដ៏អស្ចារ្យ» បានលើកឡើងថា «ការអានគឺដើម្បីខួរក្បាល ការហាត់ប្រាណគឺដើម្បីរូបកាយ ការសូត្រធម៌ឬបួងសួងគឺដើម្បីដួងវិញ្ញាណ។ យើងនឹងក្លាយដូចជាសៀវភៅដែលយើងអាន។ មួយវិញទៀត មនុស្សដែលចេះអក្សរតែមិនព្រមអាន ពុំមានលក្ខណៈសម្បត្តិគ្រង់ណាដែលប្រសើរជាងអ្នកដែលមិនចេះអក្សរឡើយ»។ នៅក្នុងទ្រឹស្តីខាងលើនេះបានបង្ហាញថា ការអានគឺជាវិធីសាស្ត្រលឿនបំផុតដើម្បីផ្លាស់ប្តូរផ្នែកណាមួយនៃជីវិតឬជាវិធីសាស្ត្រដើម្បីទទួលចំណេះដឹង គំនិត និងយុទ្ធសាស្ត្រដែលអ្នកត្រូវការឈានទៅរកភាពជោគជ័យនៅក្នុងជីវិត (នីដា, 2020)។

ដូច្នេះ សិស្សានុសិស្សទាំងអស់គប្បីប្រឹងប្រែងព្យាយាមជ្រើសរើសយកសៀវភៅល្អៗមកអានដើម្បីបណ្តុះប្រាជ្ញា ការគិត និងការវិភាគដើម្បីក្លាយជាមូលធនមនុស្សដែលមានសក្តានុពលនៅក្នុងសង្គម។ ផ្ទុយទៅវិញ បច្ចុប្បន្ននេះបច្ចេកវិទ្យាកាន់តែទំនើប សម្ភារៈប្រើប្រាស់កាន់តែសម្បូរបែបស្របពេលជាមួយនឹងបរិបទនៃជំងឺកូវីដ-១៩ ដែលជាបញ្ហាសកលផងនោះបានធ្វើឱ្យមនុស្សមួយចំនួនជាពិសេសសិស្សានុសិស្សមិនសូវចេះអានអក្សរទៅវិញ។ ទាំងនេះជាបញ្ហាមួយគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងដែលទាមទារឱ្យរាជរដ្ឋាភិបាល ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា រួមទាំងលោកគ្រូ អ្នកគ្រូ និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលត្រូវយកចិត្តទុកដាក់និងសហការគ្នាយ៉ាងសកម្មក្នុងការងារអប់រំមួយនេះ។

ដោយឡែក ប្រសិនបើយើងក្រឡេកមកមើលសិស្សានុសិស្សមួយចំនួនតូចនៃវិទ្យាល័យ ហ៊ុន សែន បល្ល័ង្កខេត្តកំពង់ធំវិញ ក៏ទទួលរងឥទ្ធិពលនិងជួបប្រទះនូវបញ្ហាខាងលើនេះដែរ។

**តារាង៖** ស្ថិតិសិស្សចូលអានសៀវភៅនៅបណ្ណាល័យ វិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក

| ឆ្នាំសិក្សា | សិស្សសរុប | សិស្សស្រី | ភាគរយ | សិស្សសរុប ចូលអាន | សិស្សស្រី ចូលអាន |
|---|---|---|---|---|---|
| 2018-2019 | 1292 | 702 | 83,28% | 1075 | 584 |
| 2019-2020 | 1334 | 683 | 62,46% | 833 | 426 |
| 2020-2021 | 1344 | 689 | 41,64% | 559 | 286 |

យោងតាមស្ថិតិសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យខាងលើបានបង្ហាញឱ្យឃើញថា៖ នៅឆ្នាំសិក្សា២០១៨-២០១៩ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យរហូតដល់៨៣.២៨%។ ចំណែកឯឆ្នាំសិក្សា២០១៩-២០២០ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យ៦២.៤៦% ហើយនៅឆ្នាំសិក្សា២០២០-២០២១ មានសិស្សចូលអានសៀវភៅនៅក្នុងបណ្ណាល័យ៤១.៦៤%។ យោងតាមទិន្នន័យបង្ហាញថា ភាគរយសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យមានការធ្លាក់ចុះជាលំដាប់ ដោយសារជំងឺរាតត្បាតសកលដែលតម្រូវឱ្យរក្សាគម្លាតសង្គម។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសផ្អាកដំណើរការសាលារៀននៅទូទាំងប្រទេស ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលគឺ ៣ កុំ និង៣ ការពារ ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩។

ហេតុនេះ ក្រុមអ្នកស្រាវជ្រាវនៅវិទ្យាល័យ ហ៊ុន សែន បល្ល័ង្កបានលើកយកនូវប្រធានបទដែលទាក់ទងនឹងកម្សោយនៃការអានរបស់សិស្សមួយចំនួនមកធ្វើការវិភាគស្រាវជ្រាវរកឱ្យឃើញថា៖«តើមូលហេតុអ្វីបានជាសិស្សមួយចំនួនមិនសូវចេះអានអក្សរ?»

ដើម្បីស្រាយចម្ងល់ដ៏ចាក់ស្រេះខាងលើនេះ ក្រុមអ្នកស្រាវជ្រាវបានចុះសិក្សានិងឈ្វេងយល់យ៉ាងល្អិតល្អន់ដើម្បីស្វែងរកមូលហេតុដែលនាំឱ្យសិស្សមួយចំនួនមិនសូវចេះអានអក្សរ។ ក្នុងនោះ ការសិក្សាកន្លងមកបានរកឃើញពាក់ព័ន្ធនឹងកត្តា៣យ៉ាងគឺ កត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្ស។

**កត្តាគ្រូបង្រៀន៖** លោកគ្រូ អ្នកគ្រូ ភាគច្រើនមិនសូវមានសកម្មភាពក្នុងដឹកនាំសិស្សចូលអានក្នុងបណ្ណាល័យនិងមណ្ឌលអាន ដែលធ្វើសិស្សខ្សោយនូវសមត្ថភាពក្នុងការអាននិងសរសេរឱ្យបានត្រឹមត្រូវ។ ទាំងនេះ ជាហេតុផលមួយដែលធ្វើឱ្យសិស្សានុសិស្សមួយចំនួនមានភាពខ្វះខាតទាំងផ្នែកទទួលព័ត៌មាន និងបំណិនផ្នែកអាន។

**កត្តាគ្រួសារ៖** ជាទូទៅនៅក្នុងគ្រួសារនីមួយៗមានស្ថានភាពជីវភាពគ្រួសារផ្សេងៗពីគ្នា ដែលក្នុងនោះគ្រួសារមួយចំនួនបានយកចិត្តទុកដាក់ក្នុងការតាមដាន និងជំរុញកូនក្នុងការសិក្សារៀនសូត្រ តែក៏មានគ្រួសារមួយចំនួនមិនសូវបានជំរុញនិងលើកទឹកចិត្តកូនក្នុងការសិក្សារៀនសូត្រ ដោយសារតែគាត់មានការមមាញឹកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំងមិនបានរៀបចំបន្ទប់សិក្សានៅផ្ទះ(មានតុកៅអី ក្តារខៀន ទូរដាក់សៀវភៅជាដើម)។

**កត្តាសិស្សខ្លួនឯង៖** សិស្សនុសិស្សមួយចំនួនមិនសូវចូលចិត្តអានគឺការអានរបស់គាត់មានរយៈពេលខ្លីចន្លោះពី១០-១៥នាទី ព្រមទាំងអនុវត្តមិនទៀងទាត់។ សិស្សមួយចំនួនតូចមិនមានពេលវេលាគ្រប់គ្រាន់ព្រោះត្រូវជួយការងារផ្ទះឬដើរលក់ដូរតាមតំបន់ផ្សេងៗ ចំណែកសិស្សមួយចំនួនទៀតរវល់ធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ សិស្សមួយចំនួនតូចមិនសូវចូលចិត្តអានសៀវភៅដោយលើកហេតុផលថាឈឺក្បាលនិងងងុយដេក។ ម៉្យាងទៀត កត្តាសម្ភារៈនិយមក៏ជាបញ្ហាមួយដែលធ្វើឱ្យសិស្សមួយចំនួនចូលចិត្តលេងហ្គេម(Game) និងមើលយូធូប(YouTube) ដែលជាហេតុធ្វើឱ្យបាត់បង់ពេលវេលាអានសៀវភៅ។

## ២.វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមអ្នកស្រាវជ្រាវធ្វើការជ្រើសរើសអ្នកពាក់ព័ន្ធក្នុងការសម្ភាសសរុបចំនួន១៥នាក់ ក្នុងនោះមាន នាយក០១នាក់ គ្រូបង្រៀន០២នាក់ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស០២នាក់ និងសិស្សានុសិស្ស១០នាក់ ក្នុងនោះមានស្រីចំនួន០៧នាក់។ ទីតាំងនៃការស្រាវជ្រាវនេះធ្វើឡើងនៅក្នុងវិទ្យាល័យ ហ៊ុន សែន បល្ល័ង្ក ដែលស្ថិតនៅក្នុងភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

អ្នកផ្តល់សម្ភាសបានធ្វើការឆ្លើយតបនឹងសំណួរស្រាវជ្រាវក្នុងនោះមាន៖ នាយកសាលាបានឆ្លើយចំនួន០៧សំណួរ ដែលទាក់ទងទៅនឹងបណ្ណាល័យ សៀវភៅនៅក្នុងបណ្ណាល័យ ទីកន្លែងអាននៅក្នុងសាលារៀន ការខ្ចីសៀវភៅពីបណ្ណាល័យ ទិន្នន័យសិស្សអានសៀវភៅប្រចាំឆ្នាំ ផែនការសម្រាប់សិស្សានុសិស្សចូលអានសៀវភៅនៅបណ្ណាល័យនិងកម្មវិធីប្រឡងអំណាននៅក្នុងសាលារៀន។ កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូមានចំនួន០៤សំណួរដែលទាក់ទងទៅនឹងសកម្មភាពដឹកនាំសិស្សានុសិស្សអានសៀវភៅ ការជំរុញឱ្យសិស្សអានសៀវភៅនៅផ្ទះ វិធីសាស្ត្រក្នុងការលើកទឹកចិត្តសិស្សឱ្យអានសៀវភៅនៅផ្ទះនិងវិធីសាស្ត្រអានបណ្តាក់នៅក្នុងថ្នាក់រៀន។ សម្រាប់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលមានចំនួន០៤សំណួរ ដែលទាក់ទងទៅនឹងសកម្មភាពអានសៀវភៅនៅផ្ទះ ការជំរុញនិងការលើកទឹកចិត្ត

ព្រមទាំងការផ្តល់សៀវភៅសម្រាប់កូនអាននៅផ្ទះ។ សម្រាប់សិស្សានុសិស្សមានចំនួន០៨សំណួរដែលទាក់ទងទៅនឹងទម្លាប់នៃការអានសៀវភៅនៅផ្ទះ ការជួយបង្រៀនបន្ថែមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល ចំណង់ចំណូលចិត្តក្នុងការអានសៀវភៅ សារៈប្រយោជន៍នៃការអានសៀវភៅ ការប្រកួតប្រជែងគ្នាក្នុងការអាន ការជួយគ្នាពីរបៀបអានសៀវភៅ ការណែនាំឱ្យមិត្តភក្តិអានសៀវភៅ និងមិត្តភក្តិណែនាំក្នុងការអានសៀវភៅ។

ក្រុមអ្នកស្រាវជ្រាវយើងប្រមូលទិន្នន័យបានតាមរយៈការសម្ភាស ដោយប្រើកម្រងសំណួរ ហើយបានធ្វើការកំណត់ច្បាស់នូវចំនួនអ្នកចូលរួមដូចជា លោកនាយក លោកគ្រូ អ្នកគ្រូ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស រួមទាំងសិស្សានុសិស្សផងដែរ ដែលទាក់ទងទៅនឹងប្រធានបទដែលកំពុងធ្វើការស្រាវជ្រាវ។

ទិន្នន័យបានពីការសម្ភាសត្រូវបានកត់ត្រា ដោយបំពេញព័ត៌មានតាមលំដាប់លំដោយនៃអ្នកចូលរួម ដើម្បីពិនិត្យរកគំនិតសំខាន់ៗដែលមានសារៈប្រយោជន៍ដាក់ក្នុងតារាងតាមលេខរៀងនៃអ្នកចូលរួមម្តងមួយៗរហូតដល់គ្រប់គ្នា រួចធ្វើចំណាត់ថ្នាក់គំនិតសំខាន់ទាំងនោះ បន្ទាប់មកធ្វើការវិភាគរកលទ្ធផលស្រាវជ្រាវ ដោយអនុវត្តតាមគោលការណ៍ក្រមសីលធម៌នៃអ្នកស្រាវជ្រាវ។

## ៣.លទ្ធផល និងការពិភាក្សា

យោងតាមលទ្ធផលនៃការសម្ភាសបានបង្ហាញឱ្យឃើញថា មានមតិជាច្រើនបានឆ្លុះបញ្ចាំងអំពីមូលហេតុច្បាស់លាស់ ដែលជះឥទ្ធិពលដល់ការមិនសូវចូលចិត្តអានអក្សររបស់សិស្សានុសិស្សនៅក្នុងវិទ្យាល័យ ហ៊ុន សែនបល្ល័ង្គ កត្តាទាំងនោះរួមមាន៖

### ៣.១.កត្តាគ្រូបង្រៀន

លោកគ្រូ អ្នកគ្រូមួយចំនួនពុំសូវបានហៅសិស្សានុសិស្សឱ្យអានបានច្រើនគ្នា ជាហេតុដែលធ្វើពួកគេតូចចិត្តនិងមិនសូវចាប់អារម្មណ៍ក្នុងការអានសៀវភៅ។ មួយផ្នែកទៀត ម៉ោងសិស្សចូលបណ្ណាល័យត្រូវបានជំនួសដោយត្រូវឱ្យសិស្សានុសិស្សធ្វើការងារផ្សេងៗក្នុងសាលា។

### ៣.២.កត្តាគ្រួសារ

ជីវភាពគ្រួសារជាកត្តាមួយយ៉ាងសំខាន់ក្នុងការកំណត់ជោគវាសនានៃការសិក្សារបស់សិស្ស។ បើគ្រួសារសិស្សមានជីវភាពខ្វះខាត នោះកូនៗប្រឈមនឹងការខ្វះខាតពេលវេលាសម្រាប់អានសៀវភៅ ដោយសារត្រូវការរកប្រាក់បន្ថែមដើម្បីជួយគ្រួសារដែលជាសម្ពាយមួយដ៏ធ្ងន់សម្រាប់ពួកគេ។ តាមមតិរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សបានលើកឡើងថា *«មូលហេតុដែលនាំឱ្យកូនរបស់ខ្ញុំមិនសូវ*

*ចេះអានដោយសារជីវភាពខ្វះខាត ត្រូវបង្ខំចិត្តបោះបង់សៀវភៅដើម្បីយកពេលវេលាជួយឪពុកម្តាយក្នុងការរកប្រាក់ចំណូលតាមរយៈការលក់ដូរទៅធ្វើការពេលពេលទំនេរ(ការងារតាមម៉ោងទំនេរពីការសិក្សា)*»។ ទាំងនេះជាកត្តាមួយដែលធ្វើឱ្យការអានរបស់កូនធ្លាក់ចុះ។ មួយវិញទៀត មាតាបិតាអូសទាញកូនឱ្យធ្វើការងារផ្ទះ ឬមើលប្អូនៗរបស់ពួកគេ និងជួយធ្វើស្រែចំការឪពុកម្តាយ ពីព្រោះកូនៗពួកគាត់ដល់វ័យដែលមានកម្លាំងពលកម្មដែលអាចជួយជំនួសការងាររបស់គាត់បានទាំងស្រុងផងដែរ។ ជាមួយគ្នានោះពួកគាត់គិតថា កូនរៀនមិនសូវចេះហើយ រាល់ពេលកូនទំនេរគាត់តែងតែប្រាប់កូនឱ្យជួយធ្វើការងារ ឬរៀនអាជីពផ្សេងៗទៀតដូចជា ផាត់មុខ ធ្វើសក់ រៀនសំអាងការជាដើម។ លើសពីនេះទៀត សិស្សានុសិស្សមួយចំនួនតូចគ្មានលទ្ធភាពទិញសៀវភៅដែលខ្លួនចូលចិត្តអាន ព្រោះសៀវភៅទាំងនោះមានតម្លៃថ្លៃ ហើយគ្មានលក់នៅក្នុងតំបន់ដែលពួកគេរស់នៅ ឬនៅក្នុងបណ្ណាល័យសាលាឬក៏ទីសាធារណៈ(ទីតាំង)។

ម្យ៉ាងវិញទៀត ភាពមិនចុះសម្រុងគ្នារវាងឪពុកម្តាយដែលអាចឈានទៅដល់ការបែកបាក់គ្នាជាកត្តាជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កូនៗ ជាពិសេស សម្ពាធផ្លូវចិត្ត។ នៅពេលឪពុកម្តាយសិស្សបែកបាក់គ្រួសារធ្វើឱ្យសេដ្ឋកិច្ចគ្រួសារមានការធ្លាក់ចុះដែលប៉ះពាល់ដល់អារម្មណ៍របស់កូនៗក្នុងការរៀនសូត្រពិសេសលើការអានសៀវភៅ។ ឪពុកម្តាយមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់តាមដានការរៀនសូត្ររបស់កូនៗ មិនបានជំរុញញកូនឱ្យអាន ឬមើលមេរៀនជាប្រចាំនិងធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ ឪពុកម្តាយមិនទាន់យល់ដឹងពីករណីយកិច្ចរបស់ខ្លួនដែលត្រូវជួយជំរុញបន្ថែមទៅលើការអានរបស់កូនៗគាត់ទាំងនៅផ្ទះ សាលារៀន និងពេលទំនេរ។ ទាំងនោះជាហេតុធ្វើឱ្យកុមារមិនបានទទួលការថែទាំជិតដល់ មិនអាចផ្តោតអារម្មណ៍ក្នុងការអាននិងធ្វើឱ្យការសិក្សាថយចុះ។

### ៣.៣ កត្តាសិស្សខ្លួនឯង

វិទ្យាសាស្ត្រកាន់តែទំនើប សិស្សានុសិស្សភាគច្រើនហាក់មានការងប់ងល់និងចំណាយពេលច្រើនទៅលើការប្រើប្រាស់បច្ចេកវិទ្យា។ រាល់ពេលទំនេរពីការសិក្សា សិស្សានុសិស្សចំណាយពេលលេងទូរស័ព្ទដូចជា លេងហ្គេម(Game)និងមើលបណ្តាញសង្គមផ្សេងៗទៀត។ គាត់មិនសូវផ្តោតទៅលើការអានសៀវភៅ ទស្សនាវដ្តី កាសែត ព័ត៌មានផ្សេងៗ និងការស្រាវជ្រាវរកមេរៀនដែលមាននៅក្នុងទូរស័ព្ទនោះទេ។

ចំណែកសិស្សានុសិស្សមួយចំនួនតូច ពួកគេអានច្រើនមិនកើតគឺបណ្តាលមកពីមូលហេតុរាល់ពេលអាន ធ្វើឱ្យងងុយគេង ឬគេងលក់ ឈឺក្បាល ព្រិលភ្នែក ឈឺឆ្អឹងខ្នង មានពិការភាព និងជំងឺប្រចាំកាយ។ល។ មួយផ្នែកទៀត បណ្តាលមកពីខ្វះសៀវភៅដែលគាត់ចូលចិត្តអាន ឬពិបាកស្វែងរកសៀវភៅសម្រាប់អាន។

យោងតាមលទ្ធផលនៃកិច្ចសម្ភាស អ្នកចូលរួមទាំងអស់បានលើកឡើងនូវបញ្ហាស្រដៀងគ្នាទាក់ទងនឹងកង្វះការចូលរួមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលក្នុងការជួយជំរុញការអានរបស់កូនៗ។

សរុបសេចក្តីមក ការសិក្សាស្រាវជ្រាវលើប្រធានបទនេះវាមានសារៈសំខាន់ណាស់ដើម្បីជួយដល់ប្អូនៗសិស្សានុសិស្ស ឪពុកម្តាយ ឬអ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ នាយកសាលា ឱ្យពួកគាត់មានការយល់ដឹងពីសារៈសំខាន់នៃការអានសៀវភៅដើម្បីអភិវឌ្ឍសមត្ថភាពខួរក្បាលនៃការសិក្សារបស់កូនៗពួកគាត់ផ្ទាល់ ក៏ដូចជាបានជួយសម្រួលបន្ទុករាជរដ្ឋាភិបាលក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើននាពេលអនាគត។

## ៤.ចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានបញ្ចប់កិច្ចការស្រាវជ្រាវលើប្រធានបទខាងលើនេះរួចមក ក្រុមអ្នកស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបាននូវចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

**ក.ចំណុចខ្លាំងយើងឃើញថា៖** ១) ក្រុមការងារចេះសហការគ្នាធ្វើការបានល្អ ២) បានចុះធ្វើការងារទៅតាមគម្រោងផែនការធ្វើការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ ដឹងតួនាទី និងគោរពពេលវេលា ៣) អ្នកត្រូវចូលរួមសម្ភាសបានផ្តល់ចម្លើយដោយភាពស្មោះត្រង់ ៤) បង្ហាញពីគោលបំណងនៃការសម្ភាសច្បាស់លាស់ដល់អ្នកចូលរួមផ្តល់សម្ភាស ៥) រាល់ចម្លើយរបស់អ្នកចូលរួមផ្តល់សម្ភាសត្រូវរក្សាទុកជាការសម្ងាត់។

**ខ.ចំណុចខ្សោយមានដូចខាងក្រោម៖** ១) រយៈពេលខ្លីពេកសម្រាប់ប្រមូលទិន្នន័យ និងការបង្កើតកម្រងសំណួរ ២) សមាសភាពអ្នកផ្តល់បទសម្ភាសមានចំនួនតិច ៣) មានការខ្វែងគំនិតគ្នាបន្តិចបន្តួចពេលធ្វើកម្រងសំណួរ និង ៤) មិនបានកំណត់ពេលវេលាសម្រាប់សម្ភាស។

## ៥. សេចក្តីសន្និដ្ឋាន

ក្រោយពីការវិភាគលទ្ធផលរួចមក អ្នកស្រាវជ្រាវសន្និដ្ឋានបានថាមានកត្តា៣ធំៗដែលជះឥទ្ធិពលនិងប្រឈមខ្លាំងដែលធ្វើឱ្យសិស្សានុសិស្សមិនសូវចូលចិត្តអានអក្សរគឺកត្តាគ្រូបង្រៀន កត្តាគ្រួសារ និងកត្តាសិស្សផ្ទាល់ខ្លួន។ **កត្តាគ្រូបង្រៀន៖** លោកគ្រូ អ្នកគ្រូមួយចំនួនតូចខ្វះវិធីសាស្ត្រក្នុងការបង្រៀនសិស្ស មិនសូវបានសួរសំនួរសិស្ស ពុំសូវហៅសិស្សអានឱ្យបានញឹកញាប់គ្រប់ៗគ្នាឬប្រាប់ឱ្យសិស្សអានមេរៀននៅពេលទំនេរ ដើម្បីឱ្យស្ទាត់ជំនាញក្នុងការអាននិងសរសេរ ពេលម៉ោងចូលបណ្ណាល័យពួកគាត់ឱ្យសិស្សធ្វើការងារផ្សេងៗនិងព្រងើយកន្តើយឬរើសអើងសិស្ស។ **កត្តាគ្រួសារ៖** ឪពុកម្តាយ ឬអ្នក

អាណាព្យាបាលពុំសូវបានយកចិត្តទុកដាក់និងតាមដានលើការសិក្សារបស់កូនៗ ប្រើប្រាស់កម្លាំងពលកម្មរបស់កូន ដោយឱ្យជួយលក់ដូរ ធ្វើការងារផ្ទះនិងទៅធ្វើការក្រៅម៉ោងរាល់ពេលទំនេរមិនសូវបានលើកទឹកចិត្តកូនៗក្នុងការរៀនសូត្រ និងមិនយល់ពីកាតព្វកិច្ចរបស់កូន។ **កត្តាសិស្សខ្លួនឯង៖** មានពិការភាព ជំងឺប្រចាំកាយ ខ្សោយការអាននិងការសរសេរពាក្យ កាលពីរៀននៅបឋមសិក្សា។ មួយវិញទៀតសិស្សមួយចំនួនញៀនលេងហ្គេម(Game) និងចូលចិត្តមើលបណ្ដាញសង្គមផ្សេងៗដែលមិនមានប្រយោជន៍ដល់ការសិក្សារបស់ខ្លួន។

## អនុសាសន៍

បន្ទាប់ពីកំណត់បាននូវបញ្ហាប្រឈមខ្លាំងបំផុតអាចឱ្យក្រុមអ្នកស្រាវជ្រាវផ្តល់អនុសាសន៍មួយចំនួនដូចជា៖ ១.ឪពុកម្តាយ ឬអ្នកអាណាព្យាបាលមានករណីយកិច្ចនិងកាតព្វកិច្ចបញ្ជូនកូនទៅសាលារៀនឱ្យបានគ្រប់ៗគ្នា ពិសេសជំរុញការរៀនសូត្រនៅផ្ទះតាមរយៈការអាន ការធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ។ ២. សាលារៀនគួររៀបចំធ្វើការប្រកួតប្រជែងលើការអានតាមកម្រិតថ្នាក់ដើម្បីជំរុញអានឱ្យកាន់តែប្រសើរឡើង។ លោកគ្រូ អ្នកគ្រូគួរមានតម្លាភាពក្នុងការបង្រៀនអាចឱ្យសិស្សអានបានគ្រប់ៗគ្នានិងជំរុញលើកទឹកចិត្តឱ្យសិស្សខំប្រឹងរៀន(អាន)។ ៣.សិស្សខ្លួនឯងផ្ទាល់គួរថែទាំសុខភាពឱ្យបានល្អ កាត់បន្ថយប្រើទូរស័ព្ទ ដោយយកពេលវេលាមកអានមេរៀន ធ្វើកិច្ចការសាលាដែលលោកគ្រូ អ្នកគ្រូបានដាក់ឱ្យ និងព្យាយាមពង្រឹងសមត្ថភាពអានរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។

## ឯកសារយោង

ដោ នីដា. (2020). *ពេលព្រឹកដ៏អស្ចារ្យ*. ភ្នំពេញ: edu.នាយកដ្ឋានធានាគុណភាពអប់រំ. (២០២០). *ឯកសារជំនួយស្មារតីស្តីពី "សំណួរតេស្តគំរូនៃកម្មវិធី វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ*. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

រដ្ឋាភិបាលកម្ពុជា .(២០១៥) .*អនុក្រឹត្យស្តីពី ទិវាជាតិអំណាន.* ភ្នំពេញ .រាជរដ្ឋាភិបាលកម្ពុជា : សារព័ត៌មានថ្មីៗ២០២២) ., មីនា ០៦ .(*ថ្មីៗ* :យកមកវិញពី ថ្មីៗ . https://thmeythmey.com/?page=detail&id=113166

ហង់ជួន ណារ៉ុន .(២០២២) .*ទ្រឹស្តីអភិវឌ្ឍភាសា និងទ្រឹស្តីនៃការអភិវឌ្ឍកុមារ.* ភ្នំពេញក្រសួងអប់រំ : .យុវជន និងកីឡា

ឡាំ លីម .(២០១៩) .*អំណានជាអំណាច.* ភ្នំពេញ.

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# តើវិទ្យាល័យព្រះបាទសុរាម្រឹតបានត្រៀមខ្លួនក្លាយជាសាលារៀនជំនាន់ថ្មីហើយ ឬនៅ ?

លឿង បញ្ញាវុឌ្ឍ[១] ហុង សៅ[២] ហែម បញ្ញារិទ្ធិ[៣] ឡុង ស៊ីដាវុធ[៤] ឃឹម ផាត[៥] វី វំចេក[៦] និង សំ វីរៈ[៧]

បានទទួល៖ ០១ មករា ២០២២ សម្រេចយក៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

វិទ្យាល័យព្រះបាទសុរាម្រឹតជាសាលាធនធានដែលមានសក្តានុពល ដោយយោងតាមទីតាំងភូមិសាស្ត្រ គ្រូបង្រៀនមានមនសិការវិជ្ជាជីវៈខ្ពស់ និងមានសិស្សពូកែដែលទទួលបានចំណាត់ថ្នាក់ជាតិ ក៏ដូចជាទទួលបាននិទ្ទេស A ជារៀងរាល់ឆ្នាំ។ តាមរយៈសក្តានុពលគួរឱ្យកត់សម្គាល់នេះ ក្រុមអ្នកស្រាវជ្រាវបានជ្រើសរើសយកប្រធានបទស្តីពី «តើវិទ្យាល័យព្រះបាទសុរាម្រឹតបានត្រៀមខ្លួនក្លាយជាសាលារៀនជំនាន់ថ្មីហើយឬនៅ?» យកមកសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សានេះ ក្រុមអ្នកស្រាវជ្រាវបានកំណត់យកគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្ស ឪពុកម្តាយ ឬអ្នកអាណាព្យាបាល និងសមហគមន៍ជាក្រុមគោលដៅដើម្បីសម្ភាសក្នុងការឈ្វេងយល់អំពីផ្នត់គំនិតនិងគោលជំហររបស់អ្នកពាក់ព័ន្ធទាំងនោះ សម្រាប់គាំទ្រដល់គោលបំណងនៃការប្រែក្លាយវិទ្យាល័យព្រះបាទសុរាម្រឹត ទៅជាសាលារៀនជំនាន់ថ្មីនាពេលខាងមុខ។ ដើម្បីសម្ភាសអ្នកពាក់ព័ន្ធ ក្រុមអ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរដាច់ដោយឡែកសម្រាប់ក្រុមគោលដៅនីមួយៗ ដើម្បីយកទៅសម្ភាសដោយផ្ទាល់។ ជាលទ្ធផល ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា អំឡុងពេលខ្លីនេះ វិទ្យាល័យព្រះបាទសុរាម្រឹតពុំទាន់មានលទ្ធភាពប្រែក្លាយជាសាលារៀនជំនាន់ថ្មីនៅឡើយទេ ដោយសារកត្តាមួយចំនួនដូចជា គ្រូបង្រៀនមានសមត្ថភាពឌីជីថលនៅមានកម្រិត អាណាព្យាបាលសិស្សមួយចំនួនធំមានជីវភាពខ្វះខាត ហើយសិស្សមិនទាន់យល់ដឹងទូលំទូលាយពី

សាលារៀនជំនាន់ថ្មី ដែលជាហេតុនាំឱ្យពួកគេពិបាកក្នុងការសម្រេចចិត្តជ្រើសរើសចូលរៀននៅសាលារៀនជំនាន់ថ្មី។

ដើម្បីឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតប្រែក្លាយជាសាលារៀនជំនាន់ថ្មី គណៈគ្រប់គ្រងត្រូវបង្កើនសមត្ថភាពឌីជីថលនិងជួយជំរុញលើទឹកចិត្តដល់លោកគ្រូ អ្នកគ្រូឱ្យចូលបង្រៀននៅសាលារៀនជំនាន់ថ្មី ហើយជួយផ្សព្វផ្សាយនិងជួយជំរុញសិស្សឱ្យចូលបង្រៀននៅសាលាជំនាន់ថ្មី។ ម៉្យាងទៀត គណៈគ្រប់គ្រងសាលាត្រូវមានទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ ជាពិសេសសហគមន៍ក្នុងការផ្សព្វផ្សាយឱ្យពួកគាត់បានដឹងពីសារៈប្រយោជន៍ក្នុងការប្រែក្លាយសាលាធនធានឱ្យទៅសាលារៀនជំនាន់ថ្មី។ ដោយឡែក ចំពោះសិស្សដែលមានជីវភាពខ្វះខាត គួរបន្ធូរបន្ថយថ្លៃសិក្សា ឬជួយរកជំនួយផ្សេងៗ តាមរយៈអាជ្ញាធរ និងសប្បុរសជនដើម្បីជួយឧបត្ថម្ភឱ្យពួកគេបានចូលរៀននៅសាលារៀនជំនាន់ថ្មីដូចសិស្សដទៃ។

**អាគតដ្ឋាន:** លឿង, ប., ហុង, ស., &ហែម, ប. (២០២២). តើវិទ្យាល័យព្រះបាទសុរាម្រឹតបានត្រៀមខ្លួនក្លាយជាសាលារៀន ជំនាន់ថ្មីហើយឬនៅ? *កាលិកបត្រអប់រំកម្ពុជា,* ៥(១),២៨-៣៥។

## ១. សេចក្តីផ្តើម

នៅឆ្នាំ១៩៥៨ ដោយលោក ឌុក សាអ៊ីម ដែលជាចៅហ្វាយស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ជាប្រធានសាងសង់នៃគម្រោងសាលាអនុវិទ្យាល័យព្រះបាទសុរាម្រឹត។ បន្ទាប់មកសាលានេះត្រូវបានប្រែក្លាយទៅជាវិទ្យាល័យវិញនៅក្នុងឆ្នាំ១៩៦៣ និងចុងក្រោយបានក្លាយជាវិទ្យាល័យព្រះបាទសុរាម្រឹតនៅក្នុងឆ្នាំ១៩៩៣។ វិទ្យាល័យព្រះបាទសុរាម្រឹតមានទីតាំងស្ថិតនៅភូមិស្រែព្រីង សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង (វិទ្យាល័យព្រះបាទសុរាម្រឹត, ១៩៨០)។ បច្ចុប្បន្នវិទ្យាល័យព្រះបាទសុរាម្រឹតមានអគារសិក្សាចំនួន១៥ខ្នង មាន៨៨បន្ទប់ និងនៅឆ្នាំ២០១០ ក្រោមការកំណែទម្រង់សាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈគោលនយោបាយសាលាមធ្យមសិក្សាធនធាន វិទ្យាល័យព្រះបាទសុរាម្រឹតបានទទួលអគារធនធានមួយខ្នង ដែលបានបំពាក់នូវបន្ទប់ព័ត៌មានវិទ្យា (ICT) ចំនួន០២ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន ០២ ដែលមាន(បួនមុខវិជ្ជា) បណ្ណាល័យចំនួន០១ និងជាពិសេសនៅឆ្នាំ ២០២១ ក្រសួងអប់រំ យុវជន និងកីឡាបានជួយរៀបចំបន្ថែមនូវបន្ទប់ពិសោធន៍វិទ្យាសាស្ត្រចំនួន ០២ និងបន្ទប់ពហុបំណងចំនួន ០១បន្ថែមទៀត។ វិទ្យាល័យព្រះបាទសុរាម្រឹតមានគ្រូបង្រៀនសរុបចំនួន ១៦៣ នាក់ ស្រី ៦៣ នាក់ ក្នុងនោះគ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ០៧ នាក់ ស្រីចំនួន ០១នាក់ និងមានសិស្សសរុបចំនួន ២៨៦០នាក់ ស្រីចំនួន

១៥៦៥នាក់។ សាលារៀនមានសិស្សពូកែថ្នាក់ជាតិ និងសិស្សដែលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទទួលបាននិទ្ទេស A ជារៀងរាល់ឆ្នាំ (វិទ្យាល័យព្រះបាទសុរាម្រឹត, ២០២២)។ សាលារៀនមានការរីកចម្រើនទាំងលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បរិស្ថានល្អ និងការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ ដោយសារមានការចូលរួមពីលោកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដី សហគមន៍ ឪពុកម្តាយ និងអ្នកអាណាព្យាបាល។

នៅក្នុងឆ្នាំសិក្សា ២០២១-២០២២ វិទ្យាល័យព្រះបាទសុរាម្រឹតទទួលសិស្សដែលផ្នែកវិទ្យាសាស្ត្រទទួលបានលទ្ធផលជាប់ល្អប្រសើរជាងសិស្សថ្នាក់វិទ្យាសាស្ត្រសង្គម ក្នុងនោះសិស្សបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ថ្នាក់វិទ្យាសាស្ត្រ ៦០.៦៣% និងថ្នាក់វិទ្យាសាស្ត្រសង្គម ៥៧.៦៧%។ លើសពីនេះ នៅវិទ្យាល័យព្រះបាទសុរាម្រឹតមានសិស្សពូកែថ្នាក់ជាតិ និងសិស្សប្រឡងជាប់និទ្ទេស A ជារៀងរាល់ឆ្នាំ ព្រមទាំងមានគ្រូបង្រៀនដែលមានបទពិសោធបង្រៀនយូរឆ្នាំច្រើន។ម្យ៉ាងវិញទៀតមានការចូលរួមយ៉ាងជិតស្និតពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ក្នុងការចូលរួមចំណែកអភិវឌ្ឍសាលារៀននិងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សដែលធ្វើឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតក្លាយជាវិទ្យាល័យគំរូមួយក្នុងខេត្តកំពង់ឆ្នាំង (វិទ្យាល័យព្រះបាទសុរាម្រឹត, ២០២២)។ វឌ្ឍនភាពទាំងនេះកើតឡើងដោយមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធជាច្រើនដូចជា គណៈគ្រប់គ្រង គ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយ ឬអ្នកអាណាព្យាបាល អាជ្ញាធរដែនដីនិងសហគមន៍។

ទន្ទឹមនឹងមានការអភិវឌ្ឍទាំងនេះ វិទ្យាល័យព្រះបាទសុរាម្រឹត ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវការដោះស្រាយដូចជា បរិស្ថានសាលារៀននៅមិនទាន់មានសោភណភាពល្អប្រសើរ គ្រូបង្រៀនភាគច្រើនមានវ័យចំណាស់ដែលមានជំងឺប្រចាំកាយ នៅខ្វះសម្ភារៈសម្រាប់ដំណើរការបង្រៀន និងរៀនតាមអនឡាញ សិស្សមួយចំនួនមិនសូវចូលចិត្តរៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយឪពុកម្តាយ ឬអ្នកអាណាព្យាបាលមួយចំនួនពុំសូវបានយកចិត្តទុកដាក់និងជំរុញកូនឱ្យចូលរៀនថ្នាក់វិទ្យាសាស្ត្រនោះទេ (វិទ្យាល័យព្រះបាទសុរាម្រឹត, ២០២២)។

យោងតាមវឌ្ឍនភាពដែលគួរឱ្យកត់សម្គាល់ខាងលើ ក្រុមអ្នកស្រាវជ្រាវសម្រេចជ្រើសយកប្រធានបទស្រាវជ្រាវ «តើវិទ្យាល័យព្រះបាទសុរាម្រឹតបានត្រៀមខ្លួនក្លាយជាសាលារៀនជំនាន់ថ្មីហើយឬនៅ?»យកមកសិក្សាដើម្បីពិនិត្យមើលលទ្ធភាពដែលអាចឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតត្រៀមលក្ខណៈប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី ស្របតាមចក្ខុវិស័យនៃកំណែទម្រង់ការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡានាពេលបច្ចុប្បន្ន និងឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍជាតិឆ្នាំ ២០៣០។

## ២. វិធីសាស្ត្រ

ការស្រាវជ្រាវនេះបានជ្រើសរើសអ្នកដែលពាក់ព័ន្ធនឹងប្រធានបទមកចូលរួមដូចជា គណៈគ្រប់គ្រង់សាលាចំនួន០២នាក់ លោកគ្រូ អ្នកគ្រូចំនួន ១៥នាក់ សិស្សចំនួន ២០នាក់ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្សចំនួន ១០ នាក់ និងអាជ្ញាធរចំនួន ០១នាក់ ដោយមានការណាត់ពេលជាមុនបន្ទាប់មកបែងចែកក្រុមការងារដើម្បីចុះសម្ភាសដោយផ្ទាល់នៅតាមសាលារៀន។ ដោយឡែកចំពោះឪពុកម្ដាយ ឬ អ្នកអាណាព្យាបាលសិស្ស ក្រុមអ្នកស្រាវជ្រាវធ្វើសម្ភាសផ្ទាល់ខ្លះ និងតាមរយៈកូនរបស់គាត់ខ្លះ។ នៅក្នុងការសម្ភាសនេះក៏បានជួបបញ្ហាលំបាកមួយចំនួនដែរដូចជា លោកគ្រូ អ្នកគ្រូមិនសូវមានការសហការចូលរួមឆ្លើយសំណួរដែលក្រុមអ្នកស្រាវជ្រាវបានសាកសួរ ហើយមួយចំនួនទៀត មិនចូលរួមឆ្លើយ និងឪពុកម្ដាយ ឬ អ្នកអាណាព្យាបាលសិស្សមួយចំនួនមានទីលំនៅឆ្ងាយពីសាលាដែលធ្វើឱ្យក្រុមអ្នកស្រាវជ្រាវមានការលំបាកក្នុងការចុះសម្ភាសដោយផ្ទាល់។

អ្នកដែលត្រូវបានជ្រើសរើសចូលរួមសម្ភាសគឺជាបុគ្គល ដែលមានការចូលរួមដោយផ្ទាល់ និងប្រយោលក្នុងការជួយជំរុញសាលាធនធានឱ្យក្លាយទៅជាសាលារៀនជំនាន់ថ្មី ហើយនៅក្នុងការសម្ភាសក្រុមអ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរដែលទាក់ទងនឹងប្រធានបទស្រាវជ្រាវ សម្រាប់ក្រុមគោលដៅនីមួយៗមុននឹងចុះសម្ភាស។ អំឡុងការសម្ភាសក្រុមអ្នកស្រាវជ្រាវបានកត់ត្រាចម្លើយរបស់អ្នកចូលរួមក្នុងតារាង ហើយបានស្រង់យកគំនិតសំខាន់ៗ ដើម្បីកត់ត្រាចូលក្នុងតារាងដែលភ្ជាប់ជាមួយកម្រងសំណួរឱ្យមានភាពងាយស្រួលក្នុងការវិភាគ និងបកស្រាយទិន្នន័យ។ ការស្រាវជ្រាវនេះត្រូវបានវិភាគទិន្នន័យតាមរយៈការវិភាគគំនិតសំខាន់ៗ។

## ៣. លទ្ធផល និងការពិភាក្សា

តាមរយៈការសម្ភាសគណៈគ្រប់គ្រង ក្រុមអ្នកស្រាវជ្រាវសង្កេតទទួលបានគំនិតចម្រុងៗផ្សេងគ្នាលើនិន្នាការនៃការប្រែក្លាយវិទ្យាល័យព្រះបាទសុរាម្រឹតទៅជាសាលារៀនជំនាន់ថ្មីដូចខាងក្រោម៖

### ៣.១. លទ្ធភាពក្នុងការប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី

គណៈគ្រប់គ្រងបានផ្ដល់ចម្លើយថា វិទ្យាល័យព្រះបាទសុរាម្រឹតមានអគារ បណ្ណាល័យ បន្ទប់ ICT និង STEAM បន្ទប់ពិសោធន៍ ថ្នាក់រៀនគ្រប់គ្រាន់ ភូមិសាស្ត្រក្នុងក្រុងធំទូលាយនិងមានសិស្សទទួលបានមេដាយទាំងថ្នាក់ជាតិនិងអន្តរជាតិ។ ចំណែកបុគ្គលិកអប់រំមានបទពិសោធ មានគុណធម៌ មនសិការវិជ្ជាជីវៈ មានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានផែនការដឹកនាំនិងត្រួតពិនិត្យច្បាស់លាស់ ព្រមទាំងមានតម្លាភាពក្នុងការអនុវត្តន៍ការងារបង្រៀននិងរៀន។ បន្ថែមពីនេះទៀត យោងតាមចម្លើយពីគ្រូបង្រៀន

ក៏បានអះអាងថា លោកគ្រូ អ្នកគ្រូមួយចំនួនមានមនសិការវិជ្ជាជីវៈក្នុងការងារបង្ហាត់បង្រៀនសិស្ស មានសមត្ថភាពលើមុខវិជ្ជាឯកទេសរបស់ខ្លួននិងមានសមត្ថភាពព័ត៌មានវិទ្យាដែលអាចចូលរួមក្នុងការបម្រើការក្នុងសាលារៀនជំនាន់ថ្មីបាន។

ចំណែកឯសិស្សានុសិស្សមួយចំនួនក៏ចង់ឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតក្លាយទៅជាសាលារៀនជំនាន់ថ្មីផងដែរ ព្រោះសាលានេះមានគ្រូបង្រៀនល្អៗ មានវិន័យ សីលធម៌ល្អ និងបែបបទក្នុងការសិក្សារៀនសូត្រប្រសើរជាងនៅសាលាធនធាន ព្រមទាំងមានអគារ សម្ភារៈសិក្សាមានភាពទំនើប និងបរិយាកាសសិក្សាល្អជាង ជាពិសេសសិស្សមិនត្រូវការចំណាយពេលវេលា និងថវិការទៅរៀនគួរបន្ថែមទៀត។ សិស្សបន្តទៀតថា ពួកគេចង់ឈ្វេងយល់នូវអ្វីដែលថ្មីៗ ជាពិសេសការផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ ឬស្ទែមដែលសាលារៀនជំនាន់ថ្មីអាចផ្តល់ឱ្យពួកគេខុសពីសាលាធនធាន។ ម៉្យាងវិញទៀតយោបល់ពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សក៏បង្ហាញថា ពួកគាត់មានចំណាប់អារម្មណ៍ចង់ឱ្យកូនរបស់ពួកគាត់បានរៀននៅសាលាដែលមានការអប់រំល្អដូចជាសាលារៀនជំនាន់ថ្មីផងដែរ ដោយពួកគាត់បានសន្យាថា នឹងជំរុញកូនរបស់គាត់ឱ្យចូលរៀននៅសាលានេះ ព្រមទាំងជួយឧបត្ថម្ភសម្ភារៈ និងថវិកាទៅតាមលទ្ធភាពដែលអាចជួយបាន។ ចំពោះសហគមន៍វិញបានលើកឡើងថា ពួកគាត់នឹងចូលជួយគាំទ្រឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតក្លាយទៅជាសាលារៀនជំនាន់ថ្មី តាមរយៈការជួយពន្យល់ដល់ប្រជាពលរដ្ឋក្នុងសហគមន៍របស់គាត់ឱ្យជំរុញកូនចូលរៀននៅសាលារៀនជំនាន់ថ្មី និងជួយកៀរគរថវិកានិងសម្ភារៈបន្ថែមទៀតដើម្បីជួយគាំទ្រឱ្យសាលានេះដំណើរការទៅបាន។

### ៣.២. បញ្ហាក្នុងការប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី

ទន្ទឹមនឹងការគាំទ្រពីនាក់ពាក់ព័ន្ធក្នុងការជំរុញវិទ្យាល័យព្រះបាទសុរាម្រឹតឱ្យក្លាយជាសាលារៀនជំនាន់ថ្មីតាមរយៈការសម្ភាសគណៈគ្រប់គ្រង ក៏នៅមានបញ្ហាប្រឈមចម្បងមួយចំនួនដែលវិទ្យាល័យព្រះបាទសុរាម្រឹត អាចប្រឈមមុខក្នុងការដោះស្រាយ ដើម្បីប្រែក្លាយជាសាលារៀនជំនាន់ថ្មី។ កត្តាទាំងនោះមានដូចជា គណៈគ្រប់គ្រប់ លោកគ្រូ អ្នកគ្រូមួយចំនួនធំមានសមត្ថភាពឌីជីថលនៅមានកម្រិតនៅឡើយ ជីវភាពគ្រួសារសិស្សក៏មានកម្រិតមធ្យម ខ្លះក្រីក្រ សាលារៀនមិនទាន់មានអាហារដ្ឋានសម្រាប់សិស្ស មិនទាន់មានអាគារសម្រាប់សិស្សសម្រាកនៅពេលថ្ងៃ និងបរិស្ថានសាលានៅពុំទាន់មានភាពល្អប្រសើរនៅឡើយ។ ចំពោះគ្រូបង្រៀនភាគច្រើនពុំមានចិត្តចង់បង្រៀននៅសាលារៀនជំនាន់ថ្មីទេ ព្រោះពួកគាត់គិតថា សាលារៀនជំនាន់ថ្មីមានការងារច្រើន ធ្វើឱ្យគាត់មានការលំបាក ហត់នឿយ ហើយប្រាក់ដែលឧបត្ថម្ភក៏មិនច្រើន។ ហេតុដូច្នេះ គាត់ចង់ទុកពេលទៅរកស៊ី ឬក៏ទៅបង្រៀនគួនៅខាងក្រៅវិញបានប្រាក់ចំណូលច្រើនជាងយកពេលទៅបង្រៀននៅសាលារៀនជំនាន់ថ្មី។ ដោយឡែកសិស្សមួយ

ចំនួនធំមិនចង់ឱ្យវិទ្យាល័យព្រះបាទសុរាម្រឹតក្លាយជាសាលារៀនជំនាន់ថ្មីដែរ ពីព្រោះពួកគេពិបាកសម្របខ្លួនដោយយល់ថា សាលារៀនជំនាន់ថ្មីមានការសិក្សាតឹងរ៉ឹងពេក ហើយសិស្សភាគច្រើននៅវិទ្យាល័យព្រះបាទសុរាម្រឹតមកពីគ្រួសារ ដែលមានជីវភាពខ្វះខាតផង ពុំមានលទ្ធភាពចូលរួមជាថវិកាជាមួយសាលា ដើម្បីដំណើរការបង្រៀននិងរៀនរបស់សាលារៀនជំនាន់ថ្មីទេ។ ចំណែកឯអាជ្ញាធរមួយចំនួនបានលើកឡើងថា ពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគាត់ភាគច្រើននៅមានជីវភាពខ្វះខាត ពិបាកក្នុងការជំរុញឱ្យកូនចៅរបស់ពួកគាត់ចូលរៀននៅសាលារៀនជំនាន់ថ្មី ពីព្រោះពួកគាត់ត្រូវការឱ្យកូនយកពេលវេលាខ្លះ ដើម្បីជួយធ្វើការងារក្នុងគ្រួសារ។

## ៤. ចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីក្រុមអ្នកស្រាវជ្រាវបានកំណត់គោលដៅដែលត្រូវចុះសម្ភាសរួចហើយ ការសម្ភាសមានការចូលរួមពិភាក្សាយ៉ាងក្បោះក្បាយទៅលើសំណួរនីមួយៗពីសំណាក់គណៈគ្រប់គ្រង គ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយ ឬអ្នកអាណាព្យាបាល និងអាជ្ញាធរមូលដ្ឋានដែលធ្វើឱ្យក្រុមអ្នកស្រាវជ្រាវទទួលបាននូវចម្លើយជាក់លាក់ អាចយកជាការបានដើម្បីសិក្សាទៅលើប្រធានបទនេះ។ ទោះយ៉ាងណាក៏នៅមានបញ្ហាលំបាកខ្លះដែរ សម្រាប់ក្រុមអ្នកស្រាវជ្រាវដែលចុះសម្ភាសទៅតាមគោលដៅ ដែលមានទីតាំងនៅឆ្ងាយ ពីព្រោះខ្វះការសហការរបស់អ្នកចូលរួមផ្តល់សម្ភាសមួយចំនួន ដោយពួកគាត់ឆ្លើយថាមិនចេះឆ្លើយនឹងសំណួរទាំងនោះ ឬក៏ឆ្លើយថា ពួកគាត់មានការរវល់ច្រើន។ លើសពីនេះ ដោយពុំសូវមានការយល់ដឹងទៅលើប្រធានបទនេះ ពួកគាត់ក៏បដិសេធមិនផ្តល់ការសម្ភាសតែម្តង។

## ៥. សរុបសេចក្តី អនុសាសន៍

យោងតាមលទ្ធផលនៃការស្រាវជ្រាវបង្ហាញថា វិទ្យាល័យព្រះបាទសុរាម្រឹតនៅពុំទាន់បានត្រៀមខ្លួនគ្រប់គ្រាន់នៅឡើយទេក្នុងការប្រែក្លាយពីសាលាធនធានទៅជាសាលារៀនជំនាន់ថ្មី ពីព្រោះត្រូវការពេលវេលាបន្ថែមទៀតដើម្បីបំពេញនៅចំណុចខ្វះខាត។

ឆ្លើយតបនឹងចំណុចដែលនៅខ្វះខាតទាំងនោះ ក្រុមអ្នកស្រាវជ្រាវយល់ឃើញថា វិទ្យាល័យព្រះបាទសុរាម្រឹតត្រូវការគ្រូបង្រៀនដែលមានឆន្ទៈចង់ចូលរួមបង្រៀននៅសាលារៀនជំនាន់ថ្មី ហើយពួកគាត់ត្រូវជួយជំរុញនិងលើកទឹកចិត្តសិស្សឱ្យមានចំណាប់អារម្មណ៍ចង់ចូលរៀននៅសាលារៀនជំនាន់ថ្មី។ ម៉្យាងទៀត គណៈគ្រប់គ្រងត្រូវជួយជំរុញលើកទឹកចិត្តគ្រូបង្រៀនឱ្យចូលរួមបង្រៀននៅសាលារៀនជំនាន់ថ្មីត្រូវបង្កើនសមត្ថភាពលើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងវិធីសាស្ត្របង្រៀនផ្នែក

វិទ្យាសាស្ត្រដល់គ្រូបង្រៀន ព្រមទាំងបង្កើនការចុះឈ្មោះចូលរៀន ការប្រឡងជាប់ថ្នាក់ជាតិសម្រាប់ថ្នាក់វិទ្យាសាស្ត្រ និងពង្រឹងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ជាពិសេសសហគមន៍ដើម្បីធានាគុណភាពបង្រៀននិងរៀនដើម្បីគាំទ្រវិទ្យាល័យព្រះបាទសុរាម្រឹតឱ្យក្លាយទៅជាសាលារៀនជំនាន់ថ្មី។

## ឯកសារយោង

វិទ្យាល័យព្រះបាទសុរាម្រឹត . (១៩៨០) . ប្រវត្តិសាលារៀន

វិទ្យាល័យព្រះបាទសុរាម្រឹត . (២០២២) . ស្ថិតិសិស្សដើមឆ្នាំ ២០២២

វិទ្យាល័យព្រះបាទសុរាម្រឹត . (២០២២) . លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសម័យប្រឡង ២៧ ធ្នូ ២០២១

វិទ្យាល័យព្រះបាទសុរាម្រឹត . (១៩៨០) . ព្រឹត្តបត្រព័ត៌មានសាលារៀន

**ក្រសួងអប់រំ យុវជន និងកីឡា**
**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី១០ រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ

សូរ ម៉ាយូណែត*[១] គុជ សំអែល[២] គឹម មង្គល[៣] ប៉ែន វន្ថា[៤] កូវ ធារី[៥] និង ឥន រិទ្ធី[៦]
*វិទ្យាល័យ ហ៊ុន សែន ប្រសូតិ

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ ៖ ១៥ មិថុនា ២០២២

## សង្ខិត្តន័យ

យោងតាមលទ្ធផលសិក្សាសិស្សថ្នាក់ទី១០ លើមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យ ហ៊ុន សែន ប្រសូតិ ខេត្តស្វាយរៀងបង្ហាញថាមានការថយចុះគួរឱ្យកត់សម្គាល់។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដើម្បីកំណត់នូវកត្តាជះឥទ្ធិពលដែលនាំឱ្យសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ។ ការសិក្សានេះប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ ដោយប្រើកម្រងសំណួរជាទម្រង់សំណួរបើកក្នុងការប្រមូលទិន្នន័យដើម្បីស្វែងរកកត្តាដែលនាំឱ្យសិស្សរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ។ ក្នុងនោះអ្នកចូលរួមផ្តល់សម្ភាសមានដូចជា នាយក នាយករង ចំនួន០២នាក់ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ ចំនួន ០៦នាក់ សិស្សចំនួន១៤នាក់ និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សរៀនយឺតមុខវិទ្យាសាស្ត្រចំនួន០៥ នាក់។ តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា បញ្ហាសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រគឺកត្តាសិស្សខ្លួនឯង កត្តាគ្រួសារ និងកត្តាគ្រូបង្រៀន។ ដូចនេះ ដើម្បីឱ្យសិស្សថ្នាក់ទី១០ ដែលរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យ ហ៊ុន សែន ប្រសូតិ ខេត្តស្វាយរៀងទទួលបានលទ្ធផលសិក្សាល្អនិងទទួលបានគុណភាពអប់រំពេញលេញ អ្នកពាក់ព័ន្ធគួរតែយកចិត្តទុកដាក់ និងសហការផ្តល់ព័ត៌មានគ្នាទៅវិញទៅមកនិងតាមដានការសិក្សារបស់សិស្សឱ្យបានទៀងទាត់។ ក្នុងនោះ សិស្សខ្លួនឯងត្រូវយកចិត្តទុកដាក់ការសិក្សានិងខិតខំរៀនសូត្រដោយធ្វើកិច្ចការផ្ទះ ស្វ័យសិក្សាបន្ថែមនិងបង្កើន

សកម្មភាពនៅក្នុងថ្នាក់រៀន។ ចំណែកគ្រូបង្រៀនគួរតែកែលម្អវិធីសាស្ត្របង្រៀន តាមដានការសិក្សារបស់សិស្សជួយសិស្សដែលរៀនយឺត លើកទឹកចិត្ត បណ្តុះភាពក្លាហានដល់សិស្ស និងពន្យល់សិស្សពីសារប្រយោជន៍នៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ។ បន្ថែមលើនេះ គ្រូបង្រៀនគួរតែបង្កើនការសហការ និងចែករំលែកព័ត៌មានពីលទ្ធផលសិក្សាសិស្សជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស។ ចំណែកឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្សគួរតែតាមដានការសិក្សារបស់កូនទាំងនៅសាលារៀននិងនៅផ្ទះជាប្រចាំ ព្រមទាំងចូលរួមផ្តល់ព័ត៌មានដល់គ្រូបន្ទុកថ្នាក់ ឬនាយកសាលា ដើម្បីធានាថា កូនៗមានទាំងចំណេះដឹង និងសមត្ថភាព ព្រមទាំងទទួលបានការអប់រំពេញលេញ។

**អាគតដ្ឋាន:** សូរ, ម., គុជ, ស., &គឹម, ម. (២០២២). កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី១០ រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ?. *កាលិកបត្រអប់រំកម្ពុជា,* ៥(១),៣៦-៤៦។

## ១. សេចក្តីផ្តើម

ដោយមើលឃើញថា នៅលើពិភពលោកក៏ដូចជាប្រទេសនៅក្នុងតំបន់មានការយកចិត្តទុកដាក់ខ្ពស់ក្នុងវិស័យអប់រំ ដែលជាវិស័យសំខាន់មួយក្នុងការជំរុញឱ្យប្រទេសជាតិមានការរីកចម្រើនឆាប់រហ័ស ប្រទេសកម្ពុជាក៏បានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងឆ្នាំ២០១៥ និងការអនុវត្តក្នុងការធ្វើមូលដ្ឋាននីយកម្មដើម្បីឆ្លើយតបទៅនឹងស្ថានភាពនិងតម្រូវការជាក់ស្តែងរបស់ប្រទេស។

ទាក់ទងទៅនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលក្នុងនោះការអភិវឌ្ឍធនធានមនុស្សជាកត្តាអាទិភាពទី១ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ស្តីពី «ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា»។ ដោយផ្តោតអាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។ ដំណាក់កាលបន្ទាប់២០១៩-២០២៣ និងឆ្ពោះទៅឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡាប្តេជ្ញាសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០៣០ស្តីពី ការអប់រំដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ម្យ៉ាងទៀត ក្រសួងបន្តកាត់បន្ថយគម្លាតជំនាញដោយសហការជាមួយអ្នកពាក់ព័ន្ធក្នុងការបង្កើនការផ្គត់ផ្គង់ជំនាញដែលមានតម្រូវការខ្ពស់

ក្នុងវិស័យអាទិភាពមួយចំនួនដោយដាក់ចេញនូវការអប់រំតាមបែបឌីជីថល ដើម្បីឆ្លើយតបនឹងគោលនយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

ម្យ៉ាងវិញទៀតដើម្បីឆ្លើយតបទៅនឹងអនុវិស័យការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស ដែលបានលើកទឹកចិត្តឱ្យគ្រូខំបង្រៀន សិស្សខំប្រឹងរៀន ឪពុកម្តាយជួយគាំទ្រ និងអាជ្ញាធរគ្រប់កម្រិតចូលរួមក្នុងការកែលម្អគុណភាពអប់រំនៅកម្រិតមធ្យមសិក្សាក្នុងរយៈពេល៥ឆ្នាំកន្លងមក ក្រសួងក៏បានយកចិត្តទុកដាក់ដល់ការបង្កើនការចូលរៀនដោយសមធម៌ក្នុងការចូលរៀនកម្រិតមធ្យមសិក្សា និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងការផ្តល់ប្រឹក្សាអាជីព ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា។ ជាលទ្ធផលការចូលរៀនមានការកើនឡើង សិស្សក្រីក្របានទទួលអាហារូបករណ៍តាំងពីថ្នាក់ទី៧ និងបន្តការសិក្សារហូតដល់ទី១២ ហើយអត្រាការបោះបង់ការសិក្សាបានថយចុះ។ ក្រសួងបានធ្វើតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ សិស្សថ្នាក់ទី៨លើមុខវិជ្ជា ភាសាខ្មែរ គណិត និងរូបវិទ្យា និងបានចូលរួមកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដោយលទ្ធផលបង្ហាញថា សិស្សកម្ពុជាអាយុ១៥ឆ្នាំមានសមត្ថភាពអំណានទាបជាង មធ្យមភាគនៃប្រទេសកំពុងអភិវឌ្ឍជាសមាជិកទាំង៩ប្រទេស ប៉ុន្តែលទ្ធផលលើសកម្រិតនៃប្រទេសនៅទ្វីបអាហ្វ្រិកដែលសមត្ថភាពខាងផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យាស្មើនឹងមធ្យមភាគ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ជាមួយគ្នានោះ ក្នុងអនុវិស័យការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេសនេះដែរ ក្រសួងបានផ្តោតការយកចិត្តទុកដាក់លើកិច្ចការចម្បងគឺ ១) ការគ្រប់គ្រងសាលារៀនផ្តោតការបង្រៀនលើវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា ២) សាលារៀនជំនាន់ថ្មី ៣) បំណិនការងារនៅសាលាមធ្យមសិក្សា និង ៤) ភាសាអង់គ្លេសនិងភាសាបរទេសផ្សេងៗទៀត តាមតម្រូវការនូវមូលដ្ឋាន សាលារៀនរួមជាមួយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០០៨ ក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំស្តីពី ការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅមធ្យមសិក្សាទុតិយភូមិដោយបានរៀបចំការបែងចែកបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ការរៀបចំការបែងចែកនេះមានគោលដៅឱ្យសិស្សបន្តការសិក្សានៅឧត្តមសិក្សាលើមុខជំនាញដែលទាក់ទងនឹងស្នែម ឱ្យស្របទៅតាមសមត្ថភាព ចំណង់ចំណូលចិត្តរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក៏ដូចជាស្របទៅនឹងទីផ្សារការងារ។ បន្ថែមលើនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាមានគោលបំណងចង់បានធនធានសិស្ស ដែលមានសមត្ថភាពខាងផ្នែកវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមពិតប្រាកដ។ ក៏ប៉ុន្តែបន្ទាប់ពីមានការបែងចែកថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមរួចមក យើងសង្កេតឃើញថា អត្រាសិស្សចុះឈ្មោះចូលរៀនថ្នាក់វិទ្យាសាស្ត្រ តិចជាងថ្នាក់វិទ្យា

សាស្ត្រសង្គម។ ជាការកត់សម្គាល់ទាំងចំណេះដឹង និងសមត្ថភាពសិស្សលើមុខវិជ្ជាវិទ្យាសាស្ត្រនៅមានកម្រិតទាបជាហេតុធ្វើឱ្យពួកគាត់មិនជ្រើសរើសរៀននៅថ្នាក់វិទ្យាសាស្ត្រ។ ជាក់ស្តែង ក្នុងឆ្នាំ២០២០ អត្រាសិស្សចុះឈ្មោះចូលរៀនថ្នាក់វិទ្យាសាស្ត្រមានត្រឹមតែ ៣៨,៦០ភាគរយ (MoEYS, 2020a) នៅក្នុងបរិការណ៍សង្គមដែលមានតម្រូវការធនធានមនុស្សដែលមានសមត្ថភាព និងចំណេះដឹងផ្នែកវិទ្យាសាស្ត្រស្របទៅនឹងទីផ្សារការងារបែបនេះហើយ ទើបក្រុមការងារស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ «**កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី១០ រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ**»។ ការជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីរកឱ្យឃើញពីបញ្ហាប្រឈមនានា កើតមានចំពោះសិស្សថ្នាក់ទី១០ដែលរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រនិងជួយបង្កើនលទ្ធផលសិក្សាក៏ដូចជា សមត្ថភាព និងគុណភាពការសិក្សារបស់សិស្ស និងកែលម្អការបង្រៀនរបស់គ្រូ ដើម្បីឱ្យសិស្សទទួលបាននូវការអប់រំពេញលេញ បន្ទាប់ពីលទ្ធផលនៃការស្រាវជ្រាវត្រូវបានផ្សព្វផ្សាយ។

ជាមួយគ្នានេះ ដើម្បីរកឱ្យឃើញនូវបញ្ហាប្រឈមនានាដែលជាកត្តាជះឥទ្ធិពលដល់ការរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្ររបស់សិស្សថ្នាក់ទី១០ ក្រុមអ្នកស្រាវជ្រាវបានបង្កើតសំណួរស្រាវជ្រាវ និងសំណួរគន្លឹះមួយចំនួន។

**សំណួរស្រាវជ្រាវ៖** តើមានកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់សិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ?

## ២. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីឱ្យការស្រាវជ្រាវលើប្រធានបទខាងលើមានប្រសិទ្ធភាព ក្រុមអ្នកស្រាវជ្រាវបានប្រជុំគ្នាប្រមូលបញ្ហាប្រឈមសំខាន់ៗ និងបានឯកភាពជ្រើសរើសយកបញ្ហាដែលអាទិភាពមួយមកធ្វើជាប្រធានបទស្រាវជ្រាវ។ ក្រោយពីជ្រើសរើសបានប្រធានបទ ហើយក្រុមអ្នកស្រាវជ្រាវបានកំណត់អ្នកពាក់ព័ន្ធរួចបង្កើតកម្រងសំណួរជាទម្រង់សំណួរបើក ស្របតាមភាគីពាក់ព័ន្ធដែលបានកំណត់ដើម្បីប្រមូលទិន្នន័យ។ ក្នុងការចុះប្រមូលទិន្នន័យនេះក្រុមអ្នកស្រាវជ្រាវ បានរៀបចំកាលវិភាគច្បាស់លាស់ ដូចជាការកំណត់ពេលវេលា ទីតាំង និងសមាសភាពដែលត្រូវសម្ភាស ដោយមានការទាក់ទងទៅអាជ្ញាធរនិងមន្ត្រីគ្រប់គ្រងតាមឋានានុក្រមដើម្បីផ្តល់ព័ត៌មាននិងសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ក៏ដូចជាបង្កលក្ខណៈឱ្យអ្នកពាក់ព័ន្ធបានត្រៀមខ្លួនទុកជាមុន។ ភ្ជាប់ជាមួយដំណើរការចុះធ្វើសម្ភាសក្រុមអ្នកស្រាវជ្រាវបានរៀបចំជាកិច្ចព្រមព្រៀង សម្រាប់គ្រប់សមាសភាពចូលរួមបានពិនិត្យនិងយល់ព្រម ដោយមានការស្ម័គ្រចិត្ត ព្រមទាំងចុះហត្ថលេខាទទួលស្គាល់លើកិច្ចព្រមព្រៀងដែលគាត់បានពិនិត្យរួចទៀតផង។

ចំពោះគ្រប់ភាគីចូលរួមក្នុងបទសម្ភាសមានភាពរួសរាយរាក់ទាក់ មានការពេញចិត្ត និងមានភាពក្លាហាន ហ៊ានបញ្ចេញមតិតាមកម្រងសំណួរ ដែលក្រុមការងារបានរៀបចំដោយមិនស្ទាក់ស្ទើរ ឬភ័យខ្លាចនោះឡើយ ដែលនេះជាហេតុធ្វើឱ្យដំណើរការសម្ភាសប្រព្រឹត្តទៅដោយរលូននិងទទួលបានទិន្នន័យគ្រប់គ្រាន់តាមអ្វីដែលក្រុមអ្នកស្រាវជ្រាវរំពឹងទុក។

ទាក់ទងទៅនឹងដំណើរការប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវបានចុះប្រមូលទិន្នន័យដោយកំណត់អ្នកចូលរួមដោយឡែក ហើយបែងចែកសមាជិកសម្ភាសតាមអ្នកពាក់ព័ន្ធ។ ជាងនេះទៅទៀត ក្នុងករណីទិន្នន័យដែលក្រុមស្រាវជ្រាវទទួលបានមិនសូវមានភាពច្បាស់លាស់ ឬត្រូវការព័ត៌មានបន្ថែម ក្រុមអ្នកស្រាវជ្រាវក៏បានទាក់ទងទៅក្រុមគោលដៅតាមរយៈតេឡេក្រាមឬទូរស័ព្ទទាក់ទងដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់។ រីឯអ្នកចូលរួមដែលត្រូវសម្ភាស ក្រុមអ្នកស្រាវជ្រាវបានកំណត់យក នាយក នាយករង ០២នាក់ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ ចំនួន០៦នាក់ ឪពុកម្ដាយឬអាណាព្យាបាលសិស្សរៀនយឺតមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ ចំនួន០៥នាក់និងសិស្សរៀនយឺតមុខវិជ្ជាវិទ្យាសាស្ត្រថ្នាក់ទី១០ចំនួន១៤នាក់។ ចំពោះសមាសភាគចូលរួមទាំងអស់ស្រីមានចំនួន៣០នាក់។ ការជ្រើសរើសអ្នកចូលរួមសម្ភាសបែបនេះ ក្រុមអ្នកស្រាវជ្រាវរំពឹងថា បានទទួលលទ្ធផលគួរឱ្យជឿជាក់ហើយនឹងអាចទុកចិត្តបាន។ ក្នុងដំណើរការនៃការសម្ភាសគឺប្រព្រឹត្តទៅដោយរលូន បើទោះបីជាមានបញ្ហាតិចតួច ក៏ពុំមែនជាឧបសគ្គរាំងស្ទះដល់ដំណើរកាស្រាវជ្រាវទេ។ ក្នុងពេលចុះសម្ភាសក្រុមការងារបានសុំអនុញ្ញាតថតសំឡេង ថតរូបពីភាគីដែលត្រូវសម្ភាស និងកត់ត្រាចំណុចគន្លឹះ និងគំនិតសំខាន់សម្រាប់យកមកបញ្ចូលទិន្នន័យ។ បន្ទាប់មកក្រុមអ្នកស្រាវជ្រាវ បានបំពេញទម្រង់គំរូតាមលំដាប់លំដោយនៃកម្រងសំណួរ ដោយជ្រើសរើសយកគំនិតសំខាន់ៗ រួចធ្វើចំណាត់ថ្នាក់តាមក្រុមនៃគំនិតសំខាន់ៗទាំងនោះដាក់ក្នុងតារាងតាមលេខរៀងនៃអ្នកចូលរួមម្ដងមួយៗតាមលំដាប់លំដោយដើម្បីធ្វើការវិភាគនិងបកស្រាយទិន្នន័យដោយគោរពក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣. លទ្ធផល និងការពិភាក្សា

យោងតាមលទ្ធផលនៃការសម្ភាសនាយក នាយករង គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ សិស្ស ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសិស្សរួចមក ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា កត្តាជះឥទ្ធិពលលើការរៀនយឺតរបស់សិស្សថ្នាក់ទី១០លើមុខវិជ្ជាវិទ្យាសាស្ត្រគឺបណ្ដាលមកពីកត្តាសិស្ស កត្តាគ្រូបង្រៀន និងកត្តាឪពុកម្ដាយ ឬអាណាព្យាបាល។

## ៣.១ កត្តាសិស្ស

ការស្រាវជ្រាវពីមុនមករកឃើញដូចការស្រាវជ្រាវនេះដែរថា កត្តាសិស្សរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្របណ្ដាលមកពីសកម្មភាព ស្មារតី ឥរិយាបថ សមត្ថភាព ភាពអំណត់ ចំណង់ចំណូលចិត្ត និងការខិតខំប្រឹងប្រែងរបស់ពួកគេផ្ទាល់ (នាយកដ្ឋានគោលនយោបាយ,២០២១)។ ជាការពិតមានតែខ្លួនឯងទេដែលអាចកំណត់ជោគវាសនា និងភាពជោគជ័យរបស់ខ្លួនបាន មុននឹងអ្នកដទៃជួយអន្តរាគមន៍។ ជាក់ស្តែងតាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា សិស្សរៀនយឺតគឺបណ្ដាលមកពីកត្តាផ្ទាល់ខ្លួនជាច្រើនក្នុងនោះសិស្សមួយចំនួនតូចបានលើកឡើងថា «ខ្ញុំមិនចូលចិត្តរៀនមុខវិជ្ជាវិទ្យាសាស្ត្រ ព្រោះថាមុខវិជ្ជានេះពិបាករៀន មានរូបមន្តច្រើន ទន្ទេញមិនចាំ ពិបាកយល់បាតុភូត មានការពិសោធច្រើន និងលេខច្រើនខ្វង់ពិបាកក្នុងការគណនា»។ ពួកគេភាគច្រើនបន្ថែមថា «ពេលមានចម្ងល់ ពួកគេមិនហ៊ានសួរគ្រូឡើយ ព្រោះខ្លាចខ្មាស់គេ ខ្លាចគ្រូ មិនហ៊ានប្រឈមមុខជាមួយគ្រូ»។ ដូចគ្នាដែរ គ្រូបង្រៀនភាគច្រើន និងនាយក នាយករងទាំងពីរបានអះអាងថា«សិស្សមិនបានស្រាវជ្រាវបន្ថែមឡើយចំពោះមេរៀនដែលគាត់បានរៀនពីគ្រូនៅសាលាក៏ដូចជា មេរៀនដែលនឹងត្រូវរៀននៅថ្ងៃបន្ទាប់ ពួកគាត់ក៏មិនធ្វើកិច្ចការផ្ទះ មិនស្វ័យសិក្សា ឬស្រាវជ្រាវបន្ថែមឡើយ»។ ពួកគាត់បានបន្ថែមទៀតថា ភាពមិនក្លាហាន មិនសកម្មរបស់សិស្សក្នុងម៉ោងរៀនក៏ជាកត្តារួមចំណែកដល់ការរៀនយឺតរបស់សិស្សដែរ។ ដោយឡែក បើតាមការសាកសួរគ្រូបង្រៀនម្នាក់បានឱ្យដឹងថា ចំពោះការប្រើប្រាស់ទូរស័ព្ទស្មាតហ្វូនមិនបានត្រឹមត្រូវគឺមិនបម្រើដល់ការសិក្សារៀនសូត្រ ដូចជាការលេងហ្គេម មើលរឿងផ្សេងៗដែលជាបច្ច័យមួយធ្វើឱ្យសិស្សងប់ងល់លែងចង់រៀនសូត្រ ព្រោះវាធ្វើប៉ះពាល់ដល់សតិបញ្ញាស្មារតី (មួម៉ៅ ឆេវឆាវ អារម្មណ៍មិននឹងនរ និងខ្សោយទំនាក់ទំនង) សុខភាព និងខាតបង់ថវិកា។ ប្រការទាំងអស់នេះជាដើមចមធ្វើឱ្យសិស្សខាតពេលវេលាក្នុងការរៀនសូត្រ មិនបានរៀបកាលវិភាគឱ្យបានច្បាស់លាស់ដើម្បីរៀនខ្លួនឯងនៅផ្ទះគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ ឬរំឭកមេរៀនឡើងវិញ។ ស្របនឹងបញ្ហាខាងលើនេះលោកនាយកបានលើកឡើងថា «សិស្សវក់លេងទូរស័ព្ទ ភាគច្រើនភ្លេចបាយ ភ្លេចទឹក ភ្លេចការសិក្សារៀនសូត្រ»។ បន្ថែមលើនេះគ្រូបង្រៀនម្នាក់បានអះអាងថា កត្តាសេនេទិច ឬដុងពីកំណើត ក៏ជាចំណែកមួយធ្វើឱ្យសិស្សចូលចិត្ត ឬមិនចូលចិត្តការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រដែលចូលរួមចំណែកដល់ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ ដោយហេតុថា ខួរក្បាលរបស់ពួកគាត់ខ្សោយ ពិបាកចាប់បាននូវបញ្ញត្តិនិងសញ្ញាណក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះនៃការសិក្សានិងខ្លឹមសារមេរៀនទាំងមូល។ ជាក់ស្តែង លោកគ្រូមួយចំនួនតូចបានលើកឡើងពីបញ្ហានេះថា «សិស្សគាត់មួយចំនួនខ្សោយពីកំណើត ទោះបីខំរៀនយ៉ាងណាក៏មិនយល់ មិនចេះ មិនចាំដែរ»។ មួយវិញទៀត ការសេពគប់មិត្ត

ភក្តិមិនល្អ មិនចូលចិត្តរៀន ក៏ជាជ្រុងមួយដែលបានរួមចំណែកទាក់ទាញឱ្យសិស្សងាកចេញពីការសិក្សាផងដែរ។ គ្រូមួយចំនួនទៀតបានលើកឡើងថា «សិស្សមួយចំនួនមិនខិតខំរៀនសូត្រ ដោយមានមិត្តភក្តិអូសទាញឱ្យទៅលេងហ្គេមជាក្រុម លេងបាល់ខុសពេលវេលា និងដើរលេងមិនចូលរៀន»។

សរុបមក ក្រុមអ្នកស្រាវជ្រាវរកឃើញថា ការមិនចូលចិត្តរៀនមុខវិជ្ជាវិទ្យាសាស្ត្រមិនយកចិត្តទុកដាក់ក្នុងការសិក្សាក្នុងថ្នាក់ មិនធ្វើកិច្ចការផ្ទះ មិនស្រាវជ្រាវ មិនស្វ័យសិក្សា មិនរៀបចំផែនការរៀនខ្លួនឯង មិនមានភាពក្លាហាន លេងទូរស័ព្ទច្រើនរបស់សិស្សគឺជាកត្តាផ្ទាល់ខ្លួនដែលធ្វើឱ្យសិស្សរៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ។

### ៣.២ កត្តាគ្រូបង្រៀន

គ្រូបង្រៀនគឺជាតួអង្គដ៏សំខាន់បំផុតក្នុងការដឹកនាំការបង្រៀននិងរៀន ព្រមទាំងលើកទឹកចិត្តនិងផ្តល់ការអប់រំប្រកបដោយគុណភាពដល់សិស្ស ជាពិសេសលើការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា ការរៀនយឺតរបស់សិស្សលើមុខវិជ្ជាវិទ្យាសាស្ត្រគឺមកពីកង្វះខាតវិធីសាស្ត្របង្រៀននិងរៀន មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថ្នាក់រៀន មិនយកចិត្តទុកដាក់ចំពោះសិស្ស មិនចូលរួមក្នុងការប្រជុំបច្ចេកទេសទៀងទាត់ និងកង្វះទំនាក់ទំនងជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលសិស្ស។ តាមការសម្ភាសសិស្សមួយចំនួនតូចបានលើកឡើងថា «គ្រូរបស់ពួកគេពន្យល់មិនបានគ្រប់ជ្រុងជ្រោយ បង្រៀនលឿនពេក(បង្រៀនឱ្យតែទាន់កម្មវិធី)ពន្យល់មិនសូវច្បាស់ បង្រៀនតាមតែអ្នកចេះ»។ បន្ថែមពីលើនេះទៀត ពួកគេបានអះអាងថា គ្រូបង្រៀន មិនមានវិធីសាស្ត្របង្រៀនសម្បូរបែប មិនប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀន ដោយសារជួនកាលសម្ភារៈទំនើបពេកពួកគាត់មិនចេះប្រើប្រាស់។ បន្ថែមលើនេះទៀត គណៈគ្រប់គ្រងសាលារៀនម្នាក់បានឱ្យដឹងថា «គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនបង្រៀនមិនអស់ពីសមត្ថភាព លាក់ទុកបង្រៀនគួរក្រៅម៉ោងបង្រៀនមិនអនុវត្តតាមជំហានទាំង៥នៃកិច្ចតែងការដោយកំណត់វត្ថុបំណងមិនបានច្បាស់លាស់ មិនចេះបង្កើតបញ្ញត្តិ មិនមានគំនិតនវានុវត្តន៍ និងគ្រប់គ្រងថ្នាក់មិនបានល្អ បណ្តោយឱ្យសិស្សមានភាពរញ៉េរញ៉ៃជាដើម»។ ជាងនេះទៅទៀត គាត់បានបន្ថែមថា ការមិនគោរពម៉ោងការងាររបស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ក៏ជាផ្នែកមួយប៉ះពាល់ដល់ការសិក្សារបស់សិស្សដែរដែលមានន័យថា បើគ្រូមកបង្រៀនយឺត នោះការបង្រៀនរបស់គាត់ប្រាកដជាមិនបានគោរពទៅតាមជំហានទាំង៥នៃកិច្ចតែងការឡើយ ហើយគ្រូបង្រៀនអាចរំលងជំហានណាមួយ ព្រោះពេលវេលាមិនគ្រប់គ្រាន់ ហើយសិស្សក៏មិនអាចទទួលបានចំណេះដឹងពេញលេញដែរក្នុងម៉ោងសិក្សានោះ។ ពិសេសជាងនេះទៀត គ្រូបង្រៀនដែលមិនបានចូលរួមប្រជុំក្រុមបច្ចេកទេសឱ្យបានទៀងទាត់ ក៏ធ្វើឱ្យពួកគាត់មិនបានទទួលនូវបទពិសោធ

ចំណេះដឹងថ្មីក្នុងការបង្រៀន និងការដោះស្រាយបញ្ហាប្រឈមដែលកើតឡើងនៅពេលបង្រៀនជាក់ស្តែងផងដែរ។ រីឯការមិនបានចូលរួមប្រជុំប្រចាំខែ ធ្វើឱ្យគ្រូបង្រៀនមិនបានទទួលនូវព័ត៌មានថ្មីៗទាក់ទងនឹងបច្ចេកទេសក្នុងការបង្រៀននិងរៀន។ ក្រៅពីនេះ គាត់បានបញ្ជាក់ថា គ្រូបង្រៀនមិនបានបង្ហាញពីសារប្រយោជន៍នៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រដល់សិស្ស ក៏ជាកត្តាលីករមួយធ្វើឱ្យសិស្សមិនចាប់អារម្មណ៍ និងមិនដឹងពីអត្ថប្រយោជន៍លើការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ ស្របតាមតម្រូវការ និងទីផ្សារការងាររបស់សង្គមឡើយ។ ត្រង់ចំណុចនេះ នាយកសាលាបានលើកឡើងថា «គ្រូមិនបានបង្ហាញពីគុណសម្បត្តិនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រឱ្យសិស្សបានដឹង និងមិនបានលើកទឹកចិត្តសិស្សឱ្យជ្រើសរើសមុខវិជ្ជាវិទ្យាសាស្ត្រនៅថ្នាក់វិទ្យាល័យ រួចបន្តចាប់យកមុខវិជ្ជាវិទ្យាសាស្ត្រ ក៏ដូចជាមុខវិជ្ជាស្នេមនៅថ្នាក់មហាវិទ្យាល័យ»។ គាត់បានបន្ថែមទៀតថា ចំពោះគ្រូបង្រៀនដែលមិនបានយកចិត្តទុកដាក់សិក្សាស្រាវជ្រាវបន្ថែមពីវិធីសាស្ត្របង្រៀនថ្មីៗ និងចំណេះដឹងឯកទេសរបស់ខ្លួន ក៏ជាគុណវិបត្តិមួយដែលធ្វើឱ្យការផ្ទេរចំណេះដឹងទៅសិស្សមិនបានទូលំទូលាយ ដែលធ្វើឱ្យសិស្សទទួលបានចំណេះដឹងមិនច្បាស់លាស់ អនុវត្តលំហាត់មិនបានត្រឹមត្រូវរហូតធ្វើឱ្យពួកគេរៀនយឺត។ ក្នុងគោលគំនិតនេះ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនភាគច្រើនបានអះអាងថា «លោកគ្រូ អ្នកគ្រូមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនបង្រៀនតែតាមសៀវភៅសិក្សាគោល គម្ពីរនិយម មិនមានគំនិតច្នៃប្រឌិតបង្កើតលំហាត់អនុវត្តថ្មីៗ មិនសិក្សាស្រាវជ្រាវពីបច្ចេកវិទ្យាថ្មីៗ មិនសិក្សាភាសាបរទេសបន្ថែមដើម្បីពង្រឹងដល់ការបង្រៀននិងរៀនក្នុងយុគសម័យឌីជីថល»។ ម្យ៉ាងវិញទៀត គ្រូបង្រៀនដែលមិនបានផ្តល់ព័ត៌មានអំពីលទ្ធសិក្សារបស់សិស្សទៅអាណាព្យាបាលបានទៀងទាត់តាមខែនីមួយៗ (មិនបានផ្ញើសៀវភៅតាមដាន) ក៏ជាចំណែកមួយធ្វើឱ្យអាណាព្យាបាល មិនបានទទួលព័ត៌មានពិតពីការសិក្សារបស់កូន ដែលជាហេតុធ្វើឱ្យគាត់មិនបានដឹងថា កូនរបស់ខ្លួនរៀនយឺតលើមុខវិជ្ជាណាខ្លះនោះទេ ហើយក៏មិនបានជួយជំរុញលើកទឹកចិត្តកូនឱ្យសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះចំពោះមុខវិជ្ជាដែលពួកគេរៀនយឺត។ ជុំវិញបញ្ហាទាំងនេះ អាណាព្យាបាលមួយចំនួនលើកឡើងថា « ពួកគាត់មិនបានទទួលសៀវភៅតាមដានការសិក្សារបស់កូនគាត់ឡើយ ហើយមិនបានដឹងថា គ្រូបង្រៀនមិនបានចែកឱ្យ ឬចែកឱ្យហើយ ប៉ុន្តែកូនរបស់ពួកគាត់មិនបានបង្ហាញសៀវភៅតាមដានដល់ពួកគាត់»។

សរុបមក គ្រូបង្រៀនជាតួអង្គដ៏សំខាន់ក្នុងការបង្រៀននិងរៀន ហើយបើពួកគាត់មិនគោរពនិយតភាពការងារ មិនមានវិធីសាស្ត្របង្រៀនល្អៗសម្បូរបែប មិនសិក្សាស្រាវជ្រាវបន្ថែមលើមុខវិជ្ជាឯកទេសនិងបច្ចេកវិទ្យាថ្មីៗ បង្រៀនមិនគោរពទៅតាមជំហានទាំង៥នៃកិច្ចតែងការបង្រៀន និងមិនផ្តល់

ព័ត៌មានអំពីការសិក្សារបស់សិស្សដល់អាណាព្យាបាលទេ គឺជាដើមហេតុដ៏ចម្បងបំផុតដែលជះឥទ្ធិពលដល់ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្ររបស់សិស្ស។

**៣.៣ កត្តាគ្រួសារ៖** គ្រួសារគឺជាកម្លាំងចលករមួយដ៏សំខាន់ផងដែរ ក្នុងការចូលរួមជួយសិស្សឱ្យទទួលបានជោគជ័យក្នុងការសិក្សា ដោយពួកគាត់ជាអ្នកចាំជួយលើកទឹកចិត្ត ផ្គត់ផ្គង់ទាំងផ្នែកសម្ភារៈ និងស្មារតីជាអ្នកតាមដាន ជូនដំណឹងឬផ្តល់ព័ត៌ត្រឡប់មកសាលាវិញអំពីការសិក្សារបស់កូន។ ជាតឹកតាងលទ្ធស្រាវជ្រាវបានបង្ហាញថា អាណាព្យាបាលមិនបានយកចិត្តទុកដាក់តាមដានការសិក្សារបស់កូនឱ្យគ្រប់ជ្រុងជ្រោយទេ ដោយសារពួកគាត់មមាញឹកច្រើននឹងរបរចិញ្ចឹមជីវិត។ ត្រង់ចំណុចនេះមានអាណាព្យាបាលភាគតិចបានលើកឡើងថា «ពួកគាត់មិនដែលបានសាកសួរព័ត៌មានអំពីការសិក្សារបស់កូនឬពេលគ្រូផ្ញើសៀវភៅតាមដានការសិក្សា ពួកគាត់មិនបានពិនិត្យមើលលើលទ្ធផលសិក្សារបស់កូនឡើយ(គ្រាន់តែចុះហត្ថលេខា ផ្តិតមេដៃទទួលតែប៉ុណ្ណោះ ត្រង់ការសិក្សាកូនយ៉ាងណា គឺពួកគាត់មិនបានដឹងនោះទេ)»។ អាណាព្យាបាលខ្លះទៀតបានលើកឡើងថា «ពួកគាត់មិនដែលបានជួយលើកទឹកចិត្តកូន ឬជំរុញកូនឱ្យខិតខំសិក្សារៀនសូត្រនោះទេ ដោយសារតែពួកគាត់មមាញឹកក្នុងការប្រកបរបររកស៊ីដើម្បីចិញ្ចឹមគ្រួសារចិញ្ចឹមកូនរៀន»។ បន្ថែមពីលើនេះទៀត បើជីវភាពគ្រួសាររបស់សិស្សមានភាពក្រីក្រក៏ជាបុព្វហេតុមួយដែលរាំងស្ទះដល់ការសិក្សារបស់កូនៗដែរ ព្រោះការសិក្សារៀនសូត្រត្រូវការថវិកាជាចាំបាច់សម្រាប់គាំទ្រក្នុងការសិក្សា(ទិញសម្លៀកបំពាក់ សម្ភារៈសិក្សា មធ្យោបាយធ្វើដំណើរការចាយប្រចាំថ្ងៃ និងតម្រូវការផ្សេងៗទៀតដែលចាំបាច់)។ សិស្សមួយចំនួនឆ្លៀតពេលធ្វើការងារផ្សេងៗដើម្បីរកកំរៃមកជួយផ្គត់ផ្គង់ជីវភាពគ្រួសារ (សិស្សខ្លះឆ្លៀតពេលទៅធ្វើសំណង់ ជួយលក់ឥវ៉ាន់គេ ឆ្លុះត្រី កាប់ដើមប្រចាក់យកមកបិតប្រេងគ្រាន់បានលុយមករៀន ឯសិស្សខ្លះទៀតគ្មានមធ្យោបាយធ្វើដំណើរ ត្រូវសុំគេជិះទៅជាមួយ។ បើគេមករៀនទើបបានមករៀនដែរ តែបើគេមិនមកទេ ក៏មិនបានមករៀនដែរ ហើយបើគេមករៀនយឺតពួកគាត់ក៏មកយឺតដែរ)។ គ្រូបង្រៀនមួយចំនួនតូចបានលើកឡើងថា «សិស្សខ្លះមិនមានពេលវេលារៀនគ្រប់គ្រាន់ទេ ព្រោះផ្ទះពួកគេនៅឆ្ងាយពីសាលារៀន ហើយមានជីវភាពអត្តខាត់ ខ្វះសព្វខ្វះគ្រប់»។

សរុបមកយើងឃើញថា អ្នកអាណាព្យាបាល ឬឪពុកម្តាយដែលមិនបានយកចិត្តទុកដាក់តាមដានការសិក្សារបស់កូន មិនជួយលើកទឹកចិត្ត ជំរុញកូនឱ្យខិតខំសិក្សារៀនសូត្រ និងគ្រួសារដែលមានជីវភាពក្រីក្រ ក៏ជាការរួមចំណែកធ្វើឱ្យការសិក្សារបស់កូន មានការធ្លាក់ចុះផងដែរ។

## ៤. ចំណុចខ្លាំង និងចំណុចខ្សោយ

ក្នុងដំណើរការនៃការស្រាវជ្រាវប្រធានបទស្ដីពី « កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី ១០ រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រ»ក្រុមអ្នកស្រាវជ្រាវបានរកឃើញពីចំណុចខ្លាំងនិងចំណុចខ្សោយដូចខាងក្រោម៖

**ក. ចំណុចខ្លាំង៖** ក្រុមអ្នកស្រាវជ្រាវមានការសហការ ស្រុះស្រួល រាក់ទាក់ ទំនាក់ទំនងគ្នាបានល្អ មានការសហការគ្នាល្អរវាងអ្នកស្រាវជ្រាវជាមួយនឹងភាគីពាក់ព័ន្ធ ផ្តល់ចម្លើយបានក្បោះក្បាយសហការដោយការពេញចិត្ត ផ្តល់ឱកាស និងពេលវេលាសមស្របរវាងអ្នកស្រាវជ្រាវជាមួយអ្នកត្រូវជួបសម្ភាសន៍ ដោយមានការសុំអនុញ្ញាត ការផ្តល់ការអនុញ្ញាតបានយ៉ាងត្រឹមស្របតាមរដ្ឋបាលការងារ។

**ខ. ចំណុចខ្សោយ៖** មិនបានសម្ភាសភាគីពាក់ព័ន្ធឱ្យបានច្រើន ដោយសារកត្តាពេលវេលាខ្លីមិនអាចប្រមូលទិន្នន័យបានច្រើន ហើយចំនួនអ្នកចូលរួមមានចំនួនតិច។

## ៥. សរុបសេចក្តី អនុសាសន៍

ជារួម កត្តាជះឥទ្ធិពលឱ្យសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រនៃវិទ្យាល័យ ហ៊ុន សែន ប្រសូតិគឺកត្តាសិស្ស កត្តាគ្រូបង្រៀន កត្តាគ្រួសារ។ ដូចនេះ ដើម្បីឱ្យសិស្សថ្នាក់ទី១០រៀនយឺតលើមុខវិជ្ជាវិទ្យាសាស្ត្រនៅវិទ្យាល័យ ហ៊ុន សែន ប្រសូតិទទួលបានលទ្ធផលការសិក្សាល្អនិងទទួលបានគុណភាពអប់រំពេញលេញភាគីពាក់ព័ន្ធគួរតែយកចិត្តទុកដាក់ សហការផ្តល់ព័ត៌មានដល់គ្នាទៅវិញទៅមកតាមដានការសិក្សាសិស្សឱ្យបានទៀងទាត់។ ក្នុងនោះ សិស្សត្រូវយកចិត្តទុកដាក់ការសិក្សា និងខិតខំរៀនសូត្រដោយធ្វើកិច្ចការផ្ទះ ស្វ័យសិក្សាបន្ថែម និងបង្កើនសកម្មភាពចូលរួមក្នុងថ្នាក់រៀន។

ចំណែកគ្រូបង្រៀនគួរតែកែលម្អវិធីសាស្ត្របង្រៀន តាមដានការសិក្សារបស់សិស្សជួយសិស្សដែលរៀនយឺត លើកទឹកចិត្ត បណ្តុះនូវភាពក្លាហានដល់សិស្ស និងពន្យល់សិស្សពីសារប្រយោជន៍នៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ។ បន្ថែមលើនេះ គ្រូបង្រៀនគួរតែបង្កើនការសហការនិងចែករំលែកព័ត៌មានពីគ្នាទៅវិញទៅមក និងលទ្ធផលសិក្សាសិស្សជាមួយឪពុកម្តាយសិស្ស។ ចំណែកឪពុកម្តាយសិស្សគួរតែតាមដានការសិក្សារបស់កូនទាំងនៅសាលារៀន និងនៅផ្ទះជាប្រចាំចូលរួមទទួលនិងផ្តល់ព័ត៌មានដល់គ្រូបន្ទុកថ្នាក់ ឬនាយកសាលាដើម្បីធានាថា កូនៗមានទាំងចំណេះដឹងនិងសមត្ថភាពព្រមទាំងទទួលបានការអប់រំពេញលេញ។

## ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣. ភ្នំពេញ ប្រទេសកម្ពុជា

នាយកដ្ឋានគោលនយោបាយ. (២០២១). កត្តាជិះឥទ្ធិពលលើការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងសង្គមនៅកម្រិតមធ្យមសិក្សាទុយតិយភូមិក្នុងប្រទេសកម្ពុជា. ភ្នំពេញ ប្រទេសកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). សេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាចំណោះទូទៅនៅមធ្យមសិក្សាទុតិយភូមិ. ភ្នំពេញ ប្រទេសកម្ពុជា

**ក្រសួងអប់រំ យុវជន និងកីឡា**

**នាយកដ្ឋានគោលនយោបាយ**

អត្ថបទស្រាវជ្រាវប្រតិបត្តិ

# មូលហេតុដែលនាំឱ្យសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម

ញ៉ែប សំណាង *[១] ផុន ស្រីណុម[២] និង ស្រី និង ឈូវ សុខេង[៣]

*វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារ

បានទទួល៖ ០១ មករា ២០២២ បោះពុម្ពផ្សាយ៖ ១៥ មិថុនា ២០២២

**សង្ខិត្តន័យ**

តាមទិដ្ឋភាពជាក់ស្តែងយើងសង្កេតឃើញថា វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារមានសិស្សចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួនច្រើនជាងសិស្សដែលរៀនថ្នាក់វិទ្យាសាស្ត្រ។ មូលហេតុនេះក្រុមស្រាវជ្រាវយើងខ្ញុំបានសិក្សាឈ្វេងយល់រកមូលហេតុមួយដែលអាចបណ្តាលមកពីទីតាំងសាលារៀន កត្តាសិស្ស កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន និងកត្តាសហគមន៍។ អ្នកចូលរួមសម្ភាសមានដូចជា នាយកសាលាចំនួន ០១នាក់ គ្រូបង្រៀនចំនួន០៦នាក់ អាណាព្យាបាលសិស្សចំនួន០៣នាក់ ឪពុកម្តាយសិស្សចំនួន៣នាក់ សិស្សានុសិស្សចំនួន១២នាក់។ លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថា សិស្សដែលមករៀនថ្នាក់សង្គមច្រើន ដោយសារលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ថ្នាក់សង្គមជាប់ច្រើនជាងថ្នាក់វិទ្យាសាស្ត្រ។

**អាគតដ្ឋាន:** ញ៉ែប ស,. ផុន, ស,. ស្រីឈូវ, ស. (២០២២). មូលហេតុដែលនាំឱ្យ សិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រតិចជាងវិទ្យាសាស្ត្រសង្គម. *កាលិកបត្រអប់រំកម្ពុជា,* ៥(១),៤៧-៦០។

## ១.សេចក្តីផ្តើម

ការអភិវឌ្ឍកម្មវិធីសិក្សាជាបញ្ហាមួយយ៉ាងសំខាន់នៅក្នុងសង្គមជាតិនីមួយៗដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ ផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ឆ្នាំ ២០១៨ របស់រាជរដ្ឋាភិបាលជាត្រីវិស័យមួយនៅក្នុងការកំណត់គោលដៅអប់រំជាតិ។ គោលនយោបាយសម្រាប់អនុវត្តកម្មវិធីសិក្សាចំណោះទូទៅមានរយៈពេល ១២ឆ្នាំ ឱ្យស្របទៅនឹងការរីកចម្រើននៃវិស័យសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ។ល។ យោងលិខិតលេខ៣៦៤៤ អយក អកស រាជធានីភ្នំពេញចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១១ ជម្រាបមកលោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត កម្មវត្ថុស្តីពី"ការអនុវត្តកម្មវិធីសិក្សាថ្មីចំណោះទូទៅថ្នាក់ទី១១ និងទី១២" ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តកម្មវិធីសិក្សាថ្នាក់វិទ្យាសាស្ត្រសង្គម និងថ្នាក់វិទ្យាសាស្ត្រ នៅកម្រិតវិទ្យាល័យចាប់ពីថ្នាក់ទី១១ និងថ្នាក់ទី១២។ ថ្នាក់វិទ្យាសាស្ត្រជាមុខវិជ្ជាដែលផ្តោតសំខាន់ទៅលើគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ឬមុខវិជ្ជាដែលពាក់ព័ន្ធខាងវិទ្យាសាស្ត្រ។ រីឯថ្នាក់វិទ្យាសាស្ត្រសង្គម ជាមុខវិជ្ជាដែលផ្តោតសំខាន់ទៅលើខាងមេរៀនដែលពាក់ព័ន្ធនិងមុខវិជ្ជាសង្គមដូចជា អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា ភូមិវិទ្យា ពលរដ្ឋវិជ្ជាជាដើម។

ក្នុងការសិក្សាពីមួយឆ្នាំទៅមួយឆ្នាំសិស្សានុសិស្សបានចាប់អារម្មណ៍ទៅលើថ្នាក់វិទ្យាសាស្ត្រសង្គមជាងថ្នាក់វិទ្យាសាស្ត្រដែលជាហេតុធ្វើឱ្យបរិមាណសិស្សរៀននៅថ្នាក់វិទ្យាសាស្ត្រមានការថយចុះជាពិសេសនៅកម្រិតសិក្សាថ្នាក់ទី១២។ រីឯលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក៏បានលទ្ធផលខុសគ្នាដែរ ដោយភាគរយថ្នាក់វិទ្យាសាស្ត្រសង្គមមានអត្រាខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រ។ បើផ្អែកតាមដ្យាក្រាមខាងក្រោម អត្រាប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៃសាលាធនធានទាំង៥០នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា២០២១-២០២២ នោះក៏បានបង្ហាញថា សន្ទុះភាគរយនៃថ្នាក់វិទ្យាសាស្ត្រសង្គម ជារួមនៅតែមានភាគរយខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រដដែល បើទោះបីមានខេត្តមួយចំនួនថ្នាក់វិទ្យាសាស្ត្រមានអត្រាភាគរយខ្ពស់យ៉ាងណាក៏ដោយ(**រូបទី១**)។

**តារាងដ្យាក្រាមទី១**



ការជ្រើសរើសថ្នាក់វិទ្យាសាស្រ្ត ឬថ្នាក់វិទ្យាសាស្រ្តសង្គមរបស់សិស្សបានក្លាយជាបណ្តុំនៃបញ្ហាមួយដែលមានការចាប់អារម្មណ៍និងត្រូវឈ្វេងយល់ពីដើមចម។ ជុំវិញបរិបទនេះ ទើបអ្នកស្រាវជ្រាវបានកំណត់ជាប្រធានបទស្តីពី **"មូលហេតុដែលនាំឱ្យសិស្សនៅវិទ្យាល័យចំណោះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្រ្តតិចជាងវិទ្យាសាស្រ្តសង្គម"**។ ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងឈ្វេងយល់ពីមូលហេតុចម្បងដែលជំរុញឱ្យសិស្សនៅវិទ្យាល័យចំណោះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារទៅជ្រើសរើសថ្នាក់វិទ្យាសាស្រ្តសង្គមច្រើនជាងថ្នាក់វិទ្យាសាស្រ្ត(**តារាងស្ថិតិទី១**)។

**តារាងទី១ ៖ ស្ថិតិសិស្សទី១២ តាមឆ្នាំសិក្សា**

| ឆ្នាំសិក្សា | វិទ្យាសាស្រ្ត | វិទ្យាសាស្រ្តសង្គម | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|
| 2016 - 2017 | 186 | 72 | 72.09 | |
| 2017 – 2018 | 76 | 229 | 29.91 | |
| 2018 – 2019 | 26 | 132 | 16.45 | |
| 2019 -2020 | 16 | 104 | 13.33 | |
| 2020 -2021 | 32 | 72 | 30.76 | |
| 2021 - 2022 | 13 | 75 | 14.77 | |

ជុំវិញបញ្ហានៃប្រធានបទនេះក្រុមអ្នកស្រាវជ្រាវបានលើកជាសំណួរគន្លឹះសំខាន់ៗដូចខាងក្រោម៖

**សំណួរស្រាវជ្រាវ៖**

ហេតុអ្វីបានជាសិស្សនៅវិទ្យាល័យចំណោះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្រ្តតិចជាងវិទ្យាសាស្រ្តសង្គម?

**សំណួរគន្លឹះ:**

១.តើសាលារៀនបានជះឥទ្ធិពលអ្វីខ្លះដល់ការសម្រេចចិត្តរបស់សិស្ស?

២.តើគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងសហគមន៍មានវិធីសាស្រ្តអ្វីខ្លះដើម្បីធ្វើឱ្យសិស្សចូលរៀនថ្នាក់វិទ្យាសាស្រ្តច្រើន?

៣.តើកត្តាសិស្សអ្វីខ្លះដែលនាំឱ្យសិស្សចូលរៀនថ្នាក់វិទ្យាសាស្រ្តសង្គមច្រើន ?

៤.តើកត្តាគ្រួសារបានជះឥទ្ធិពលអ្វីខ្លះដល់ការសម្រេចចិត្តរបស់កូនក្នុងការចូលរៀនថ្នាក់សង្គម?

## ២.វិធីសាស្ត្រស្រាវជ្រាវ

ការពិភាក្សាក្រុមគឺជាការប្តូរយោបល់គ្នាទៅវិញទៅមកទៅលើបញ្ហា ឬប្រធានបទណាមួយដើម្បីបានទិន្នន័យជាក់លាក់ដែលចង់បាន។ ដោយឡែកសម្រាប់ការសិក្សាស្រាវជ្រាវនេះគឺធ្វើឡើងតាមរយៈការសម្ភាសដើម្បីប្រមូលទិន្នន័យ។ ក្រុមអ្នកស្រាវជ្រាវបានរៀបចំធ្វើចំណាត់ថ្នាក់កម្រងសំណួរដែលបានមកពីការពិភាក្សាដើម្បីត្រៀមធ្វើការសម្ភាសជាមួយអ្នកពាក់ព័ន្ធ។ ក្នុងនោះដែរយើងខ្ញុំបានកំណត់ អ្នកដែលត្រូវណាត់ជួបសម្ភាសន៍ ដោយមានលិខិតជូនដំណឹងភ្ជាប់ជាមួយតារាងបញ្ជាក់ពីពេលវេលា និងទីកន្លែងនៃការជួបសម្ភាសន៍។ ក្នុងនោះដែរក្រុមអ្នកស្រាវជ្រាវបានរៀបចំកិច្ចព្រមព្រៀងគ្រប់សមាសភាពអ្នកចូលរួម ដោយមានការចុះហត្ថលេខាច្បាស់លាស់។ ជាមួយសកម្មភាពដែលក្រុមអ្នកស្រាវជ្រាវបានធ្វើដៃគូដែលបានចូលរួមសម្ភាសន៍បានសម្តែងអារម្មណ៍សាទរចំពោះសកម្មភាពនេះ ដោយមិនមានការស្ទាក់ស្ទើរ។

សិក្សាពីបញ្ហាណាមួយប្រកបដោយភាពជោគជ័យ អ្នកសិក្សាស្រាវជ្រាវត្រូវប្រមូលទិន្នន័យនៃបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាក់ស្តែង ដើម្បីសិក្សាប្រធានបទខាងលើឱ្យទទួលបានលទ្ធផលល្អ ក្រុមអ្នកស្រាវជ្រាវបានកំណត់ជ្រើសរើសបញ្ហាសំខាន់ៗទាំងឡាយ បន្ទាប់មកបានអនុវត្តពហុមតិយកបញ្ហាសំខាន់តែមួយ ដោយមានការឯកភាពពីសមាជិកក្នុងក្រុម។ នៅពេលកំណត់បានប្រធានបទក្រុមការងារបានប្រជុំកំណត់សមាសភាពអ្នកបានចូលរួមដើម្បីសហការគ្នាបង្កើតកម្រងសំណួរ និងរៀបចំបែងចែកសមាសភាពក្រុមសម្រាប់ប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងប្រធានបទ។

ខណៈពេលចុះប្រមូលទិន្នន័យ ក្រុមអ្នកស្រាវជ្រាវបានធ្វើការបែងចែកជាក្រុមសមាសភាពជាច់ៗដោយឡែក។ ពេលខ្លះក្នុងករណីចាំបាច់ដែលតម្រូវឱ្យក្រុមការងារបានប្រើទូរស័ព្ទនិងតេឡេក្រាមដើម្បីទាក់ទងពីចម្ងាយជាមួយអ្នកផ្តល់សម្ភាសន៍។ ចំពោះសមាសភាពដែលត្រូវសម្ភាសន៍រួមមាន សហគមន៍ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អាណាព្យាបាលសិស្ស និងសិស្សានុសិស្ស។ ក្នុងនោះអ្នកដែលពាក់ព័ន្ធទាំងអស់នេះក្រុមការងារយល់ថា សុទ្ធតែអ្នកដែលអាចផ្តល់ព័ត៌មានយ៉ាងពិស្តារជុំវិញប្រធានបទ ដែលអាចទទួលយកនិងគួរឱ្យមានទំនុកចិត្ត។ ដំណើរការសម្ភាសន៍ប្រព្រឹត្តទៅដោយរលូន តែទោះជាបែបណាក៏ដោយ ក៏នៅមានឧបសគ្គតិចតួចក្នុងដំណើរការស្រាវជ្រាវនេះ ពិសេសការប្រមូលព័ត៌មានតាមទូរស័ព្ទ ឬតេឡេក្រាម។ តែទោះជាយ៉ាងណាក្រុមអ្នកស្រាវជ្រាវនៅតែព្យាយាមស្តាប់ និងកត់ត្រាយ៉ាងយកចិត្តទុកដាក់នូវពាក្យគន្លឹះ សង្ខេបគំនិតសំខាន់ៗ។

បន្ទាប់មក ក្រុមអ្នកស្រាវជ្រាវបានរៀបចំបំពេញទម្រង់គំរូទៅតាមលំដាប់លំដោយនៃខ្លឹមសារដែលចង់បានដោយពិនិត្យរកគំនិតសំខាន់ៗ និងរៀបចំចំណាត់ថ្នាក់នៃប្រព័ន្ធគំនិតនោះ ដើម្បីសម្រេចវត្ថុបំណងរបស់ប្រធានបទខាងលើ។

## ៣. លទ្ធផល និងការពិភាក្សា

នៅក្នុងការជ្រើសរើសថ្នាក់សម្រាប់សិក្សាគឺទាក់ទងទៅនឹងការសម្រេចចិត្តរបស់សិស្សម្នាក់ៗ។ ជាដំបូងសិស្សត្រូវដឹងពីសមត្ថភាពរបស់ខ្លួនឱ្យច្បាស់ ជាពិសេសត្រូវដឹងជំនាញដែលខ្លួនចង់សិក្សានិងគោលដៅការងារទៅថ្ងៃអនាគតដែលខ្លួនចង់ធ្វើ ហើយត្រូវរៀនឱ្យត្រូវជំនាញ និងចំណង់ចំណូលចិត្តដោយគិតឱ្យបានល្អិតល្អន់ជាមុនសិន មុននឹងសម្រេចចិត្តចូលរៀនថ្នាក់ណាមួយ(វិទ្យាសាស្ត្រ ឬសង្គម) ព្រោះវាទាក់ទងទៅនឹងអនាគត។

ទាក់ទងទៅនឹងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមរបស់សិស្សនេះជាលទ្ធផលគឺយើងបានធ្វើការសម្ភាសន៍ ដើម្បីស្ទាបស្ទង់មតិយោបល់ជាច្រើន ដើម្បីប្រមូលបានជាតុចូលយកមកឆ្លុះបញ្ចាំងឱ្យឃើញពីកត្តាដែលជះឥទ្ធិពលលើការសម្រេចចិត្តរបស់សិស្ស ក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារ។ កត្តាខាងក្រោមជាយោបល់ដែលត្រូវបញ្ជាក់លំអិតអំពីអ្នកពាក់ព័ន្ធមួយចំនួននៅក្នុងការសិក្សារបស់សិស្សថ្នាក់ទី១២ ដែលជ្រើសរើសយកថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យសាស្ត្រ។

បន្ទាប់ពីបានធ្វើសកម្មភាពប្រមូលទិន្នន័យបានគ្រប់គ្រាន់ហើយគឺអាចផ្តល់នូវគំនិតដើម្បីឈានទៅរកការវិភាគបញ្ហានៃប្រធានបទខាងលើ។ ក្រុមការងារអាចដឹងពីមូលហេតុដែលសិស្សនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារចូលរៀនថ្នាក់វិទ្យាសាស្ត្រ តិចជាងវិទ្យាសាស្ត្រសង្គមគឺអាចបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

### ៣.១.កត្តាសាលារៀន

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសព្រះរាជសម្ភារមានចម្ងាយពីទីរួមខេត្តកំពត ប្រហែលជា៥គីឡូម៉ែត្រ ស្ថិតនៅភូមិអរតួច ឃុំអណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត។ សាលារៀនជាប្រភេទសាលាធនធានដែលមានអាគារសិក្សាចំនួន១៣អាគារ ស្មើនឹង៨៨បន្ទប់ រួមទាំងមានអាគារធនធានចំនួន០១ស្មើនឹង០៨បន្ទប់ក្នុងនោះមានបន្ទប់ពិសោធន៍ចំនួន០២។ បន្ទប់ពិសោធន៍ទី១ សម្រាប់មុខវិជ្ជាគីមីវិទ្យា និងជីវវិទ្យា។ បន្ទប់ពិសោធន៍ទី២ សម្រាប់មុខវិជ្ជារូបវិទ្យា និងផែនដីវិទ្យា។

ទីតាំងសាលារៀន ដែលសិស្សសិក្សាក៏មានទំនាក់ទំនងទៅនឹងការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសផ្នែកសិក្សារបស់ពួកគេដែរ។ បើទោះបីស្ថិតក្នុងបរិបទផ្សេងគ្នាការសិក្សាទាំងពីរនេះបានរកឃើញថា សិស្សដែលសិក្សានៅសាលារៀនក្នុងទីប្រជុំជនមានទំនោរជ្រើសរើសយកផ្នែកវិទ្យាសាស្ត្រ ដោយបានលើកឡើងពីហេតុផលពាក់ព័ន្ធនឹងធនធានគ្រូបង្រៀន និងសម្ភារៈសម្រាប់ដំណើរការបង្រៀននិងរៀន។ ធនធានសាលារៀន ដែលបម្រើដល់ការបង្រៀន និងរៀនក៏ត្រូវបានរកឃើញថាមានផលប៉ះពាល់ដល់ការជ្រើសរើសរបស់សិស្សនៅវិទ្យាល័យ។ សាលារៀនតូចនិងសាលារៀនមធ្យមពុំមានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការដល់ការសិក្សាលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រកម្រិតខ្ពស់ ដូចសាលារៀនធំៗឡើយ ដែលជាហេតុធ្វើឱ្យមានការជ្រើសរើសយកផ្នែកវិទ្យាសាស្ត្រសង្គម។ ម្យ៉ាងទៀតកង្វះគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ សម្ភារៈដំណើរការបង្រៀន និងរៀនបន្ទប់ដូចជា បន្ទប់ពិសោធន៍មុខវិជ្ជាវិទ្យាសាស្ត្របានប៉ះពាល់ទៅដល់ចំណាប់អារម្មណ៍របស់សិស្សក្នុងការសិក្សាមុខវិជ្ជានេះ(នាយកដ្ឋានគោលនយោបាយ,២០២១)។ ស្របជាមួយគ្នានេះដែរ ក៏នៅមានកត្តាសំខាន់ៗមួយចំនួនទៀតដែរ។

### ៣.២.កត្តាសិស្ស

ការជ្រើសរើសថ្នាក់រៀនវាពិតជាមានសារៈសំខាន់ណាស់សម្រាប់អនាគតសិស្ស។ ជាដំបូងពួកគេត្រូវយល់ដឹងពីសមត្ថភាពរបស់ខ្លួនឱ្យបានច្បាស់លាស់ និងត្រូវដឹងពីជំនាញដែលខ្លួនចង់រៀននិងគោលដៅការងារនាពេលអនាគត ហើយត្រូវរៀនឱ្យចំជំនាញនិងចំណង់ចំណូលចិត្តថាខ្លួននឹងត្រូវសិក្សាថ្នាក់វិទ្យាសាស្ត្រឬថ្នាក់វិទ្យាសាស្ត្រសង្គម។ ដោយឡែកសម្រាប់ការសិក្សានៅថ្នាក់ទី១០មិនទាន់មានការបែងចែកមុខវិជ្ជាទេ ពោលគឺនៅសិក្សារួម។ ប៉ុន្តែ នៅពេលដែលសិស្សបន្តមកដល់ថ្នាក់ទី១១ត្រូវធ្វើការសម្រេចចិត្តដើម្បីជ្រើសរើសថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមក្នុងការបន្តរហូតដល់ថ្នាក់ទី១២។

ក្នុងប្រភពទិន្នន័យដែលបានសម្ភាសពីសិស្សនៅក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមបង្ហាញឱ្យឃើញពីបញ្ហាសិស្ស ដែលបានមករៀននៅថ្នាក់សង្គមច្រើនគឺបណ្តាលមកពីមូលហេតុដូចជា ពេលខ្លះសិស្សចូលរៀនតាមគ្នា ដោយមិនបានកំណត់គោលដៅច្បាស់លាស់ ការសិក្សាមិនត្រូវការចំណាយថវិកាច្រើនទៅលើការៀនគួរ ព្រោះផ្តោតសំខាន់តែលើមុខវិជ្ជាមេរៀនប៉ុណ្ណោះ។ ចំណែក ការសិក្សានៅថ្នាក់វិទ្យាសាស្ត្រគឺត្រូវការចំណាយថវិការៀនគួរទៅលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា គណិត រូប គីមី ជីវៈជាដើម។ ទន្ទឹមនឹងនេះ ក៏ផ្អែកទៅលើសមត្ថភាពសិស្សខ្លួនឯង ដោយសិស្សខ្លះមិនមានមូលដ្ឋានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រពីថ្នាក់ក្រោម។ នាពេលកន្លងមកសិស្សបានមើលឃើញពីលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សិស្សនៅផ្នែកសង្គមជាប់ច្រើន។ ហេតុ

ផលដែលសិស្សប្រហែលជា ៨៥ ភាគរយមានទំនោរទៅជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យាសាស្ត្រ ដោយសារពួកគេមិនគិតពីការទទួលនិទ្ទេសល្អក្នុងការប្រឡងថ្នាក់ជាតិឡើយ ពួកគេគ្រាន់តែចង់ប្រឡងឱ្យជាប់តែប៉ុណ្ណោះ។ ចំណែកទីផ្សារការងារមួយចំនួន ពួកគាត់បានយល់ឃើញថាគេយកត្រឹមតែសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិតែប៉ុណ្ណោះ ឱ្យតែប្រឡងជាប់ការងារបានធ្វើដោយមិនកំណត់ថាថ្នាក់វិទ្យាសាស្ត្រឬសង្គមនោះទេ។ រីឯការងារល្អមួយចំនួនជាការងារធ្វើបែបវិទ្យាសាស្ត្រ ប៉ុន្តែនៅពេលដែលប្រឡងចូលក្របខណ្ឌភាគច្រើនចេញតែតែងសេចក្តីទៅវិញ(មុខវិជ្ជាវិទ្យាសាស្ត្រសង្គម)។ មួយវិញទៀត នៅតាមសកលវិទ្យាល័យមួយចំនួនពុំទាន់មានការបែងចែកប្រភេទសញ្ញាបត្រថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមឱ្យបានច្បាស់លាស់នៅឡើយទេ ដោយសិស្សថ្នាក់វិទ្យាសាស្ត្រសង្គមក៏អាចរៀនជំនាញទាក់ទងនឹងវិទ្យាសាស្ត្របានដែរ។ តាមការសម្ភាសជាក់ស្តែងពួកគេបានបង្ហាញយ៉ាងច្បាស់ថា ៖

*«ខ្ញុំមិនចូលរៀនខាងថ្នាក់វិទ្យាសាស្ត្រ ដោយកត្តាខ្ញុំខ្លួនឯង ព្រោះខ្ញុំយល់ថាមានការពិបាក។ ខ្ញុំជ្រើសរើសថ្នាក់សង្គមមិនចំណាយលុយរៀនគួរ ឱ្យតែពូកែទន្ទេញមេរៀន សរសេរចម្លើយឆ្លើយសំណួរឱ្យបានច្រើនៗប្រឡងជាប់ហើយ។ រវាងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ខ្ញុំជ្រើសរើសយកថ្នាក់សង្គម ព្រោះវាងាយប្រឡងជាប់និងមានការយល់ដឹងពីបញ្ហាសង្គមបានច្រើន។ រៀនថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមប្រឡងជាប់ទទួលបានសញ្ញាបត្រដូចតែគ្នា។»*

### ៣.៣. កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន និងសហគមន៍

ក្នុងកត្តាទាំងនេះក៏បានជះឥទ្ធិពលយ៉ាងខ្លាំង ដល់សិស្សនៅក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រសង្គមច្រើនជាងថ្នាក់វិទ្យាសាស្ត្រដែរ។ ពេលខ្លះគណៈគ្រប់គ្រងខ្វះការជំរុញឱ្យគ្រូផ្នែកវិទ្យាសាស្ត្រផលិតសម្ភារៈឧបទ្ទេសងាយៗដើម្បីបម្រើប្រយោជន៍ដល់ការបង្រៀននិងរៀន ព្រោះវាមានលក្ខណៈរូបី ដោយភ្ជាប់ទ្រឹស្តីនិងការអនុវត្តផងដែរ។ នេះជាផ្នែកមួយនៃការទាក់ទាញសិស្សឱ្យមករៀនថ្នាក់វិទ្យាសាស្ត្រឡើងវិញ។ ការតម្រង់ទិសសិក្សារបស់សិស្សថ្នាក់ទី១២ នៅមិនទាន់បានគ្រប់ជ្រុងជ្រោយទូលំទូលាយពីមជ្ឈដ្ឋានជុំវិញនៅឡើយទេ។ ពេលខ្លះខ្វះការលើកទឹកចិត្តពីលោកគ្រូ អ្នកគ្រូដោយគាត់បានពន្យល់ថាវិទ្យាសាស្ត្រសង្គមប្រឡងជាប់ ដោយមិនពិបាកគិតលេខដូចវិទ្យាសាស្ត្រឱ្យតែចងចាំមេរៀនសរសេរបានល្អៗ ក៏អាចប្រលងជាប់ដែរ។ កត្តាមួយទៀតមិនបាច់រៀនគួរ សិស្សរៀនមធ្យមក៏អាចប្រឡងជាប់បានដែរ។ កត្តាទាំងនេះហើយទើបធ្វើឱ្យសិស្សងាកមករៀនថ្នាក់សង្គមច្រើន។

ចំពោះសហគមន៍វិញ ក៏មិនទាន់បានយល់ដឹងជ្រួតជ្រាបពីតម្លៃនៃការសិក្សាថ្នាក់វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៅឡើយ ព្រោះពេលខ្លះខ្វះមធ្យោបាយក្នុងការទំនាក់ទំនងរវាងសហគមន៍និងគណៈ

គ្រប់គ្រងសាលាក្នុងការប្រឹក្សាយោបល់ស្ដីពីការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមដើម្បីផ្សព្វផ្សាយដល់អាណាព្យាបាលសិស្សឱ្យពួកគាត់មានការយល់ដឹងកាន់តែច្បាស់។ បញ្ហាមួយចំនួននេះអាចទាក់ទងទៅនឹងកត្តាតម្រង់ទិសមានរយៈពេលខ្លីពេកគឺធ្វើត្រឹមថ្នាក់ទី១១។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាគួររៀបចំឱ្យមានការតម្រង់ទិសជ្រើសរើសថ្នាក់សិក្សាតាំងពីថ្នាក់ទី៩ ឬទី១០ ព្រោះពេលខ្លះសិស្សថ្នាក់ក្រោមមិនទាន់ដឹងពីថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមជាអ្វី? ឬមុខវិជ្ជាអ្វីខ្លះដែលត្រូវរៀននៅឡើយ។ តាមរយៈការសម្ភាសក៏បានបង្ហាញឱ្យឃើញពីព័ត៌មានមួយចំនួនដូចខាងក្រោម៖

> *«សម្រាប់ខ្ញុំជាគណៈគ្រប់គ្រងនៃវិទ្យាល័យចំណេះទូទៅព្រះរាជសម្ភារ សិស្សមិនចូលរៀនថ្នាក់វិទ្យាសាស្ត្របណ្ដាលមកពីកត្តាខ្លួនឯង ដោយមិនជឿទុកចិត្តលើសមត្ថភាពខ្លួនឯង មិនទាន់មានគោលដៅច្បាស់អាចបណ្ដាលមកពីកត្តាគ្រូខ្លះៗដែរ សិស្សខ្វះការលើកទឹកចិត្ត។ សិស្សជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬ ថ្នាក់វិទ្យាសាស្ត្រសង្គម មិនបណ្ដាលមកពីកម្មវិធីសិក្សាទេ ព្រោះកម្មវិធីសិក្សាមានការកំណត់ចំនួនម៉ោង កំណត់មេរៀន និងកំណត់វត្ថុបំណងច្បាស់លាស់ណាស់។ សិស្សមិនចូលរៀនថ្នាក់វិទ្យាសាស្ត្រអាចបណ្ដាលមកពីកត្តាគ្រូផងដែរ ព្រោះលោកគ្រូ អ្នកគ្រូដែលជាអ្នកប្រឹក្សាអាជីពមិនបានយកចិត្តទុកដាក់ខ្ពស់ក្នុងការតម្រង់ទិសសិស្ស ពេលខ្លះធ្វើឱ្យសិស្សពិបាកសម្រេចចិត្តជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬ វិទ្យាសាស្ត្រសង្គម។ ជួនកាលទៀត សិស្សទទួលគំនាបពីគ្រូឱ្យមករៀនគួរច្រើន។ ចំពោះសាលារៀនទទួលបានលទ្ធផលប្រឡងភាគរយខ្ពស់ តាមរយៈថ្នាក់វិទ្យាសាស្ត្រសង្គម (សាលាបើកថ្នាក់សង្គម) ធ្វើឱ្យសាលារៀនជាប់ចំណាត់ល្អ ទទួលបានការកោតសរសើរពីថ្នាក់ដឹកនាំ (នាយក)។*
>
> *ចំពោះសិស្ស ខ្ញុំយល់ថា ទាំងសិស្សថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់សង្គមមានក្ដីរំភើបរីករាយពេលទទួលបានលទ្ធផលប្រឡងជាប់ (នាយក គ្រូ សហគមន៍ មាតាបិតាសិស្ស)។ ថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គមមានបរិមាណសិស្សចូលសិក្សាមិនស្មើគ្នា(ថ្នាក់វិទ្យាសាស្ត្រសិស្សតិចសង្គមសិស្សច្រើន)ជាក្ដីកង្វល់ទៅអនាគតថ្នាក់វិទ្យាសាស្ត្រ និងមានបរិមាណសិស្សកាន់តែថយតិចថែមទៀត(នាយក គ្រូ)។»*

### ៣.៤. កត្តាគ្រួសារ

តាមរយៈលទ្ធផលនៃការសម្ភាសន៍បានបង្ហាញថា សិស្សទាំងថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមជ្រើសរើសយកបណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រឬវិទ្យាសាស្ត្រសង្គមដោយមានការជួយណែនាំនិងមានការជំរុញពីឪពុកម្ដាយ ឬបងប្អូននៅក្នុងគ្រួសារ។ ឪពុកម្ដាយភាគច្រើនមិនបានចូលរួមទេ តែគាត់យល់

ស្របទៅតាមការសម្រេចចិត្តរបស់កូន ដោយហេតុថាគាត់ចង់ឱ្យកូនរៀនទៅតាមសមត្ថភាពខ្លួនឯងផ្ទាល់ និងដោយសារគាត់មានភាពមមាញឹកក្នុងការងារផ្ទាល់ខ្លួនរបស់គាត់។ ឪពុកម្តាយមួយចំនួនតូចលួចតាមដានការសិក្សារបស់កូនតាមរយៈការទំនាក់ទំនងជាមួយគ្រូបង្រៀនផ្ទាល់ (នាយកដ្ឋានគោលនយោបាយ,២០០១)។

*«ខ្ញុំឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រ ដោយបានពន្យល់ណែនាំថា ការរៀនថ្នាក់វិទ្យាសាស្ត្រមានតម្លៃជាងវិទ្យាសាស្ត្រសង្គម ព្រោះតម្រូវទៅតាមស្ថានភាពទីផ្សារការងារបច្ចុប្បន្ន ស្របនឹងកូនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរៀនថ្នាក់វិទ្យាសាស្ត្រ (សម្ភាសឪពុកម្តាយជាគ្រូបង្រៀន)។ ខ្ញុំគាំទ្រវិធីសាស្ត្របង្រៀន និងសមត្ថភាពរបស់លោកគ្រូ អ្នកគ្រូ ហើយថែមទាំងបានជំរុញកូនបន្ថែមឱ្យមករៀនថ្នាក់វិទ្យាសាស្ត្រ។ កូនក៏ចូលរៀនតាមការចង្អុលបង្ហាញរបស់ខ្ញុំ។» (សម្ភាសឪពុកម្តាយជាគ្រូបង្រៀន)*

*«ខ្ញុំឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គមដោយយល់ថា កូនមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលនៅថ្នាក់វិទ្យាសាស្ត្រ និងខ្លាចកូនប្រឡងធ្លាក់ព្រោះថ្នាក់សង្គម បើតាមដឹងភាគរយនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារមានភាគរយជាប់ច្រើន ទើបខ្ញុំជំរុញឱ្យកូនចូលរៀនថ្នាក់វិទ្យាសាស្ត្រសង្គម។» (សម្ភាសឪពុកជាគ្រូដែលមានកូនរៀននៅថ្នាក់វិទ្យាសាស្ត្រសង្គម)*

*«ខ្ញុំមិនបានដឹងពីថ្នាក់វិទ្យាសាស្ត្រ ឬ ថ្នាក់វិទ្យាសាស្ត្រសង្គមជាអ្វីទេ កូនចង់រៀនមួយណាស្រេចតែវារើសខ្លួនឯងឱ្យតែប្រឡងជាប់គ្រួសារសប្បាយហើយ។»(ឪពុកម្តាយ)*

ដូចនេះ តាមភស្តុតាងខាងលើ ការផ្តល់ប្រឹក្សាយោបល់ពី ឪពុកម្តាយ ឬអាណាព្យាបាលពិតជាបានចូលរួមចំណែកមួយផ្នែកដែរក្នុងការសម្រេចចិត្តរបស់កូនក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់សង្គម។

**៣.៥.កត្តាផ្សេងៗ**

ការអនុវត្តកម្មវិធីសិក្សានេះត្រូវបានគេមើលឃើញថា ថ្នាក់វិទ្យាសាស្ត្រសង្គមមានចំនួនភាគរយសិស្សជាប់ខ្ពស់ជាងថ្នាក់វិទ្យាសាស្ត្រ ហើយបច្ចុប្បន្នថ្នាក់វិទ្យាសាស្ត្រសង្គមបាននឹងកំពុងកើនឡើងជាលំដាប់នៅគ្រប់វិទ្យាល័យ។ ប្រការនេះហើយបានធ្វើឱ្យសិស្សភាគច្រើនចាប់យកថ្នាក់សង្គមជាជាងថ្នាក់វិទ្យាសាស្ត្រ។ សូមលើកយកផលវិជ្ជមាន និងអវិជ្ជមានដូចតទៅ៖ ផលវិជ្ជមាន សិស្សនាពេលបច្ចុប្បន្នប្រឡងមុខវិជ្ជាតិចជាងមុនគឺប្រឡង៧មុខវិជ្ជា ហើយការប្រឡងតិចធ្វើឱ្យសិស្សងាយផ្តោតលើមុខវិជ្ជាដែលត្រូវប្រឡង។ សិស្សថ្នាក់សង្គម ប្រឡងមុខវិជ្ជាមាន ភាសាខ្មែរ គណិត ភូមិវិទ្យា ប្រវត្តិវិទ្យា

សីលធម៌ពលរដ្ឋ ភាសាអង់គ្លេស ហើយកាលពីមុនមុខវិជ្ជា៤ ទៀតត្រូវចាប់ឆ្នោតយកតែមួយ។ មុខវិជ្ជាដែលត្រូវចាប់ឆ្នោតមាន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា។ តែបច្ចុប្បន្នមុខវិជ្ជាទាំង៤នេះគឺតម្រូវឱ្យប្រឡងតែផែនដីវិទ្យា។ ចំណែកសិស្សថ្នាក់វិទ្យាសាស្ត្រវិញប្រឡងភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា។ មុខវិជ្ជាដែលចាប់ឆ្នោតនោះមាន ប្រវត្តិវិទ្យា ភូមិ វិទ្យា និងសីលធម៌ ពលរដ្ឋវិជ្ជាផែនដីវិទ្យា។ តែបច្ចុប្បន្នមុខវិជ្ជាទាំង៤នេះ គឺតម្រូវឱ្យប្រឡងតែប្រវត្តិវិទ្យាតែប៉ុណ្ណោះ។ ជាលទ្ធផលការប្រឡងកន្លងមកសិស្សជាប់និទ្ទេស A មានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ២០១១មក។ ការសិក្សាមុខវិជ្ជាចំនួនតិចនេះក៏ជាការតម្រង់ទិសសិស្ស ដើម្បីងាយស្រួលក្នុងការចាប់យកជំនាញផងដែរ។ ផលអវិជ្ជមាន ការប្រឡងបច្ចុប្បន្នហាក់បីដូចជាមានកំណែប្រែល្អប្រសើរជាលំដាប់ តែក្នុងនោះវាមានផលអវិជ្ជមានពេលអនាគតច្រើនជាង ជាក់ស្តែងការបែងចែកសិស្សវិទ្យាសាស្ត្រ និងសិស្សវិទ្យាសាស្តសង្គមបានធ្វើឱ្យកម្រិតការយល់ដឹងរបស់សិស្សមិនទូលំទូលាយ ព្រោះមុខវិជ្ជាដែលសិស្សរៀនហើយមិនយកមកប្រឡងថ្នាក់ជាតិ ត្រូវបានសិស្សមិនចាប់អារម្មណ៍ ហើយធ្វេសប្រហែស និងអាចជាលេសមិនខិតខំរៀនសូត្រ។ ប្រការនេះកើតមានឡើងលើសិស្សថ្នាក់សង្គម ភាគច្រើនពួកគាត់ធ្វេសប្រហែសក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ ហើយកម្រិតយល់ដឹងលើវិស័យវិទ្យាសាស្ត្រគឺខ្សោយខ្លាំង។ ការបែងចែកនេះមិនត្រូវបានកំណត់មុខវិជ្ជាឡើយ សិស្សអាចបន្តថ្នាក់ឧត្តមសិក្សាគឺសិស្សថ្នាក់វិទ្យាសាស្ត្រក៏អាចរៀនសង្គម ហើយសិស្សសង្គមក៏អាចរៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ ការធ្វើបែបនេះនាំឱ្យសិស្សខ្លះដែលចង់ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ (ជាប់បាក់ឌុប) ចង់រៀនថ្នាក់វិទ្យាសាស្ត្រពិបាកខ្លាំង ហើយសូម្បីតែការប្រឡងនានាក៏ទាមទារប្រឡងមុខវិជ្ជាវិទ្យាសាស្ត្រដែរ ហេតុនេះសិស្សសង្គមមិនអាចប្រកួតប្រជែងបាន។ លើសពីនេះទៀត នៅថ្ងៃអនាគតសង្គមយើងនឹងខ្វះអ្នកបច្ចេកទេសច្រើនថែមទៀត ហើយប្រទេសអភិវឌ្ឍន៍គឺជាប្រទេសដែលមានវិស័យវិទ្យាសាស្ត្ររីកចម្រើន តែនិយាយបែបនេះ មិនមែនថាមុខវិជ្ជាវិទ្យាសាស្ត្រសង្គមមិនសំខាន់នោះទេគឺសំខាន់ដូចគ្នាតែសូមឱ្យតុល្យភាព។ តាមការអង្កេតរបស់ផ្ទាល់ ភាគច្រើនសិស្សចាប់យកមុខវិជ្ជាសង្គម គាត់គិតថាខ្លួនគាត់ខ្សោយមុខវិជ្ជាគណិតវិទ្យា ហើយខ្លះទៀតគឺមិនចង់គិតច្រើនធ្វើយ៉ាងណាឱ្យតែជាប់បាក់ឌុប។ ការយល់ឃើញបែបនេះហើយ ទើបធ្វើឱ្យសិស្សសង្គមមានសមត្ថភាពកាន់តែខ្សោយជាងសិស្សវិទ្យាសាស្ត្រ។ ជាក់ស្តែងសិស្សសង្គមពិបាកនឹងយកនិទ្ទេស A ណាស់ ហើយភាគច្រើនខ្សោយលើការវិភាគគន្លឹះតក្កវិជ្ជា។ ជាសរុប ការបែងចែកសិស្សមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានផលវិជ្ជមាននិងអវិជ្ជមាន ហើយផលអវិជ្ជមានច្រើនទៅថ្ងៃអនាគតគឺចំនួនសិស្សសង្គមបាននឹងកើនឡើង ហើយអាចជាផលប៉ះពាល់ដល់សង្គមព្រោះជនជាតិយើងនឹងមិនមានអ្នកជំនាញបច្ចេកទេស និងវិទ្យាសាស្ត្រច្រើន(វិស្វករ ពេទ្យ ជាដើម)។ ហេតុនេះ

ការឱ្យសិស្សរៀនច្រើនមុខ និងប្រឡងគ្រប់មុខវិជ្ជាជាការល្អ ព្រោះដើម្បីឱ្យពួកគាត់មានសមត្ថភាពនិងចំណេះដឹងទូលំទូលាយទាំងមុខវិជ្ជាសង្គមនិងវិទ្យាសាស្រ្ត នៅកម្រិតចំណេះទូទៅ ហើយកម្រិតចំណេះដឹងមានលក្ខណៈសកល វាជាការសំខាន់ លុះដល់ពេលពួកគាត់ចាប់យកជំនាញនៅថ្នាក់ឧត្តមសិក្សា ចាំពួកគាត់សម្រេចជំនាញដែលគាត់ពេញចិត្ត ក៏មិនទាន់យឺតពេលដែរ។

## ៤. ចំណុចខ្លាំង និងចំណុចខ្សោយ

ទោះបីជាមានការខិតខំប្រឹងប្រែងប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់នៅក្នុងការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ក្រុមការងារស្រាវជ្រាវបានស្វែងយល់ឃើញថា សកម្មភាពក្រុមមានចំណុចវិជ្ជមាន និងអវិជ្ជមានរបស់ខ្លួនមួយចំនួនដូចជា៖

### ៤.១. ចំណុចវិជ្ជមាន

ក្រុមសិក្សាស្រាវជ្រាវបានសហការ សាមគ្គីភាពគ្នាបានយ៉ាងល្អបន្ទាប់ពីបានកំណត់ជ្រើសរើសប្រធានបទដោយមានការពិភាក្សាជាពហុមតិរួចមក ហើយក៏មានការរៀបចំក្រុមពិភាក្សា រៀបចំកំណត់ពេលវេលា កំណត់សមាសភាពចូលរួមសម្ភាស។ ក្រុមស្រាវជ្រាវបានរៀបចំកម្រងសំណួរទៅតាមគោលដៅសម្ភាសន៍ ដើម្បីប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា។ សមាសភាពពាក់ព័ន្ធដែលបានចូលរួមមានការពេញចិត្ត និងសហការជាមួយក្រុមស្រាវជ្រាវដោយក្តីសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត។

### ៤.២. ចំណុចអវិជ្ជមាន

ក្រុមការងារស្រាវជ្រាវមានពេលវេលាខ្លីសម្រាប់ការស្រាវជ្រាវប្រមូលព័ត៌មាន។ ក្រុមការងារស្រាវជ្រាវមិនបានសម្ភាសគ្រប់សមាសភាពដែលបានកំណត់ទុក។ ការប្រមូលឯកសារពិគ្រោះនៅមានកំណត់ដោយសារពេលវេលាខ្លី ហើយក្រុមការងារស្រាវជ្រាវយើងខ្ញុំក៏មានការលំបាក ព្រោះជាពេលវេលាក្នុងបរិបទជំងឺCovid-19 កំពុងរីករាលដាលក្នុងសហគមន៍ ជាហេតុធ្វើឱ្យមានការលំបាកដល់ក្រុមការងារស្រាវជ្រាវក្នុងការប្រមូលព័ត៌មានព្រោះពេលខ្លះត្រូវធ្វើការសម្ភាសពីចម្ងាយតាមរយៈទូរស័ព្ទ ឬប្រព័ន្ធ Zoom ។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមរយៈទិន្នន័យ និងលទ្ធផលដែលទទួលបានមកបានឆ្លុះបញ្ចាំងឱ្យឃើញថា សិស្សដែលជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្រ្តសង្គមច្រើនបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា កត្តា

សាលារៀន កត្តាសិស្ស កត្តាគណៈគ្រប់គ្រង កត្តាគ្រូបង្រៀន សហគមន៍ កត្តាគ្រួសារ និងកត្តារួមផ្សំផ្សេងៗទៀត។ ក្នុងចំណោមកត្តាទាំងនេះ កត្តាដែលជះឥទ្ធិពលខ្លាំងក្នុងការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ ឬសង្គមគឺកត្តាសិស្សខ្លួនឯងដោយសារគាត់មិនបានទទួលការប្រឹក្សាយោបល់គ្រប់ជ្រុងជ្រោយពីលោកគ្រូ អ្នកគ្រូ និងមជ្ឈដ្ឋានជុំវិញ។ លើសពីនេះទៀតសិស្សខ្លះតែងតែមានការព្រួយបារម្ភនៅក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត ឬថ្នាក់សង្គម។ សិស្សដែលមានសមត្ថភាពខាងវិទ្យាសាស្ត្រគាត់មិនរុញរាក្នុងការចូលរៀនថ្នាក់វិទ្យាសាស្ត្រ។ ចំណែកឯសិស្សដែលមានសមត្ថភាពខ្សោយខាងវិទ្យាសាស្ត្រគាត់ជ្រើសរើសចូលរៀនថ្នាក់សង្គម ។

## ៥.១.អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវរកឃើញពីកត្តាដែលសិស្សជ្រើសរើសរៀនថ្នាក់វិទ្យាសាស្ត្រមានចំនួនតិចជាងថ្នាក់វិទ្យាសាស្ត្រសង្គម ក្រុមការងារស្រាវជ្រាវ សូមផ្តល់ជាអនុសាសន៍មួយចំនួនដូចជា៖ លោកគ្រូ អ្នកគ្រូ ជាអ្នកប្រឹក្សាអាជីពត្រូវតែយកចិត្តទុកដាក់និងមានឆន្ទៈខ្ពស់បំផុតក្នុងការតម្រង់ទិសនិងលើកទឹកចិត្តសិស្ស ដើម្បីឱ្យសិស្សយល់ពីតម្លៃនៃការជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមតាមសមត្ថភាពនិងឧបនិស្ស័យដែលខ្លួនពេញចិត្ត។ ទន្ទឹមនឹងនេះដែរ លោកគ្រូ អ្នកគ្រូថ្នាក់វិទ្យាសាស្ត្រទាំងអស់ (គណិត រូប គីមី ជីវៈ និងផែនដី) ក៏ដូចជាលោកគ្រូ អ្នកគ្រូឯកទេសដទៃៗទៀតត្រូវតែបង្កើន និងពង្រឹងសមត្ថភាពទាំងចំណេះដឹងឯកទេសនិងវិធីសាស្ត្របង្រៀនដើម្បីផ្តល់ទំនុកចិត្តចំពោះសិស្សានុសិស្ស។ បន្ថែមពីនេះ គណៈគ្រប់គ្រងសាលាត្រូវមានការទំនាក់ទំនងយ៉ាងជិតស្និតជាមួយសហគមន៍ អាណាព្យាបាល មាតាបិតាសិស្ស ដើម្បីពន្យល់ដល់ពួកគាត់ឱ្យដឹងពីគុណតម្លៃនៃការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងការងាយស្រួលជួយចូលរួមចំណែកតម្រង់ទិសកូន។ ស្របជាមួយគ្នានេះដែរ ក៏ត្រូវជួយលើកទឹកចិត្តដល់សិស្សានុសិស្សគ្រប់គ្នាក្នុងការជ្រើសរើសរៀនថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមឱ្យស្របតាមសមត្ថភាព និងឧបនិស្ស័យដែលសិស្សមាន។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរតែពិចារណាទៅលើមុខវិជ្ជាមួយចំនួនក្នុងកម្មវិធីសិក្សា ដើម្បីឱ្យសិស្សផ្តល់តម្លៃឡើងវិញនៅក្នុងការប្រឡង ហើយសូមឱ្យមានការរៀបចំតម្រង់ទិសសិស្សចាប់តាំងពីថ្នាក់ទី៩ ឬទី១០ឱ្យបានយល់ដឹងពីថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ម្យ៉ាងវិញទៀត សូមមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍ មាតាបិតាសិស្ស ហើយក៏សូមឱ្យសិស្សខ្លួនឯងមានជំហរមួយ ច្បាស់លាស់ក្នុងការជ្រើសរើសចូលរៀនថ្នាក់វិទ្យាសាស្ត្រ ឬសង្គមជៀសវាងការតាមមិត្តភក្តិអូសទាញ។

## ឯកសារយោង

នាយកដ្ឋានគោលនយោបាយ. (២០២១). កត្តាជះឥទ្ធពលលើការជ្រើសរើសថ្នាក់វិទ្យាសាស្ត្រនិងសង្គមនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងប្រទេសកម្ពុជា។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (២០១១). ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ និងទី១២ ។

ការផ្សាយចេញពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ( ២០១២). ស្តង់ដារកម្មវិធិសិក្សាថ្នាក់ទី១២ ។

លិខិតលេខ ២៤៥៤ អយក.សណន (ឆ្នាំ?). សេចក្តីណែនាំស្តីការអនុវត្តកម្មវិធីសិក្សាចំណេះទៅនៅមធ្យមសិក្សាទុតិយភូមិ ។

យោងលិខិតលេខ ៣៦៤៤ អយក អកស (១៩-១០-២០១១). ស្តីពី " ការអនុវត្តកម្មវិធីសិក្សាថ្មីចំណេះទូទៅថ្នាក់ទី១១ និងទី១២ "PhuongSokhttps://serey.io/imageupload data/22142ef3f2fb29662143eecd9ca548adec16405(០១-១៨-២០២០)

រក្សាសិទ្ធិ© កាលិកាបត្រអប់រំកម្ពុជា នាយកដ្ឋានគោលនយោបាយ
ក្រសួងអប់រំ យុវជន និងកីឡា ប្រទេសកម្ពុជា

អ៊ីមែល: *cer.editor@moeys.gov.kh*
វេបសាយ: *www.dopomoeys.com*